ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍
# ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា
# ប្រចាំឆ្នាំ២០២៤



ស័ក្តិសិទ្ធភាព នវានុវត្តន៍ និងបរិយាបន្ន

# អារម្ភកថា

ប្រព័ន្ធទូទាត់សងប្រាក់បានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ទំនើបកម្មប្រព័ន្ធទូទាត់ទាំងតម្លៃរាយនិងតម្លៃធំបានបង្កើនប្រសិទ្ធភាពក្នុងការទូទាត់ទាំងនៅទីប្រជុំជន និងជនបទ ដែលបានចូលរួមចំណែកកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ជាច្រើនដំណាក់កាលក្នុងគោលដៅឱ្យស្របទៅតាមការអភិវឌ្ឍនៃសេដ្ឋកិច្ច និងការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ជាក់ស្តែង ការដាក់ឱ្យដំណើរការប្រព័ន្ធបាគង និងស្តង់ដារឃ្យូអរកូត បានជំរុញការទូទាត់ជាអេឡិចត្រូនិកកាន់តែមានភាពងាយស្រួល ជាពិសេសបានផ្តល់លទ្ធភាពឱ្យប្រទេសកម្ពុជា ក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ជាមួយបណ្តាប្រទេសក្នុងតំបន់និងអន្តរជាតិ។ ធនាគារជាតិនៃកម្ពុជា បានបន្តតភ្ជាប់ប្រព័ន្ធទូទាត់ និងបានដាក់ឱ្យដំណើរការជាផ្លូវការនូវការទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសកម្ពុជានិងប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ ក្រុមហ៊ុនអាលីផេ និងកំពុងបន្តអភិវឌ្ឍការតភ្ជាប់ប្រព័ន្ធជាមួយបណ្តាប្រទេសផ្សេងៗទៀត សំដៅគាំទ្រវិស័យទេសចរណ៍និងពាណិជ្ជកម្ម។ លើសពីនេះ កម្មវិធីទូទាត់បាគងទេសចរ ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីសម្រួលដល់ភ្ញៀវទេសចរក្នុងការទូទាត់ទំនិញនិងសេវាតាមរយៈខេអេចឃ្យូអរកូតរបស់ពាណិជ្ជករទូទាំងប្រទេសប្រកបដោយភាពងាយស្រួលនិងមានសុវត្ថិភាព កាត់បន្ថយការប្រើប្រាស់ធនប័ត្រ។ ធនាគារជាតិនៃកម្ពុជា ក៏បានដាក់ដំណើរការសាកល្បង (Roll Out) ប្រព័ន្ធទូទាត់សងប្រាក់រួម ដែលធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗជាប្រព័ន្ធទូទាត់រួមតែមួយ ក្នុងគោលបំណងសម្រួលដល់សាធារណជនឱ្យមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់អន្តរគ្រឹះស្ថាន។ វិធាននិងនីតិវិធីនៃប្រព័ន្ធទូទាត់សងប្រាក់រួមនេះក៏កំពុងត្រូវបានរៀបចំ ដើម្បីឱ្យគ្រឹះស្ថានសមាជិកអនុវត្តតាមប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុក៏បានផ្តល់ឱកាសជាច្រើនដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការដាក់ឱ្យប្រើប្រាស់សេវាហិរញ្ញវត្ថុផ្សេងៗទៀតក្នុងទីផ្សារ។ ជាក់ស្តែង ការដាក់ឱ្យប្រើប្រាស់កម្មវិធីធនាគារតាមរយៈទូរស័ព្ទចល័តបានផ្តល់លទ្ធភាពសម្រាប់សាធារណជនអាចធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងតាមរយៈប្រព័ន្ធអនឡាញ និងបានក្លាយជាចលករដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល តាមរយៈការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់ និងក្លាយជាកត្តាមួយដ៏សំខាន់ក្នុងការជំរុញសកម្មភាពធុរកិច្ច លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ផ្តល់ព័ត៌មានបន្ថែមសម្រាប់ការសម្រេចចិត្តផ្តល់ឥណទាន និងទទួលបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ ចំនួនប្រតិបត្តិការ និងទំហំប្រាក់នៃការទូទាត់សងប្រាក់ឌីជីថលបានកើនឡើង ៧៨% និង ៣៨% រៀងគ្នាធៀបនឹងឆ្នាំ២០២៣ ហើយទំហំប្រាក់ស្មើនឹងប្រមាណ ១៥ ដងនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។

ដើម្បីធានាថាប្រព័ន្ធទូទាត់បានរួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិសមស្របសម្រាប់គ្រប់គ្រង ធានានូវស្ថិរភាពនិងនិរន្តរភាពនៃដំណើរការប្រព័ន្ធ កាត់បន្ថយហានិភ័យជាប្រព័ន្ធ និងការពារផលប្រយោជន៍អតិថិជនជាកត្តាចាំបាច់។ ក្នុងនាមជាប្រតិបត្តិករប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីជាភ្នាក់ងារទូទាត់ដោយតម្រូវឱ្យគ្រឹះស្ថានជាសមាជិករក្សាគណនីទូទាត់នៅធនាគារជាតិនៃកម្ពុជាសម្រាប់ការទូទាត់

ចុងក្រោយ ដើម្បីកាត់បន្ថយហានិភ័យសន្ទនីយភាព ហានិភ័យនៃការទូទាត់មិនប្រក្រតីឬពន្យារពេលទូទាត់។ លើសពីនេះ ប្រព័ន្ធទូទាត់សងប្រាក់ដែលបានធ្វើបច្ចុប្បន្នកម្មកន្លងមកគាំទ្រការធ្វើប្រតិបត្តិការ និងការទូទាត់ភ្លាមៗ ដោយរាល់ការទូទាត់បញ្ចប់នៅក្នុងប្រព័ន្ធត្រូវបានធ្វើឡើងភ្លាមៗ ការពារអ្នកប្រើប្រាស់ពីការក្លែងបន្លំ ឬកំហុសណាមួយជាពិសេសកាត់បន្ថយហានិភ័យសមភាគីបានយ៉ាងមានប្រសិទ្ធភាព។ ក្នុងគោលបំណងធានាបាននូវនិរន្តរភាពប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់ជាប្រចាំធៀបជាមួយគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍អន្តរជាតិ ហើយយន្តការនេះអនុវត្តឡើងដើម្បីទប់ស្កាត់ និងបង្ការនូវហានិភ័យចម្បងៗដែលកើតមានឡើងនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រកាសមួយចំនួនហើយក៏កំពុងបន្តរៀបចំប្រកាសពាក់ព័ន្ធបន្ថែមទៀត ក្នុងគោលដៅគាំទ្រនិងជំរុញការអភិវឌ្ឍប្រកបដោយសុវត្ថិភាព និងចីរភាព។

សមិទ្ធផលគួរជាទីមោទនៈនេះ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដាក់ចេញគោលនយោបាយ និងបទប្បញ្ញត្តិព្រមទាំងអនុវត្តការត្រួតពិនិត្យ ដើម្បីគាំទ្រនិងជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ដែលជាស្នាដៃមិនអាចកាត់ថ្លៃបានរបស់ **ឯកឧត្តម ជា ចាន់តូ** អតីតទេសាភិបាល និងជាទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជាបានបន្សល់ទុកសម្រាប់ធនាគារជាតិនៃកម្ពុជាទាំងមូល។ មូលដ្ឋានគ្រឹះដ៏រឹងមាំនេះ បានផ្តល់ជាកាលានុវត្តភាពដល់ធនាគារជាតិនៃកម្ពុជា អាចអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីចូលរួមគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ របស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ការបំពេញភារកិច្ចរបស់មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដែលបានរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើនជាលំដាប់ និងដំណើរការប្រកបដោយពិលាស មានសុវត្ថិភាព និងប្រសិទ្ធភាព។ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដែលបានផ្តល់កិច្ចសហការល្អ និងជិតស្និទ្ធនាពេលកន្លងមក។ របាយការណ៍ប្រចាំឆ្នាំ២០២៤ ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជានេះ នឹងក្លាយជាឯកសារដ៏មានតម្លៃសម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ និងជាព័ត៌មានដល់ភាគីពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់អំពីការយកចិត្តទុកដាក់ខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងឥតស្រាកស្រាន្តរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ពង្រឹងសមត្ថភាព និងបង្កើនផលិតភាពនៃប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីបម្រើផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាទាំងមូលឱ្យកាន់តែល្អប្រសើរ។

**ទេសាភិបាល**

**ជា សិរី**

# មាតិកា


អារម្ភកថា | i

បញ្ជីក្រាហ្វ និងប្រអប់ | v

អក្សរកាត់ | vii

បរិយាយសង្ខេប | ix

ស្ថិតអំពីស្ថានភាពសេវាទូទាត់សងប្រាក់ | xiii

១ វឌ្ឍនភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់ | ១
- ការអភិវឌ្ឍចម្បងៗ | ១
- គោលនយោបាយគាំទ្រ | ៣
- ជំហានបន្ទាប់ | ៦

២ នវានុវត្តន៍ប្រព័ន្ធបាគង | ៨
- វឌ្ឍនភាពប្រព័ន្ធបាគង | ៨
- នវានុវត្តន៍ប្រព័ន្ធបាគង | ១១

៣ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ១៧
- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ | ១៧
- ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ | ២៧

៤ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ | ២៩
- សេចក្តីផ្តើម | ២៩
- វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ| ៣០

៥ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់ | ៣៧
- ទិដ្ឋភាពទូទៅ និងការវិវត្ត | ៣៧
- ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៤១
- ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៤២
- ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៤៤

៦ ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន | ៤៥
- កិច្ចសហប្រតិបត្តិការទ្វេភាគី លើគម្រោងផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន | ៤៥
- ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន | ៥៣
- កិច្ចសហប្រតិបត្តិការពហុភាគីលើគម្រោងទូទាត់សងប្រាក់ឆ្លងដែន | ៥៦

៧ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល | ៥៩
- ហេតុអ្វីបានជាប្រព័ន្ធបាគងត្រូវបានចាត់ទុកជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល | ៥៩
- ច្រករបៀងតម្លាភាពហិរញ្ញវត្ថុ | ៦០
- គម្រោងសាកល្បង Universal Trusted Credentials (UTC) | ៦១

# មាតិកា


**ឧបសម្ព័ន្ធ** | ៦២

ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ | ៦២

ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង | ៦៥

ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៦៧

ឧបសម្ព័ន្ធ ៤ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក | ៧១

ឧបសម្ព័ន្ធ ៥ - គោលការណ៍ទាំង ២៤ របស់គោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) | ៧៣

# បញ្ជីក្រាហ្វ តារាង និងប្រអប់

## ក្រាហ្វ

ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរ និងទំហំប្រាក់ទូទាត់តាមប្រព័ន្ធឌីជីថលជាប្រាក់រៀល ................. ២
ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code ............................... ៣
ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់កម្មវិធីបាគង .................................................... ៩
ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង ........................................................ ១០
ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់ និងបន្ទាប់ពីបានដាក់ដំណើរការ ជាផ្លូវការប្រព័ន្ធបាគង ............................................................................................. ១០
ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ........................................................... ១៨
ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក .................. ២០
ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ FAST ................................................................ ២១
ក្រាហ្វ ៩ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធខេមបូឌានស្វិច ........................................ ២៣
ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធធនាគារអនឡាញ ........................................... ២៥
ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT ......................................... ២៦
ក្រាហ្វ ១២ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា .................. ២៧
ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះគណនី E-wallet និងអតិថិជន Walk-in របស់គ្រឹះស្ថាន ផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ .......៣៧
ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត តាមកាបូបអេឡិចត្រូនិក (Mobile E-wallet) ............................................................................................ ៣៨
ក្រាហ្វ ១៥ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ ................................ ៣៨
ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវា ធនាគារចល័ត ........................................................................................... ៣៩
ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ) ............... ៣៩

ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM និងម៉ាស៊ីន POS ........................................................ ៤០

ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code ...................... ៤១

ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ............................ ៥៤

ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS .............. ៥៥

## ប្រអប់

ប្រអប់ ១ - កម្មវិធីទូទាត់បាគងទេសចរ ........................................................................ ១៤

ប្រអប់ ២ - ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard .......................................................................... ១៥

ប្រអប់ ៣ - យុទ្ធនាការប្តូរប្រាក់ចាស់ ទក់ រហែក តាមរយៈការផ្ទេរប្រាក់ចូលគណនីបាគង ឬ គណនីធនាគាររបស់គ្រឹះស្ថានធនាគារ .................................................................. ១៦

ប្រអប់ ៤ - លំហូរប្រតិបត្តិការនៃការទូទាត់របស់ភ្ញៀវទេសចរថៃនៅក្នុងប្រទេសកម្ពុជា ........... ៤៧

ប្រអប់ ៥ - លំហូរប្រតិបត្តិការនៃការទូទាត់របស់ភ្ញៀវទេសចរកម្ពុជានៅក្នុងប្រទេសថៃ............. ៤៨

ប្រអប់ ៦ - ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្តាល Lesotho.................... ៥២

## តារាង

តារាង ១ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រជាប្រាក់រៀល និងដុល្លារអាមេរិក .............. ១៨

តារាង ២ - ការផាត់ទាត់ និងទូទាត់បញ្ជាផ្ទេរឥណទានជាប្រាក់រៀល និងដុល្លារអាមេរិក ........... ២០

តារាង ៣ - ប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS .......................................................២២

តារាង ៤ - ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលតាមប្រព័ន្ធ OBS ........................... ២៤

តារាង ៥ - ការផ្ទេរប្រាក់នៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តតាមប្រព័ន្ធ OBS ............២៤

តារាង ៦ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT.............................................២៦

# អក្សរកាត់

| | | |
|---|---|---|
| ATM | Automated Teller Machine | ម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិ |
| BAKONG | BAKONG System | ប្រព័ន្ធបាគង |
| BKLV | Bakong Large Value | ប្រព័ន្ធបាគងតម្លៃធំ |
| BCM | Business Continuity Management | ការគ្រប់គ្រងផែនការនិរន្តរភាពប្រព័ន្ធ |
| BIN | Bank Identification Number | លេខអត្តសញ្ញាណធនាគារ |
| CBC | Credit Bureau Cambodia | ការិយាល័យឥណទានកម្ពុជា |
| CPSS and IOSCO | Committee on Payment and Settlement Systems and International Organization of Securities Commissions | គណៈកម្មការប្រព័ន្ធទូទាត់ និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ |
| CSS | Cambodian Shared Switch | ប្រព័ន្ធខេមបូឌានស៊ែស្វីច |
| DLT | Distributed Ledger Technology | បច្ចេកវិទ្យាឌីអិលធី |
| DPI | Digital Public Infrastructure | ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល |
| ECS | Electronic Clearing System | ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក |
| EMV | Europay, Mastercard, and VISA | ស្តង់ដារអ៊ីអឹមវី |
| FAST | FAST Payment System | ប្រព័ន្ធសេវាទូទាត់រហ័ស |
| FINTECH | Financial Technology | បច្ចេកវិទ្យាហិរញ្ញវត្ថុ |
| FTC | Financial Transparency Corridor | គម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ |
| IPS | Integrated Payment System | ប្រព័ន្ធទូទាត់សងប្រាក់រួម |
| ISO | International Organization for Standardization | អង្គការស្តង់ដារអន្តរជាតិ |

| | | |
|---|---|---|
| ITRS | International Transactions Reporting System | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ |
| KHQR Code | Khmer Quick Response Code | ខេអេចឃ្យូអរកូត |
| KYC | Know Your Customer | នីតិវិធីស្គាល់អតិថិជន |
| MSMEs | Micro, Small, and Medium-Sized Enterprises | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| NCS | National Clearing System | ប្រព័ន្ធផាត់ទាត់ជាតិ |
| OBS | Online Banking System | ប្រព័ន្ធធនាគារអនឡាញ |
| PFMI | Principles for Financial Market-Infrastructures | គោលការណ៍សម្រាប់-ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ |
| POS | Point of Sale | ម៉ាស៊ីនឆូតកាត |
| QPS | QR Code Payment System | ប្រព័ន្ធទូទាត់តាមឃ្យូអរកូត |
| QR Code | Quick Response Code | ឃ្យូអរកូត |
| RETAIL PAY | Retail Pay System | ប្រព័ន្ធរីថែលផេ |
| RFT | Real-Time Fund Transfer System | ប្រព័ន្ធផ្ទេរប្រាក់ភ្លាមៗ |
| SME | Small-Medium Enterprise | សហគ្រាសធុនតូច និងមធ្យម |
| STP | Straight Through Processing | ប្រតិបត្តិការជាលក្ខណៈស្វ័យប្រវត្តិ |
| SWIFT | The Society for Worldwide Interbank Financial Telecommunication | បណ្ដាញទូរគមនាគមន៍ហិរញ្ញវត្ថុនៃធនាគារទូទាំងពិភពលោក |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UPI | UnionPay International | ក្រុមហ៊ុនទូទាត់អន្តរជាតិយូញៀនផេ |
| UTC | Universal Trusted Credentials | គម្រោងកសាងអត្តសញ្ញាណដែលគួរឱ្យទុកចិត្តសកល |

# បរិយាយសង្ខេប

ការអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ជាកត្តាសំខាន់មួយក្នុងការលើកកម្ពស់លទ្ធភាពធ្វើប្រតិបត្តិការឆ្លងគ្នារវាងគ្រឹះស្ថានធនាគារដែលនឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ។ សមិទ្ធផលថ្មីៗរបស់ប្រព័ន្ធទូទាត់សងប្រាក់បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការដាក់ឱ្យប្រើសេវា និងឧបករណ៍ទូទាត់សងប្រាក់ប្រកបដោយនវានុវត្តន៍ ដែលមានតម្លៃសមរម្យ និងមានលក្ខណៈទូលំទូលាយ ផ្តល់លទ្ធភាពឱ្យប្រជាជននៅតាមជនបទអាចប្រើប្រាស់សេវាទូទាត់សងប្រាក់ តាមរយៈសេវាហិរញ្ញវត្ថុផ្លូវការ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។ ដើម្បីឆ្លើយតបទៅនឹងរបត់ថ្មីនៃការទូទាត់ឌីជីថល និងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ជាបន្តបន្ទាប់រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធរីថៃលផេ (Retail Pay) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) សម្រាប់សម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថានប្រកបដោយភាពងាយស្រួល សុវត្ថិភាព និងរក្សាប្រក្រតីភាពនៃសកម្មភាពទូទាត់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ក្នុងគោលបំណងសម្រួលដល់សាធារណជនឱ្យមានភាពងាយស្រួល ក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថានទាំងតម្លៃរាយនិងតម្លៃធំ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម ដែលធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗជាប្រព័ន្ធទូទាត់រួមតែមួយ កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ និងមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥២ បានដាក់ដំណើរការសាកល្បងប្រព័ន្ធ។ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំវិធាននិងនីតិវិធី និងឯកសារក្របខណ្ឌគតិយុត្តពាក់ព័ន្ធ ដើម្បីគាំទ្រកិច្ចដំណើរការប្រព័ន្ធនិងទុកជាចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិក។

ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជំនាន់ថ្មី ២.0 និងបានដាក់ដំណើរការដោយរលូនសម្រាប់ប្រតិបត្តិការទូទាត់តាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការធ្វើប្រតិបត្តិការបានប្រសើរជាងមុន។ ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល មានការថយចុះទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ដោយចំនួនប្រតិបត្តិការថយចុះក្នុងអត្រា ៩,១១% និងទំហំប្រាក់ថយចុះក្នុងអត្រា ១,៦0% បើធៀបនឹងឆ្នាំ២០២៣។ ចំណែកឯចំនួនប្រតិបត្តិការមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិក មានការថយចុះ ប៉ុន្តែទំហំប្រាក់មានការកើនឡើង ដោយចំនួនប្រតិបត្តិការថយចុះក្នុងអត្រា២,៥៨% និងទំហំប្រាក់កើនឡើងក្នុងអត្រា

២៩,៦១%។ ចំពោះប្រតិបត្តិការបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកជាប្រាក់រៀល មានការកើនឡើងទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ដោយចំនួនប្រតិបត្តិការកើនឡើងក្នុងអត្រា ៣៣,៥៥% និងទំហំប្រាក់កើនឡើងក្នុងអត្រា ៧,៣៨% ។ ចំណែកឯ ចំនួនប្រតិបត្តិការបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកជាប្រាក់ដុល្លារអាមេរិក មានការថយចុះ ប៉ុន្តែ កើនឡើងក្នុងទំហំប្រាក់ ដោយចំនួនប្រតិបត្តិការថយចុះក្នុងអត្រា ៣,៣៣% និង ទំហំប្រាក់បានកើនឡើងក្នុងអត្រា ១៧,៣៥% ។ ទន្ទឹមនេះ ទំហំប្រាក់ប្រតិបត្តិការតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងអត្រា ៨៩,៧០%។ រីឯប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារអនឡាញបានកើនឡើងគួរឱ្យកត់សម្គាល់ទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់។ ដោយឡែក ប្រតិបត្តិការតាមរយៈប្រព័ន្ធខេមបូឌានស៊ែស្វីច និងប្រព័ន្ធរីធែលផេ មាននិន្នាការថយចុះស្របពេលទំហំប្រាក់ប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកតាមរយៈប្រព័ន្ធបាគងមានសន្ទុះកើនឡើងក្នុងអត្រាប្រមាណ ១២១% និង ៩០% រៀងគ្នា បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងត្រូវបានអភិវឌ្ឍឡើងដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាព ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងលើកកម្ពស់ការទូទាត់ជាប្រាក់រៀល។ នៅក្នុងឆ្នាំ២០២៤នេះ ការប្រើប្រាស់ប្រព័ន្ធបាគងនៅប្រទេសកម្ពុជាមានសន្ទុះកើនឡើងយ៉ាងខ្លាំង ដែលនេះបង្ហាញពីភាពពេញនិយម និងភាពរីកចម្រើននៃការទូទាត់តាមឌីជីថល ជាពិសេសការផ្ទេរប្រាក់ និងទូទាត់តាមយូ្សអរកូត។ ដោយមើលឃើញពីភាពជោគជ័យនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់ឆ្លងដែន និងបានដាក់ដំណើរការជាផ្លូវការជាមួយប្រទេសក្នុងតំបន់ និងដៃគូសហការរួមមាន ប្រទេសកូរ៉េខាងត្បូង ថៃ ម៉ាឡេស៊ី ឡាវ វៀតណាម ក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UPI) ក្រុមហ៊ុនអាលីផេ (Alipay) និងកំពុងបន្តអភិវឌ្ឍគម្រោងទូទាត់ឆ្លងដែនជាមួយបណ្តាប្រទេសផ្សេងទៀតដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា និងសិង្ហបុរី។ កម្មវិធីទូទាត់បាគងទេសចរ ត្រូវបានដាក់ឱ្យដំណើរការបឋម សម្រាប់ភ្ញៀវទេសចរអន្តរជាតិដែលមកកម្សាន្តនៅប្រទេសកម្ពុជាអាចប្រើប្រាស់ដើម្បីទូទាត់ទំនិញ និងសេវាដោយប្រើខេអេចយូ្សអរកូត (KHQR Code) ភ្ជាប់ជាមួយប័ណ្ណទូទាត់អន្តរជាតិផ្សេងៗ។ ទន្ទឹមនេះ បន្ទាប់ពីដាក់ឱ្យដំណើរការដោយជោគជ័យប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់រាយ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការបឋម (Pilot) ប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំដោយប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី (DLT) ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព សុវត្ថិភាព លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ និងផ្តល់ភាពងាយស្រួលដល់អតិថិជនមួយកម្រិតទៀត។

ដើម្បីជំរុញដល់សកម្មភាពពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែន ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី អភិវឌ្ឍគម្រោង FTC ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល (DPI) សម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុន (ការអនុញ្ញាត និងការផ្តល់សិទ្ធ) រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិក ដើម្បីសម្រួលដល់សហគ្រាស

ធុនមីក្រូ តូច និងមធ្យម (MSMEs) ក្នុងការធ្វើសកម្មភាពពាណិជ្ជកម្មនិងហិរញ្ញវត្ថុឆ្លងដែន។ តាមរយៈច្រករបៀងនេះ MSMEs អាចមានលទ្ធភាពផ្ទៀងផ្ទាត់តម្រូវការរវាងគ្នាទៅវិញទៅមកបានកាន់តែងាយស្រួល និងអាចពង្រីកវិសាលភាពទីផ្សាររបស់ខ្លួនបានកាន់តែទូលំទូលាយ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អភិវឌ្ឍគម្រោង UTC សាកល្បង ដើម្បីរៀបចំក្របខណ្ឌទិន្នន័យដែលអាចជឿទុកចិត្តបានដោយអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ កាត់បន្ថយហានិភ័យនៃកិច្ចសន្យាធានា MSMEs និងផ្តល់លទ្ធភាពដល់ MSMEs អាចទទួលបានសេវាហិរញ្ញវត្ថុងាយស្រួល ព្រមទាំងអាចកាត់បន្ថយតម្រូវការនៃវត្ថុធានា។ គម្រោង UTC នេះ មិនត្រឹមតែសម្រួលដល់ដំណើរការនៃការបញ្ជាក់ព័ត៌មាន (Authentication Process) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងទំនុកចិត្តរវាងគ្រឹះស្ថាន ដោយធានាថាការអនុញ្ញាតនិងការផ្តល់សិទ្ធ (Authorization and Consent) DPI គឺគោរពតាមតម្រូវការរបស់ម្ចាស់ទិន្នន័យនិងព័ត៌មាន។

ធនាគារជាតិនៃកម្ពុជា បានបន្តដាក់ឱ្យអនុវត្តស្តង់ដារឧបករណ៍ទូទាត់សងប្រាក់ជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ប្រតិបត្តិការអន្តរគ្រឹះស្ថាន និងសុវត្ថិភាពក្នុងការទូទាត់។ ជាក់ស្តែងធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យប្រើប្រាស់ស្តង់ដារឃ្យូអរកូដដែលអនុញ្ញាតឱ្យអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាមានលទ្ធភាពធ្វើប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងគ្រឹះស្ថាន ស្តង់ដារលេខអត្តសញ្ញាណធនាគារ (BIN ៩១១៦) លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ស្តង់ដារ EMV Chip សម្រាប់ប័ណ្ណទូទាត់ និងមូលប្បទានបត្រស្តង់ដារ ដើម្បីសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន។ ចំណែកឯគោលការណ៍សុវត្ថិភាពនៅលើម៉ាស៊ីនដាក់/ដកប្រាក់ (ATM) និង/ឬ ម៉ាស៊ីនឆូតកាត (POS) ក៏ត្រូវបានដាក់ឱ្យសមាជិកប្រព័ន្ធ CSS អនុវត្តផងដែរ។

ស្របពេលនឹងការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ សេវាទូទាត់សងប្រាក់ឌីជីថលមានការរីកចម្រើនជាលំដាប់នៅក្នុងប្រទេសកម្ពុជា។ ការកើនឡើងនូវចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានធនាគារ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ បានជំរុញឱ្យមានការប្រកួតប្រជែង និងពង្រីកសេវាទូទាត់និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិកកាន់តែទូលំទូលាយនៅក្នុងប្រទេស ដូចជា ផ្ទេរប្រាក់ ដាក់/ដកប្រាក់ សេវាទូទាត់វាយ ទូទាត់វិក្កយបត្រ ទូទាត់អនឡាញ ផ្ទេរប្រាក់ឆ្លងដែន និងការទូទាត់តាមគម្រោងទូទាត់អន្តរជាតិ។ សេវាទូទាត់សងប្រាក់ឌីជីថលដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានការកើនឡើងចំនួនប្រមាណ ៤៧,២% ធៀបនឹងឆ្នាំមុន ជាមួយនឹងទំហំប្រាក់មានចំនួនប្រមាណ ៣០៨ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤។

ដើម្បីធានាបាននិរន្តរភាព និងស្ថិរភាពនៃកិច្ចដំណើរការប្រព័ន្ធ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមបទដ្ឋានស្តង់ដារគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ការត្រួតពិនិត្យ

ប្រព័ន្ធទូទាត់ផ្តោតសំខាន់លើប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រតិបត្តិការប្រព័ន្ធទូទាត់ ដោយរួមមានទាំងការតាមដាននិន្នាការនៃប្រតិបត្តិការទូទាត់ និងការគ្រប់គ្រងហានិភ័យ ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទូទាត់ និងជាពិសេសហានិភ័យដួលរលំជាប្រព័ន្ធ។ ចំណែកឯ ការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

ដោយសារធនាគារជាតិនៃកម្ពុជាជាបញ្ញត្តិករគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាទើបថ្មីៗនេះ បទប្បញ្ញត្តិគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអនុម័តជាបន្តបន្ទាប់។ ក្នុងឆ្នាំ២០២៤ នេះ សេចក្តីណែនាំមួយចំនួនត្រូវបានដាក់ឱ្យប្រើដូចជា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា ការកែសម្រួលកាលបរិច្ឆេទ និងរយៈពេលបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងសេចក្តីណែនាំបន្ថែមស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បាន និងកំពុងរៀបចំប្រកាសបន្ថែមទៀត ដែលក្នុងនោះរួមមាន ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិក។ ចំណែកឯ សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលនីតិវិធីស្គាល់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់ ក៏នឹងត្រូវដាក់ឱ្យប្រើនៅដើមឆ្នាំ ២០២៥ ខាងមុខនេះផងដែរ។

ការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល ជាការងារអាទិភាពរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្តការងារអាទិភាពនេះ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។ នៅក្នុងឆ្នាំ២០២៤ នេះ ធនាគារជាតិនៃកម្ពុជាបានចុះផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគងដល់សាធារណជនទូទៅនៅតាមបណ្តាខេត្ត-ក្រុង រួមមាន ខេត្តកំពត ខេត្តកំពង់ធំ និងខេត្តកោះកុង ដែលមានអ្នកចូលរួមជាមន្ត្រីធនាគារជាតិនៃកម្ពុជា មន្ត្រីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើនរូប។

# ស្ថិតអំពីស្ថានភាពសេវាទូទាត់សងប្រាក់

## ១. ស្ថិតិទូទៅ

| | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ (៣) |
|---|---|---|
| ចំនួនប្រជាជនសរុប (ខ្ទង់លាន) [១] | ១៧,០៩ | ១៧,៦៤ |
| ផលិតផលក្នុងស្រុកសរុប (ខ្ទង់លានដុល្លារអាមេរិក) [២] | ៣២.០៦៥ | ៤២.៦៩៩ |
| ផលិតផលក្នុងស្រុកសរុប ក្នុងប្រជាជនម្នាក់ (ដុល្លារអាមេរិក) [២] | ១.៨៧៦ | ២.៤២១ |

## ២. គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ [២]

| ប្រភេទគ្រឹះស្ថាន | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | និន្នាការ |
|---|---|---|---|
| ធនាគារពាណិជ្ជ | ៥៨ | ៥៩ | ១,៧៩% |
| ធនាគារឯកទេស | ៩ | ៩ | - |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៤ | ៤ | - |
| គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ៣៣ | ២៩ | (១២,១២%) |
| អ្នកដំណើរតតិយភាគី | ៦ | ៦ | - |

## ៣. ឧបករណ៍ទូទាត់សងប្រាក់ [២] (ឯកតាខ្ទង់លាន)

| ប្រភេទឧបករណ៍ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | និន្នាការ |
|---|---|---|---|
| **៣.១ ប្រភេទឧបករណ៍រូបវន្ត** | | | |
| ប័ណ្ណ Proprietary | ៣,២១ | ៣,០ | (៧,៦%) |
| ប័ណ្ណ Debit | ២,៥១ | ២,៧៧ | ១០,៨% |
| ប័ណ្ណ Credit | ០,២១ | ០,២៤ | ១៥,៤% |
| ប័ណ្ណ Prepaid | ៧,១៣ | ៦,៦៩ | (៦,០%) |
| **៣.២ ប្រភេទឧបករណ៍បែបឌីជីថល** | | | |
| គណនីប្រាក់បញ្ញើអតិថិជន | ១៦,០២ | ២៣,៧៤ | ៤៨,២% |
| គណនីកាបូបអេឡិចត្រូនិក | ១៩,៦៦ | ២០,៤២ | ៣,៩% |
| គណនីបាគង | ០,៦០ | ០,៦៤ | ៦,៦% |

## ៤. បណ្តាញទូទាត់ [២] (ឯកតាខ្ទង់ពាន់)

| ចំនួនបណ្តាញទូទាត់ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | និន្នាការ |
|---|---|---|---|
| ម៉ាស៊ីន ATM | ៥,៤៤ | ៥,៧០ | ៥,០% |
| ម៉ាស៊ីន POS | ៥២,០៦ | ៥៣,៤៩ | ២,៧% |
| ភ្នាក់ងារផ្តល់សេវាទូទាត់ | ៦០,៤៨ | ៥៨,១០ | (៣,៩%) |

[១] ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ

[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥. ប្រតិបត្តិការទូទាត់សងប្រាក់ [២] (ឯកតាខ្ទង់លាន)

| | ឆ្នាំ២០២៣ | | ឆ្នាំ២០២៤ | | និន្នាការ | |
|---|---|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| **៥.១ មូលប្បទានបត្រ** | | | | | | |
| ចំនួនប្រតិ. | ០,០៣៤ | ១,០៤ | ០,០៣២ | ១,០១ | (៤,១១%) | (២,៥៨%) |
| ទំហំប្រាក់ | ២២.០០២.៧៥០ | ៤៤.៤៣៣ | ២១.៦៤៩.៥៦០ | ៥៧.៥៩៣ | (១,៦០%) | ២៩,៦១% |
| **៥.២ បញ្ជាទូទាត់អេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិ. | ០,០២៨ | ០,៦៣ | ០,០៣៧ | ០,៦១ | ៣៣,៥៥% | (៣,៣៣%) |
| ទំហំប្រាក់ | ៤.៨៧៦.៩៤០ | ១៣.១១៨ | ៥.២៣៦.៨៧០ | ១៥.៣៩៣ | ៧,៣៨% | ១៧,៣៤% |
| **៥.៣ ប័ណ្ណទូទាត់ [៣]** | | | | | | |
| ចំនួនប្រតិ. | - | ១៨១,៣៩ | - | ១៦៩,៧៧ | - | (៦,៤១%) |
| ទំហំប្រាក់ | ៥៥.១៤២.៩៨៨ | ១៨.០១០ | ៤៩.៥៦២.០៣៩ | ១៤.៧៣៨ | (១០,១២%) | (១៨,១៧%) |
| **៥.៤ កាបូបអេឡិចត្រូនិក** | | | | | | |
| ចំនួនប្រតិ. | ២២៧,៧៥ | ៣៧៣,៥៤ | ៤៧៥,៧៨ | ៥៨៦,៩១ | ១០៨,៩១% | ៥៧,១២% |
| ទំហំប្រាក់ | ១២៧.៣៨៧.៨៦៥ | ៤៣.៩៩៥ | ១៨២.២៩៤.៥៣៧ | ៥៨.៥៨១ | ៤៣,១០% | ៣៣,១៥% |
| **៥.៥ សេវាធនាគារចល័ត** | | | | | | |
| ចំនួនប្រតិ. | ៨៦,៧៩ | ៦៩២,៦៦ | ១៩១,៣៩ | ៨៦៩,៤៤ | ១២០,៥១% | ២៥,៥២% |
| ទំហំប្រាក់ | ៧៣.១១៤.២៣៤ | ១៦៣.៨៧៨ | ៨៩.៨៥៧.៤៣០ | ១៧០.៧៥១ | ២២,៩០% | ៤,១៩% |
| **៥.៦ សេវាធនាគារអ៊ីនធឺណិត** | | | | | | |
| ចំនួនប្រតិ. | ០,២១ | ៤,៤៩ | ០,៩៧ | ៨,៦០ | ៣៥៧,៨៥% | ៩១,៥២% |
| ទំហំប្រាក់ | ៩.២០៦.៧៦២ | ១៥.៨១៦ | ១០.៩៣៨.៦៦១ | ២១.៦៩៥ | ១៨,៨១% | ៣៦,៥៧% |
| **៥.៧ ប្រព័ន្ធបាគង** | | | | | | |
| ចំនួនប្រតិ. | ៦៨,៧៩ | ១៣២,១៤ | ២៩៩,០៧ | ៣០៧,៩៩ | ៣៣៤% | ១៣២% |
| ទំហំប្រាក់ | ៨១.០៥០.០០០ | ៥៣.៧៦០ | ១៧៩.៣០៨.០០០ | ១០២.៣២០ | ១២១% | ៩០% |

[២] ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៣] ប្រតិបត្តិការប័ណ្ណទូទាត់ រួមបញ្ចូលប្រតិបត្តិការជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកជាមួយគ្នា

# ១ វឌ្ឍនភាពរបស់ប្រព័ន្ធទូទាត់សងប្រាក់

នាយុគសម័យបច្ចេកវិទ្យាបាននិងកំពុងវិវត្តន៍យ៉ាងឆាប់រហ័ស ប្រទេសកម្ពុជាបានខិតខំអភិវឌ្ឍសេដ្ឋកិច្ចឱ្យប្រែក្លាយទៅជាសេដ្ឋកិច្ចឌីជីថលតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធជាតិដែលមានប្រសិទ្ធភាព និងសុវត្ថិភាព។ ដើម្បីឆ្លើយតបទៅនឹងវឌ្ឍនភាពនេះ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ក្នុងគោលបំណងគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ដើម្បីឱ្យស្របទៅនឹងការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់តាមដំណាក់កាលរួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធបាគង (BAKONG) ប្រព័ន្ធខេមបូឌានស្វ៊ែស៊្វីច (CSS) និងប្រព័ន្ធរីថែលផេ (Retail Pay) ដើម្បីសម្រួលការទូទាត់អន្តរធនាគារប្រកបដោយប្រសិទ្ធភាពខ្ពស់។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម ដើម្បីសម្រួលដល់ការប្រើប្រាស់របស់សាធារណជនក្នុងការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថាន។

## ១.១. ការអភិវឌ្ឍចម្បងៗ

ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាប្រព័ន្ធផាត់ទាត់ជាតិជំនាន់ថ្មី ២.០ ក្នុងឆ្នាំ២០២២ ដោយភ្ជាប់នូវមុខងារថ្មីចំនួនពីរ រួមមានយន្តការ Failure Tolerance Mechanism និងមុខងារ Straight Through Processing (STP) ដើម្បីពង្រឹងសុវត្ថិភាពប្រព័ន្ធ និងសមត្ថភាពផាត់ទាត់ដែលនឹងផ្តល់ភាពងាយស្រួលជាងមុនដល់សមាជិកប្រព័ន្ធក្នុងការធ្វើប្រតិបត្តិការ។ ទន្ទឹមនោះ ទំហំនៃការទូទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិកតាមរយៈប្រព័ន្ធផាត់ទាត់ជាតិនៅក្នុងឆ្នាំ២០២៤នេះមានការថយចុះ រីឯទំហំនៃការទូទាត់មូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិកជាប្រាក់រៀលនិងដុល្លារអាមេរិកមានការកើនឡើង បើធៀបនឹងឆ្នាំ២០២៣។ លើសពីនេះ ប្រព័ន្ធបាគងបានបន្តពង្រីកសេវានិងមុខងារថ្មីៗដើម្បីបំពេញតម្រូវការដល់អ្នកប្រើប្រាស់ដូចជា ការប្តូរប្រាក់ក្នុងគណនីបាគងរវាងប្រាក់រៀល ប្រាក់ដុល្លារអាមេរិក ការពិនិត្យមើលព័ត៌មានការចាក់វ៉ាក់សាំងកូវីដ-១៩ និងមុខងារប្រព័ន្ធធនាគារចំហ។ គួរឱ្យកត់សម្គាល់ផងដែរ ប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងមានសន្ទុះកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ ជាពិសេសប្រតិបត្តិការជាប្រាក់រៀល។ ដោយឡែក ប្រតិបត្តិការតាមរយៈប្រព័ន្ធខេមបូឌានស្វ៊ែស៊្វីចដែលជាហេដ្ឋារចនាសម្ព័ន្ធប័ណ្ណទូទាត់ថ្នាក់ជាតិសម្រាប់ធ្វើអន្តរប្រតិបត្តិការប័ណ្ណទូទាត់រវាងគ្រឹះស្ថានជាសមាជិកមានការថយចុះគួរឱ្យកត់សម្គាល់ ទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ជារៀល និងដុល្លារអាមេរិក។

បរិវត្តកម្មឌីជីថលនិងនវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុបាននិងកំពុងវិវត្តន៍យ៉ាងឆាប់រហ័ស ប្រៀបបានជាកាតាលីករក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការអភិវឌ្ឍលើគ្រប់វិស័យឱ្យកាន់តែប្រសើរឡើងទូទាំងសកលលោក។ ទន្ទឹមនេះ នវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់ និងវត្តមាននៃបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដូចជារូបិយវត្ថុអេឡិចត្រូនិក និងសេវាទូទាត់សងប្រាក់ឌីជីថល បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការវិនិយោគលើសេវាធនាគារឌីជីថល ដើម្បីឱ្យដំណើរការទូទាត់កាន់តែពិលាស។ ការណ៍នេះ បានផ្លាស់ប្ដូរឥរិយាបថរបស់ប្រជាជនកម្ពុជា ឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យក្រដាសប្រាក់ និងជាផ្នែកមួយដ៏សំខាន់ជួយគាំទ្រដល់សកម្មភាពធុរកិច្ច និងសេដ្ឋកិច្ចកម្ពុជាបានប្រសើរមួយកម្រិតទៀត។

**ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរ និងទំហំប្រាក់ទូទាត់តាមប្រព័ន្ធឌីជីថលជាប្រាក់រៀល**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ភាពជឿនលឿននៃបច្ចេកវិទ្យាហិរញ្ញវត្ថុបានជំរុញឱ្យមានការប្រកួតប្រជែងរវាងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ក្នុងការដាក់ឱ្យប្រើប្រាស់សេវាទូទាត់ឌីជីថល និងពង្រីកសេវាហិរញ្ញវត្ថុរបស់ខ្លួនដើម្បីទាក់ទាញអតិថិជន ជាពិសេសតាមរយៈការដាក់ឱ្យប្រើប្រាស់សេវា និងឧបករណ៍ទូទាត់ថ្មីៗ ប្រកបដោយនវានុវត្តន៍ រួមមាន សេវាធនាគារតាមអ៊ីនធឺណិត សេវាធនាគារចល័ត សេវាទូទាត់ចល័ត ប័ណ្ណទូទាត់ និងការទូទាត់តាមយូអរកូដ (QR Code)។ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការគំរូបរិច្ឆិនភាពខេអេចយូអរកូដ (KHQR Code) នៅឆ្នាំ២០២២ ដើម្បីលើកកម្ពស់ប្រតិបត្តិការទូទាត់រាយ និងរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ តាមរយៈការដាក់ឱ្យប្រើប្រាស់ KHQR Code ស្តង់ដារតែមួយ អ្នកប្រើប្រាស់អាចធ្វើការទូទាត់ និងទទួលប្រាក់ពីគ្រប់កម្មវិធីធនាគារចល័តរបស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធបាគង។ ការណ៍នេះ ក៏ជាចំណុចគន្លឹះ ក្នុងការធ្វើប្រតិបត្តិការឆ្លងដែនតាមរយៈមជ្ឈមណ្ឌលទូទាត់ និងបណ្ដាញទូទាត់ផ្សេងៗនៅក្នុងតំបន់ផងដែរ។ គិតរហូតមកដល់បច្ចុប្បន្ន ធនាគារ

ជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមឃ្យូអរកូដរវាងប្រទេសកម្ពុជា និងប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ និងក្រុមហ៊ុនអាលីផេ និងកំពុងបន្តអភិវឌ្ឍការតភ្ជាប់ប្រព័ន្ធជាមួយប្រទេសផ្សេងៗទៀត។

**ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

នៅក្នុងឆ្នាំ២០២៤ ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ មានការធ្លាក់ចុះ រីឯប្រតិបត្តិការទូទាត់តាមការស្កេន QR Code បន្តកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់ ទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់។ ចំនួនប្រតិបត្តិការតាមប័ណ្ណទូទាត់ មានការកើនឡើងត្រឹម ១,៥% ប៉ុន្តែទំហំប្រាក់ មានការធ្លាក់ចុះរហូតដល់ ៧,៧%។ រីឯចំនួនប្រតិបត្តិការទូទាត់តាម QR Code មានការកើនឡើងរហូតដល់ ២៤៧,៥% និងទំហំប្រាក់ មានការកើនឡើងរហូតដល់ ១៣៥,៤%។

## ១.២. គោលនយោបាយគាំទ្រ

នាយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០ បច្ចេកវិទ្យាឌីជីថលបានបោះជំហានយ៉ាងលឿន និងបានក្លាយជាកត្តាគន្លឹះជំរុញការគ្របដណ្តប់ និងការតភ្ជាប់សេដ្ឋកិច្ចនៅទូទាំងសកលលោក កាន់តែស្អិតរមួត ខិតជិតគ្នានិងអាស្រ័យគ្នាទៅវិញទៅមក។ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សកម្មភាពពាណិជ្ជកម្ម បរិយាបន្នហិរញ្ញវត្ថុ និងឈាន

ឆ្ពោះទៅរកសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាបន្តបន្ទាប់។ កន្លងមកធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់ជាច្រើន ហើយថ្មីៗនេះធនាគារជាតិនៃកម្ពុជាបានរៀបចំអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដែលធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗជាប្រព័ន្ធទូទាត់រួមតែមួយ ដើម្បីសម្រួលដល់អតិថិជន និងគ្រឹះស្ថានជាសមាជិកក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់អន្តរគ្រឹះស្ថានទាំងតម្លៃរាយ និងតម្លៃធំ។ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ និងមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន៥២ បានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធនេះ។ ក្នុងគោលបំណងគាំទ្រប្រព័ន្ធទូទាត់សងប្រាក់រួមនេះឱ្យមានសុវត្ថិភាព រឹងមាំលក្ខណៈផ្លូវច្បាប់ និងទទួលបានទំនុកចិត្តពីសាធារណជន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំវិធាននិងនីតិវិធី សម្រាប់គ្រប់គ្រង និងទុកជាឯកសារចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិកអនុវត្ត។

ប័ណ្ណទូទាត់នៅតែជាមធ្យោបាយទូទាត់ដំពេញនិយមសម្រាប់អតិថិជនដើម្បីធ្វើការទូទាត់ទំនិញ និងសេវា ព្រមទាំងប្រតិបត្តិការដាក់/ដកប្រាក់តាមម៉ាស៊ីនដាក់/ដកប្រាក់ស្វ័យប្រវត្តិ (ATM)។ ក្នុងគោលបំណង ជួយសម្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការតាមរយៈប័ណ្ណទូទាត់ឥណពន្ធឆ្លងគ្រឹះស្ថាន នៅប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធ CSS ដែលអនុញ្ញាតឱ្យអតិថិជនរបស់គ្រឹះស្ថានធនាគារជាសមាជិកអាចប្រើប្រាស់ប័ណ្ណទូទាត់លើគ្រប់ម៉ាស៊ីន ATM និងម៉ាស៊ីន POS របស់គ្រឹះស្ថានសមាជិកនៅក្នុងស្រុក។ ការដាក់ឱ្យដំណើរការប្រព័ន្ធនេះ បានផ្តល់នូវផលវិជ្ជមានជាច្រើនក្នុងការធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុឌីជីថល បង្កើនប្រសិទ្ធភាពក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយភាពងាយស្រួល និងសុវត្ថិភាព ជាពិសេសបានចូលរួមចំណែកក្នុងការសម្រេចបានសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន និងស្ថិរភាព។ ដើម្បីឆ្លើយតបនឹងស្តង់ដារសុវត្ថិភាពនៃប្រព័ន្ធ និងនិរន្តភាពនៃប្រតិបត្តិការប័ណ្ណទូទាត់ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងស្តីពីការផ្អាកដំណើរការលេខអត្តសញ្ញាណធនាគារ មិនមែនស្តង់ដារសម្រាប់ប័ណ្ណឥណពន្ធក្នុងស្រុក និងប័ណ្ណទូទាត់ឥណពន្ធ Magnetic Stripe របស់ប្រព័ន្ធ CSS ដោយប័ណ្ណទូទាត់របស់គ្រឹះស្ថានសមាជិកដែលមិនអនុវត្តស្តង់ដារ BIN (៩១១៦) ស្របតាមវិធាននិងនីតិវិធីប្រព័ន្ធ CSS និងប័ណ្ណទូទាត់ឥណពន្ធ Magnetic Stripe នឹងមិនអាចដំណើរការតាមប្រព័ន្ធ CSS ចាប់ពីដំណាច់ខែកញ្ញា ឆ្នាំ២០២៤ និងកំណត់ទំហំប្រាក់ដូចគ្នាក្នុងប្រតិបត្តិការ និងកម្រៃសេវាថេរនៅលើម៉ាស៊ីន ATM សម្រាប់ប្រតិបត្តិការដកសាច់ប្រាក់ដែលប្រើប្រាស់ប័ណ្ណឥណពន្ធ។ការចេញសេចក្តីជូនដំណឹងនេះ បានឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការពារអតិថិជនពីហានិភ័យដែលអាចកើតមានឡើងពីការលួចបន្លំផ្សេងៗនៅពេលធ្វើប្រតិបត្តិការតាមរយៈប័ណ្ណទូទាត់ឥណពន្ធ Magnetic Stripe ដែលមិនសូវមានសុវត្ថិភាព។ លើសពីនេះ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យានិងលើកកម្ពស់ភាពងាយស្រួលក្នុងការ

ប្រើប្រាស់ប័ណ្ណទូទាត់ ធនាគារជាតិនៃកម្ពុជាក៏បានបន្តអភិវឌ្ឍមុខងារ Contactless ដោយបច្ចុប្បន្ន មានគ្រឹះស្ថានធនាគារចំនួន ៦ កំពុងធ្វើសន្ទានកម្ម។

ទន្ទឹមគ្នានេះដែរ ប្រព័ន្ធបាគងដែលមានភាពពេញនិយមក្នុងស្រទាប់យុវវ័យ ត្រូវបានបន្តធ្វើទំនើបកម្ម ដោយបានបន្ថែមនិងពង្រីកមុខងារ និងសេវាកាន់តែទូលំទូលាយដល់អ្នកប្រើប្រាស់ ដោយបានដាក់ឱ្យដំណើរការបឋមកម្មវិធីទូទាត់បាគងទេសចរ (Bakong Tourists App) កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤។ ប្រព័ន្ធបាគងត្រូវបានប្រើប្រាស់ជាហេដ្ឋារចនាសម្ព័ន្ធទូទាត់សម្រាប់ការទូទាត់ឆ្លងដែន និងបានដាក់ឱ្យដំណើរការជាផ្លូវការជាមួយប្រទេសក្នុងតំបន់ រួមមាន ប្រទេសថៃ ម៉ាឡេស៊ី ឡាវ វៀតណាម កូរ៉េខាងត្បូង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ ក្រុមហ៊ុនអាលីផេ និងកំពុងបន្តអភិវឌ្ឍគម្រោងទូទាត់ឆ្លងដែនជាមួយបណ្ដាប្រទេស ផ្សេងទៀតដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា និងសិង្ហបុរី។ ក្រោមការអភិវឌ្ឍប្រព័ន្ធបាគង រួមមាន បាគងតម្លៃធំ និងបាគងតម្លៃរាយក៏ត្រូវបានបែងចែក ដើម្បីជំរុញភាពច្បាស់លាស់ក្នុងការប្រើប្រាស់សេវាទូទាត់សងប្រាក់។ ការអភិវឌ្ឍប្រព័ន្ធនេះនឹងផ្ដល់ជាមធ្យោបាយសម្រួលការទូទាត់ឆ្លងដែនដល់អ្នកប្រើប្រាស់ដូចជា ភ្ញៀវទេសចរ ពលករ និងអ្នកធុរកិច្ច។

ទន្ទឹមនឹងវឌ្ឍនភាពនៃប្រព័ន្ធទូទាត់សងប្រាក់ ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់ក៏ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់តាមរយៈការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីរក្សាសុវត្ថិភាពនិងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល។ ជាក់ស្ដែង ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្ដីណែនាំ ព្រមទាំងវិធាននិងនីតិវិធីសម្រាប់ជាចំណងផ្លូវច្បាប់គ្រប់គ្រងលើការអនុវត្ត និងប្រតិបត្តិការរបស់ប្រព័ន្ធនីមួយៗ និងបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលជាឯកសារមូលដ្ឋានបង្ហាញពីគោលដៅនៃគោលនយោបាយត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដែលអនុវត្តដោយធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជា អនុវត្តគោលការណ៍ណែនាំសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃពីកម្រិតហានិភ័យចម្បងៗក្នុងប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ទោះជាយ៉ាងណាយន្តការទាំងនោះនៅមិនទាន់គ្រប់គ្រាន់សម្រាប់គ្រប់គ្រងហានិភ័យប្រតិបត្តិការតាមទម្រង់ផ្សេងៗ ដែលអាចកើតមានឡើង ស្របតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ឡើយ។ ក្នុងនាមជាអាជ្ញាធរគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានគិតពីផលប៉ះពាល់នៃភាពអាក់អួលនៃប្រព័ន្ធទូទាត់សងប្រាក់ដល់ស្ថិរភាពហិរញ្ញវត្ថុ ដែលនាំទៅដល់វិបត្តិហិរញ្ញវត្ថុជាយថាហេតុ។ កំណើននៃការប្រើប្រាស់ឧបករណ៍ និងសេវាទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជា មានការកើនឡើងជាលំដាប់នាពេលបច្ចុប្បន្ននេះ ដោយសារតែការវិវត្តន៍នៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការផ្ដល់សេវានិងឧបករណ៍ទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញបទប្បញ្ញត្តិលើវិស័យធនាគារនិងហិរញ្ញវត្ថុ តាមរយៈការរៀបចំ និងដាក់ចេញក្របខណ្ឌបទប្បញ្ញត្តិរឹងមាំ និងប្រកបដោយប្រសិទ្ធភាព។ ជាក់ស្ដែងនៅក្នុងឆ្នាំ២០២៤ សេចក្ដីណែនាំ

ស្តីពី "ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា" ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីឱ្យការអនុវត្តមានលក្ខណៈស្តង់ដារ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំបទប្បញ្ញត្តិបន្ថែមទៀត ដែលក្នុងនោះរួមមាន ប្រកាសស្តីពី ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រតិបត្តិការទីផ្សារឥណទានតាមប្រព័ន្ធអេឡិចត្រូនិក និងសេចក្តីជូនដំណឹងមួយចំនួនទៀត ដើម្បីគាំទ្រប្រតិបត្តិការ ការទូទាត់ជាឌីជីថលឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញគោលការណ៍គ្រប់គ្រងហានិភ័យព័ត៌មានវិទ្យាសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីអនុវត្តក្នុងគោលបំណងពង្រឹងប្រព័ន្ធសុវត្ថិភាពផ្ទៃក្នុង ក្នុងការផ្តល់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព។

បន្ទាប់ពីបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ និងក្របខណ្ឌបទប្បញ្ញត្តិរួចមក ចំណេះដឹងហិរញ្ញវត្ថុឌីជីថលក៏ជាកត្តាសំខាន់សម្រាប់ការអប់រំក្នុងយុគសម័យឌីជីថល។ ការលើកកម្ពស់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដែលមានភាពល្អប្រសើរតាមរយៈ បច្ចេកវិទ្យាហិរញ្ញវត្ថុទាមទារនូវការយល់ដឹងអំពីហិរញ្ញវត្ថុឌីជីថល ដើម្បីឱ្យសាធារណជនប្រើប្រាស់សេវាទាំងនោះបានប្រកបដោយប្រសិទ្ធភាព និងជៀសវាងពីការឆបោក ការក្លែងបន្លំ ការប្រើប្រាស់ទិន្នន័យដោយគ្មានការអនុញ្ញាត និងការទទួលបានសេវាដោយមិនស្មើភាពគ្នាជាដើម។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានចុះផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ប្រព័ន្ធបាគងដល់សាធារណជនទូទៅនៅតាមបណ្តាខេត្ត-ក្រុងដោយបង្កើតជាវីឌីអូអប់រំខ្លីៗ ផ្សព្វផ្សាយតាមកម្មវិធីនានាជាច្រើនរូបភាព ដើម្បីបញ្ជ្រាបចំណេះដឹងហិរញ្ញវត្ថុឌីជីថលដល់អ្នកប្រើប្រាស់។

## ១.៣. ជំហានបន្ទាប់

ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយដូចបានរៀបរាប់ខាងលើ ការផ្តល់ការគាំទ្រមតិណែនាំ និងកិច្ចសហការយ៉ាងជិតស្និតជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកប្រព័ន្ធ និងភាគីពាក់ព័ន្ធទាំងអស់ជាកត្តាចាំបាច់ ក្នុងការជំរុញឱ្យគ្រឹះស្ថានជាសមាជិកមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ស្របតាមវឌ្ឍនភាពប្រព័ន្ធទូទាត់សងប្រាក់ជំនាន់ថ្មីរបស់ធនាគារជាតិនៃកម្ពុជាតាមដំណាក់កាលនីមួយៗបានដោយជោគជ័យ។

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុលោមតាមគោលនយោបាយរបស់ប្រព័ន្ធ CSS ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានវឌ្ឍនភាព និងសហការជាមួយគ្រឹះស្ថានសមាជិក ដើម្បីអាចឱ្យការអនុវត្តគោលនយោបាយ ដែលមានចែងក្នុងសេចក្តីជូនដំណឹងសម្រេចបានតាមពេលវេលាកំណត់។

ធនាគារជាតិនៃកម្ពុជានឹងបន្តជំរុញ និងលើកកម្ពស់ការទូទាត់តាមប្រព័ន្ធបាគង និងការអនុវត្តស្តង់ដារ KHQR Code ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីសម្រេចបានក្នុងការត្រៀមខ្លួនសម្រាប់ការធ្វើអន្តរប្រតិបត្តិការទូទាត់តាមរយៈឃ្យូអរកូតទាំងក្នុងប្រទេស និងតំបន់។

ធនាគារជាតិនៃកម្ពុជាបានបន្តគាំទ្រការធ្វើសន្ទានកម្មរបស់គ្រឹះស្ថានជាសមាជិករបស់ប្រព័ន្ធទូទាត់សងប្រាក់រួម ដើម្បីធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ចម្បងៗជាប្រព័ន្ធទូទាត់រួមតែមួយសម្រាប់សម្រួលដល់ប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ទាំងតម្លៃរាយ និងតម្លៃធំ។ ឯកសារវិធាននិងនីតិវិធីសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម កំពុងត្រូវបានរៀបចំ និងត្រៀមពិភាក្សាជាមួយបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មុននឹងដាក់ឱ្យដំណើរការប្រព័ន្ធនេះជាផ្លូវការ។

បន្ថែមលើការអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ការថែរក្សាប្រព័ន្ធទូទាត់សងប្រាក់ឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ជាកត្តាចាំបាច់ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នបំផុត។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងឯកសារការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធបាគងដោយផ្អែកលើគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។ លើសពីនោះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងរៀបចំសេចក្តីព្រាង ផែនការនិរន្តភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ក្នុងគោលបំណងអាចបន្តដំណើរការរបស់ប្រព័ន្ធទូទាត់នៅពេលមានឧបទ្ទវហេតុណាមួយកើតឡើង ហើយដោះស្រាយបញ្ហាបានទាន់ពេលវេលា។

ជាមួយនឹងការវិវត្តន៍ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ សេវាទូទាត់សងប្រាក់ និងសេវាផ្ទេរប្រាក់បានអភិវឌ្ឍយ៉ាងឆាប់រហ័ស ដែលការណ៍នេះបានផ្តល់ឱកាសឱ្យធនាគារជាតិនៃកម្ពុជាដែលជានិយ័តករ បន្តសិក្សា និងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសមស្របថ្មីៗ ក្នុងគោលបំណងឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ។

បន្ថែមពីនេះ ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ការបង្កើនការយល់ដឹងដល់សាធារណជនអំពីរបៀបប្រើប្រាស់ឱ្យបានទូលំទូលាយ ជាកត្តាចាំបាច់ និងទាមទារឱ្យមានការរៀបចំជាក្របខណ្ឌ និងផែនការសកម្មភាពផ្សេងៗក្រោមកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថលទទួលបានប្រសិទ្ធភាពខ្ពស់។

# ២ នវានុវត្តន៍ប្រព័ន្ធបាគង

ក្នុងគោលបំណងពង្រឹង លើកកម្ពស់ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគងដែលជាប្រព័ន្ធកន្លោង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០។ ប្រព័ន្ធបាគងបាន ១/. ឆ្លុះបញ្ចាំងអំពីបរិវត្តកម្មឌីជីថលដែលប្រកបដោយនវានុវត្តន៍នៅក្នុងប្រព័ន្ធទូទាត់សងប្រាក់ ២/. ជួយសម្រួលអន្តរប្រតិបត្តិការធនាគារឱ្យកាន់តែមានប្រសិទ្ធភាព ៣/. លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និង ៤/. លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ប្រព័ន្ធបាគងត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិថាជាប្រព័ន្ធទូទាត់ក្នុងយុគសម័យថ្មី ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) និងបច្ចេកវិទ្យាឌីអិលធី (DLT) ប្រកបដោយនវានុវត្តន៍។ ជាសក្ខីភាព ប្រព័ន្ធបាគងបានទទួលពានរង្វាន់ពីសារព័ត៌មាន NIKKEI ដែលជាសារព័ត៌មានល្បីជួរមុខរបស់ប្រទេសជប៉ុន ក្នុងការសម្រេចបានគោលដៅបរិយាបន្នហិរញ្ញវត្ថុ និងនវានុវត្តន៍។ ប្រព័ន្ធបាគងក៏បានដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ សម្រាប់ប្រជាជនកម្ពុជា តាមរយៈការជំរុញប្រតិបត្តិការទូទាត់សងប្រាក់ឌីជីថលសម្រាប់ប្រជាជនដែលពុំមានលទ្ធភាពក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។ ធនាគារជាតិនៃកម្ពុជា កំពុងបន្តអភិវឌ្ឍប្រព័ន្ធបាគងជាប្រចាំ ក្នុងគោលបំណងពង្រីកមុខងារផ្សេងៗទៀត ជាពិសេសនៅក្នុងការទូទាត់ឆ្លងដែន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

## ២.១. វឌ្ឍនភាពប្រព័ន្ធបាគង

គិតត្រឹមដំណាច់ឆ្នាំ២០២៤ ប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៦៩ គ្រឹះស្ថាន ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ៦០ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ៩ ផ្សេងទៀតបាននិងកំពុងបន្តធ្វើសន្ទានកម្មប្រព័ន្ធ។

**សមាជិកប្រព័ន្ធបាគងទាំង ៦០ គ្រឹះស្ថាន**

ក្នុងឆ្នាំ២០២៤ នេះ អតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគងតាមរយៈកម្មវិធីបាគងមានចំនួន ៦៥២,៥ ពាន់គណនី កើនឡើង ៧% បើធៀបនឹងឆ្នាំ២០២៣។ ទន្ទឹមនេះ ចំនួនអតិថិជនដែលមានគណនីធនាគារ/កាបូបអេឡិចត្រូនិកនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ហើយអាចធ្វើប្រតិបត្តិការតាមប្រព័ន្ធបាគង (Customer Reached) មានចំនួនប្រមាណ ៣០ លានគណនី ដែលប៉ាន់ប្រមាណស្មើនឹង ១៦៩% នៃចំនួនប្រជាជនសរុប។ លើសពីនេះ ប្រព័ន្ធបាគងក៏មានមុខងារទូទាត់តាមរយៈ KHQR Code ដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់នៅកម្ពុជាផងដែរ។ គិតត្រឹមដំណាច់ឆ្នាំ២០២៤នេះ ពាណិជ្ជករដែលចុះឈ្មោះប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ ដើម្បីទទួលការទូទាត់តាមខេអេចឃ្យូអរកូត មានប្រមាណ ៤,៥ លានគណនី (កើនឡើង ៣៦,៣៦% ធៀបឆ្នាំ២០២៣)។

**ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់កម្មវិធីបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

រីឯប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគងមានចំនួន ៦០៨,៣២ លានប្រតិបត្តិការ ក្នុងនោះប្រតិបត្តិការជាប្រាក់រៀលមានចំនួន ២៩៩,៣២ លានប្រតិបត្តិការ (កើនឡើង ៣៣៥%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣០៨,២០ លានប្រតិបត្តិការ (កើនឡើង ១៣២%) និងមានទំហំប្រាក់ជាប្រាក់រៀលប្រមាណ ១៧៩,៣០ ទ្រីលានរៀល (កើនឡើង ១២១%) និងទំហំប្រាក់ជាប្រាក់ដុល្លារអាមេរិកប្រមាណ ១០២,៣២ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៩០%) ដែលទំហំប្រាក់សរុបនៅក្នុងឆ្នាំ២០២៤ ស្មើនឹង ៣២៧% នៃផ.ស.ស។ ការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រព័ន្ធបាគង មានការកើនឡើងជាលំដាប់ បន្ទាប់ពីប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការ ដូចបានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

### ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់ និងបន្ទាប់ពីបានដាក់ដំណើរការជាផ្លូវការប្រព័ន្ធបាគង




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.២. នវានុវត្តន៍ប្រព័ន្ធបាគង

### ក. ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិក (e-KYC) តាមប្រព័ន្ធបាគង

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ វិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេសការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់បានជំរុញឱ្យប្រទេសកម្ពុជាចាប់ផ្ដើមផ្លាស់ប្ដូរពីសង្គមដែលពឹងផ្អែកលើសាច់ប្រាក់ ទៅជាសង្គមដែលពេញនិយមប្រើប្រាស់ការទូទាត់សងប្រាក់ឌីជីថល។ ទោះជាយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការប្រើប្រាស់ការទូទាត់សងប្រាក់ឌីជីថល ដូចជា ការក្លែងបន្លំ ឆបោកតាមប្រព័ន្ធអ៊ីនធឺណែត និងការប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាផ្សេងៗ ដែលបញ្ហាទាំងអស់នេះកើតចេញមកពីការមិនបានផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឱ្យបានត្រឹមត្រូវ។ កន្លងមក ការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជននៅក្នុងវិស័យធនាគារភាគច្រើនធ្វើឡើងដោយដៃ និងតម្រូវឱ្យមានឯកសារភ្ជាប់សម្រាប់ផ្ទៀងផ្ទាត់ផ្ទាល់ ការណ៍នេះតម្រូវឱ្យអតិថិជនត្រូវមកផ្ទៀងផ្ទាត់នៅតាមបណ្ដាសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមិនត្រឹមតែប្រើប្រាស់ពេលវេលាច្រើនប៉ុណ្ណោះទេ ថែមទាំងងាយនឹងមានកំហុស ព្រមទាំងអាចប្រឈមនឹងហានិភ័យផងដែរ។ ក្នុងគោលបំណងដោះស្រាយបញ្ហានេះ ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" បានសហការគ្នា ដើម្បីកំណត់ក្របខណ្ឌសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល និងផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណកម្មពីក្រសួងមហាផ្ទៃ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិក (e-KYC) តាមប្រព័ន្ធបាគង ដើម្បីសម្រួលដល់ដំណើរការនិងបង្កើនប្រសិទ្ធភាពនៃការចុះឈ្មោះអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាផ្ដល់នូវភាពងាយស្រួលជាងមុនក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អតិថិជនផងដែរ។

### ខ. ការអភិវឌ្ឍមុខងារតភ្ជាប់គណនី (Linking Account)

ការតភ្ជាប់គណនីជាមួយកម្មវិធីទូទាត់បាគង គឺជាមធ្យោបាយដាក់ប្រាក់បន្ថែមមួយទៀត ដែលអាចធ្វើឡើងតាមរយៈកម្មវិធីទូទាត់បាគងដោយតភ្ជាប់គណនីដែលអតិថិជនមានជាមួយនឹងគ្រឹះស្ថានធនាគារដោយផ្ទាល់។ មុខងារថ្មីនេះនឹងជួយសម្រួលដល់ដំណើរការដាក់ប្រាក់រហ័សប្រកបដោយប្រសិទ្ធភាព និងគ្រប់ពេលវេលា ព្រមទាំងធានាបាននូវសុវត្ថិភាព និងភាពងាយស្រួលដល់អតិថិជន។ គិតត្រឹមដំណាច់ឆ្នាំ២០២៤មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិកចំនួន ២៣ បានបញ្ចប់សន្ទានកម្មរួចរាល់ និង ៣៣ គ្រឹះស្ថានទៀតកំពុងធ្វើសន្ទានកម្ម។

### គ. ការអភិវឌ្ឍមុខងារខេអេចឃ្យូអរកូតរូបិយប័ណ្ណតែមួយ

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវសេចក្ដីណែនាំស្ដីអំពី "ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា" ដែលតម្រូវឱ្យរាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្ដល់សេវាទូទាត់

សងប្រាក់ទាំងអស់ បើកគណនីប្រាក់បញ្ញើ និង/ឬ គណនីទូទាត់សងប្រាក់ជាប្រាក់រៀល ដែលប្រើប្រាស់សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ជូនគ្រប់អតិថិជនទាំងអស់។ ចំពោះអតិថិជនដែលមានគណនីទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចបង្កើតជា KHQR Code រួមមួយសម្រាប់ឱ្យអតិថិជនទទួលការទូទាត់ ដែលការណ៍នេះ នឹងជួយសម្រួលដល់ការធ្វើប្រតិបត្តិការឱ្យកាន់តែមានភាពងាយស្រួល ព្រមទាំងកាត់បន្ថយការចំណាយ ជាពិសេសសម្រាប់ពាណិជ្ជករ។

### ឃ. នីតិវិធីដោះស្រាយបណ្តឹងអតិថិជនប្រព័ន្ធបាគង

ជាមួយការវិវត្តន៍ និងការតភ្ជាប់ប្រព័ន្ធទូទាត់កាន់តែស្មុគស្មាញ ជម្លោះអាចកើតឡើងជាញឹកញាប់ ដូចជា កំហុសប្រតិបត្តិការ ការក្លែងបន្លំ ឬ កំហុសបច្ចេកទេស ចំពោះអតិថិជនដែលធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ដូចនេះ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើម រៀបចំនិងចងក្រងនីតិវិធីដោះស្រាយបណ្តឹងអតិថិជនសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម ដែលជាក្របខណ្ឌគតិយុត្តសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តក្នុងការដោះស្រាយជម្លោះ ឬវិវាទ ដើម្បីកសាងទំនុកចិត្តអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងធានាបាននូវដំណើរការដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ បច្ចុប្បន្ននេះ សមាគមធនាគារនៅកម្ពុជា បាននិងកំពុងប្រឹក្សាយោបល់បន្ថែមផ្នែកគតិយុត្តលើសេចក្តីព្រាងនីតិវិធីដោះស្រាយបណ្តឹងអតិថិជននេះ។

### ង. មុខងារតំណភ្ជាប់បាគងសម្រាប់ការទូទាត់ឆ្លងដែន (Cross-border Bakong API)

ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមអភិវឌ្ឍគម្រោងទូទាត់ និងផ្ទេរប្រាក់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ ព្រមទាំងដៃគូសហការផ្សេងៗទៀតតាមរយៈការចុះអនុស្សរណៈយោគយល់គ្នារវាងធនាគារកណ្តាល ដៃគូសហការ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធានាថារាល់ប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែននឹងត្រូវធ្វើតាមប្រព័ន្ធបាគង។ ទន្ទឹមនេះ ក្រុមការងារកំពុងរៀបចំនិងបានដាក់បន្ថែមនូវមុខងារសន្ទានកម្មកុំនៃកម្មវិធីព្យូទ័រ (API) ឱ្យសមាជិកធ្វើសន្ទានកម្មកម្មវិធីធនាគារចល័តសម្រាប់ប្រតិបត្តិការទូទាត់ឆ្លងដែន។

### ច. កិច្ចសហការជាមួយវិស័យសាធារណៈ

ក្នុងកិច្ចសហការគាំទ្រដល់វិស័យរដ្ឋបាលសាធារណៈ ធនាគារជាតិនៃកម្ពុជាបានចូលរួមសហការគាំទ្រ និងធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (API) ជាមួយក្រសួង-ស្ថាប័នដូចជា៖

- **កិច្ចសហការជាមួយក្រសួងសុខាភិបាល**

ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងសុខាភិបាលក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល តាមរយៈការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវតំណភ្ជាប់សម្រាប់ស្វែងរកមើលព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ តាមប្រព័ន្ធបាគង កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣។ បុគ្គលដែលបានចុះ

ឈ្មោះប្រើប្រាស់ ដោយបំពេញព័ត៌មានបានត្រឹមត្រូវរួចរាល់ ស្វែងរកព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួន តាមរយៈកម្មវិធីបាគងបានយ៉ាងងាយស្រួល និងមានភាពច្បាស់លាស់។

- **កិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ**

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការសម្របសម្រួលរៀបចំមធ្យោបាយប្រមូលពន្ធតាមរយៈការទូទាត់តាមប្រព័ន្ធបាគង។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកប្រព័ន្ធបាគងទាំងអស់អាចចូលរួម ដើម្បីក្លាយជាភ្នាក់ងារក្នុងការសម្របសម្រួលដល់ការបង់ពន្ធដាររបស់សាធារណជនតាមបែបបទឌីជីថលប្រកបដោយភាពងាយស្រួល តម្លាភាព និងប្រសិទ្ធភាព។

- **កិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម**

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការលើកកម្ពស់មុខងារទូទាត់សងប្រាក់តាមរយៈប្រព័ន្ធបាគងជាមួយផ្សារពាណិជ្ជកម្មអេឡិចត្រូនិក (CambodiaTrade)។ កិច្ចសហការនេះ នឹងផ្តល់ជាកាលានុវត្តភាពដល់ MSMEs ក្នុងការទទួលបានការទូទាត់សងប្រាក់ពីអតិថិជននៅក្នុងប្រទេសកម្ពុជាតាមបែបឌីជីថល។ ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម កំពុងបន្តលើកទឹកចិត្តឱ្យពាណិជ្ជករ ព្រមទាំងសហគ្រាស ប្រើប្រាស់ KHQR Code សម្រាប់ពាណិជ្ជករវិញ ដើម្បីទទួលបានការទូទាត់សងប្រាក់ឆ្លងដែនពីសំណាក់ភ្ញៀវទេសចរអន្តរជាតិកាន់តែងាយស្រួល រហ័ស និងសុវត្ថិភាព។

- **កិច្ចសហការជាមួយក្រសួងមហាផ្ទៃ**

ធនាគារជាតិនៃកម្ពុជា និងក្រសួងមហាផ្ទៃ កំពុងធ្វើសន្ធានកម្មប្រព័ន្ធបាគង និងសេវារដ្ឋបាលនៅតាមច្រកចេញ-ចូលតែមួយ និងថ្នាលអេឡិចត្រូនិកច្រកចេញ-ចូលតែមួយសម្រាប់ទទួលការទូទាត់សេវាសាធារណៈ។

- **កិច្ចសហការជាមួយគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

ធនាគារជាតិនៃកម្ពុជា និងគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ កំពុងបន្តសិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ឱ្យក្លាយជាភ្នាក់ងារចុះឈ្មោះសម្រាប់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងផ្តល់ជូន KHQR Code សម្រាប់ពាណិជ្ជករដែលជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលចុះឈ្មោះត្រឹមត្រូវរួចហើយ។

- **កិច្ចសហការជាមួយអគ្គិសនីកម្ពុជា**

ធនាគារជាតិនៃកម្ពុជា និងអគ្គិសនីកម្ពុជាបាននិងកំពុងសិក្សាលទ្ធភាពក្នុងការរៀបចំ KHQR Code សម្រាប់បោះពុម្ពលើវិក្កយបត្រអគ្គិសនី ដើម្បីសម្រួលដល់ការទូទាត់ថ្លៃអគ្គិសនីរបស់ប្រជាពលរដ្ឋ បង្កើនប្រសិទ្ធភាពក្នុងការប្រមូលថ្លៃអគ្គិសនីរបស់អគ្គិសនីកម្ពុជា ព្រមលើកកម្ពស់ការទូទាត់ជាឌីជីថលផងដែរ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា និងអគ្គិសនីកម្ពុជាក៏បាននិងកំពុងធ្វើសន្ធានកម្មលើមុខងារការពារការទូទាត់ទ្វេរដងផងដែរ ដើម្បីកាត់បន្ថយហានិភ័យនៃការទូទាត់ស្ទួនរបស់អតិថិជន។

## ប្រអប់ ១ - កម្មវិធីទូទាត់បាគងទេសចរ

ដើម្បីលើកស្ទួយវិស័យទេសចរណ៍នៅកម្ពុជា ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការជាបឋមនូវកម្មវិធីទូទាត់បាគងទេសចរ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤។ តាមរយៈការប្រើប្រាស់កម្មវិធីទូទាត់បាគងទេសចរ ភ្ញៀវទេសចរអន្តរជាតិដែលមកកម្សាន្តនៅប្រទេសកម្ពុជា អាចទាញយកកម្មវិធីទូទាត់បាគងទេសចរដោយភ្ជាប់ជាមួយប័ណ្ណទូទាត់ ដើម្បីទូទាត់ទំនិញ និងសេវាជាមួយខេអេចឃ្យូអរកូត (KHQR Code) របស់ពាណិជ្ជករទូទាំងប្រទេសប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាព។ ជាមួយនឹងនីតិវិធីក្នុងការចុះឈ្មោះប្រើប្រាស់កម្មវិធីទូទាត់បាគងទេសចរដែលមិនមានភាពស្មុគស្មាញ ភ្ញៀវទេសចរអន្តរជាតិ គ្រាន់តែចុះឈ្មោះប្រើប្រាស់កម្មវិធីបាគងទេសចរតាមរយៈអ៊ីមែលផ្ទាល់ខ្លួនជាការស្រេច។ ទន្ទឹមនេះ ភ្ញៀវទេសចរអន្តរជាតិក៏អាចដកប្រាក់ដែលនៅសេសសល់ក្នុងកម្មវិធីទូទាត់បាគងទេសចរ ឬអាចទុកប្រើប្រាស់សម្រាប់ទស្សនកិច្ចទេសចរលើកក្រោយ ឬបញ្ចូលប្រាក់តាមមុខងារដែលមានស្រាប់របស់បាគង។










### ប្រអប់ ២ - ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរជាមួយក្រុមហ៊ុនបណ្ដាញប័ណ្ណទូទាត់អន្តរជាតិ Mastercard

ថ្មីៗនេះ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ ជាមួយក្រុមហ៊ុនបណ្ដាញប័ណ្ណទូទាត់អន្តរជាតិ Mastercard ដើម្បីសម្រួលឱ្យភ្ញៀវទេសចរអន្តរជាតិអាចទទួលបានបទពិសោធន៍ទូទាត់ថ្លៃទំនិញ និងសេវាតាមប្រព័ន្ធឌីជីថលកាន់តែងាយស្រួលដោយគ្រាន់តែទាញយកកម្មវិធីទូទាត់បាគងទេសចរ រួចបញ្ចូលទឹកប្រាក់ក្នុងគណនីបាគងដោយភ្ជាប់ជាមួយប័ណ្ណទូទាត់ Mastercard ដែលមានស្រាប់ពីប្រទេសដើមរបស់ខ្លួន។ សម្រាប់ជំហានបន្ទាប់ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលទ្ធភាពធ្វើសន្ធានកម្មកម្មវិធីទូទាត់បាគងទេសចរជាមួយក្រុមហ៊ុនបណ្ដាញប័ណ្ណទូទាត់អន្តរជាតិផ្សេងទៀតដូចជា Visa Card ដើម្បីជំរុញឱ្យការទូទាត់សងប្រាក់មានភាពទំនើប និងងាយស្រួលសម្រាប់ភ្ញៀវទេសចរអន្តរជាតិ។












## ប្រអប់ ៣ - យុទ្ធនាការប្តូរប្រាក់ចាស់ ទក់ រហែក តាមរយៈការផ្ទេរប្រាក់ចូលគណនីបាគង ឬ គណនីធនាគាររបស់គ្រឹះស្ថានធនាគារ

នៅក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំប្តូរប្រាក់ចាស់ ទក់ រហែក ជូនប្រជាពលរដ្ឋ តាមរយៈការផ្ទេរប្រាក់ចូលគណនីបាគង ឬគណនីធនាគាររបស់គ្រឹះស្ថានធនាគារចំនួន ១៦ លើក ក្នុងគោលបំណងបង្កើនការយល់ដឹង និងជំរុញឱ្យមានការប្រើប្រាស់គណនីបាគង និងការទូទាត់តាមរយៈ KHQR Code ឱ្យកាន់តែទូលំទូលាយជាងមុន និងមានប្រជាពលរដ្ឋចូលរួមប្រមាណ ២០.៨៥០ នាក់។

ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា បានធ្វើប្រតិបត្តិការផ្ទេរប្រាក់ចំនួន ៩.៤៧៣ ប្រតិបត្តិការ ដែលមានទំហំប្រាក់ចំនួន ៣.៩៥៧.២៨៨.២០០ រៀល ចូលទៅគណនីបាគង និងគណនីធនាគាររបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យធនាគារ ក្រុមការងារធនាគារជាតិនៃកម្ពុជា បានសហការជាមួយគ្រឹះស្ថានសមាជិកប្រព័ន្ធបាគង បានបើកគណនីបាគងចំនួន ៣.០៦១ គណនី និងគណនីធនាគារចំនួន ៦៥.៤១៣ គណនី ជូនប្រជាពលរដ្ឋ។










# ៣ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

អនុលោមតាមបេសកកម្ម និងការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានបន្តពិនិត្យ និងអនុវត្តច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយផ្សេងៗ ដើម្បីគាំទ្រវឌ្ឍនភាពនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល និងដើម្បីធានាថាប្រព័ន្ធទាំងនោះគោរពតាមគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់ និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។

## ៣.១. ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអភិវឌ្ឍ និងមួយចំនួនត្រូវបានធ្វើទំនើបកម្មតាមរយៈការធ្វើបច្ចុប្បន្នកម្មលើមុខងារបន្ថែមចាំបាច់មួយចំនួន ដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឌីជីថល ព្រមទាំងជំរុញបរិយាបន្នហិរញ្ញវត្ថុ។ បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលត្រូវបានដាក់ឱ្យប្រើប្រាស់រួមមាន៖

### ក. ប្រព័ន្ធផាត់ទាត់ជាតិ (NCS)

ប្រព័ន្ធផាត់ទាត់ជាតិ បានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រួលដល់ការផាត់ទាត់ និងទូទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការអន្តរធនាគារ តាមរយៈឧបករណ៍ទូទាត់សងប្រាក់ជាមូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទានទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក រវាងគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធផាត់ទាត់ជាតិប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល ហើយមានមណ្ឌលដោះដូរមូលប្បទានបត្ររូបវន្តនៅទីស្នាក់ការកណ្ដាលធនាគារជាតិនៃកម្ពុជា និងតាមបណ្ដាសាខាធនាគារជាតិនៃកម្ពុជាខេត្តចំនួន ៧ គឺ សៀមរាប បាត់ដំបង កំពង់ចាម ព្រះសីហនុ បន្ទាយមានជ័យ ស្វាយរៀង និងកំពង់ឆ្នាំង។ ប្រព័ន្ធផាត់ទាត់ជាតិមានគ្រឹះស្ថានជាសមាជិកចំនួន ៦៣ ដែលក្នុងនោះគ្រឹះស្ថានចំនួន ៤៨ ជាសមាជិកផ្ទាល់ និង ១៥ គ្រឹះស្ថានជាសមាជិកមិនផ្ទាល់។

#### - មូលប្បទានបត្រ

ក្នុងឆ្នាំ២០២៤ ចំនួនមូលប្បទានបត្រជាប្រាក់រៀលដែលបានឆ្លងកាត់ការផាត់ទាត់ និងទូទាត់តាមរយៈប្រព័ន្ធផាត់ទាត់ជាតិមានចំនួនប្រមាណ ៣២.៧០៦ សន្លឹក (ថយចុះ ៤,១១%) និងទំហំប្រាក់ប្រមាណ ២១.៦៤៩,៥៦ ប៊ីលានរៀល (ធ្លាក់ចុះ ១,៦០%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់រៀលមានប្រមាណ ៩៨ សន្លឹក (ថយចុះ ៣៤,២០%) និងទំហំប្រាក់ ១៣១,៥០ ប៊ីលានរៀល (កើនឡើង ១៧៩,៥៨%)។

ជាមួយគ្នានេះ ចំនួនមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានចំនួនប្រមាណ ១.០១៤.៧៨៥ សន្លឹក (ថយចុះ ២,៥៨%) និងទំហំប្រាក់ ៥៧.៥៩៣,៧៣ លានដុល្លារអាមេរិក (កើនឡើង ២៩,៦១%)។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់ដុល្លារអាមេរិកមានប្រមាណ ១០.១៨០ សន្លឹក (ថយចុះ ១៣,៤៣%) និងទំហំប្រាក់ ១១.៧៩០,៨៤ លានដុល្លារអាមេរិក (កើនឡើង ១២២៧,៤២%)។ ទំហំប្រាក់សរុបរបស់មូលប្បទានបត្រធ្វើប្រតិបត្តិការតាមប្រព័ន្ធជាត់ទាត់ជាតិនៅក្នុងឆ្នាំ២០២៤ មានទំហំប្រមាណ ១៤០,១៣% នៃផ.ស.ស។

**តារាង ១៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់មូលប្បទានបត្រ**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (គិតជាប៊ីលាន) | ដុល្លារអាមេរិក (គិតជាលាន) |
| **២០២០** | ៣៥.៥៧០ | ១.២០០.១១០ | ២២.៩៥៥,៣២ | ៥០.២២០ |
| **២០២១** | ៣១.៧៤៩ | ១.០៧៧.១០៤ | ១៩.០៨៩,៣៥ | ៤៦.៣៨១,០៦ |
| **២០២២** | ៣៣.៦០៨ | ១.១០៥.៧១២ | ១៩.៨៣១,៣០ | ៥៣.៨៥៣,៩៤ |
| **២០២៣** | ៣៤.១០៩ | ១.០៤១.៧១០ | ២២.០០២,៧៤ | ៤៤.៤៣៣,១៩ |
| **២០២៤** | ៣២.៧០៦ | ១.០១៤.៧៨៥ | ២១.៦៤៩,៥៦ | ៥៧.៥៩៣,៧៣ |

**ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមក្រាហ្វខាងលើបង្ហាញថា មូលប្បទានបត្រដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិជាប្រាក់រៀលមានការថយចុះទាំងចំនួនប្រតិបត្តិការ និងទំហំប្រាក់ រីឯមូលប្បទានបត្រដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិជាប្រាក់ដុល្លារអាមេរិកមាននិន្នាការប្រែប្រួលដោយចំនួនប្រតិបត្តិការមានការថយចុះ ប៉ុន្តែទំហំប្រាក់មានការកើនឡើងបើធៀបនឹងឆ្នាំ២០២៣។ ទោះបីមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានការប្រែប្រួលបន្តិច ក៏ប៉ុន្តែមូលប្បទានបត្រជារួមនៅតែជាឧបករណ៍ទូទាត់សងប្រាក់ដែលពេញនិយមប្រើប្រាស់សម្រាប់ការទូទាត់ក្នុងសេដ្ឋកិច្ច។

ដោយសារមូលប្បទានបត្រនៅតែជាឧបករណ៍ទូទាត់សងប្រាក់ដែលមានហានិភ័យខ្ពស់ជាងឧបករណ៍ទូទាត់ដទៃ ដូច្នេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តអនុវត្តវិធានការមួយចំនួនដើម្បីកាត់បន្ថយការប្រើប្រាស់មូលប្បទានបត្រ និងកាត់បន្ថយចំនួនមូលប្បទានបត្រគ្មានសាច់ប្រាក់ តាមរយៈការលើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកពង្រឹងការអនុវត្តលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់មូលប្បទានបត្រ តាមដានសមតុល្យគណនីជាប្រចាំ និងសិក្សាពីវិធានការនានា ដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនមូលប្បទានបត្រគ្មានសាច់ប្រាក់។

### - បញ្ជាផ្ទេរប្រាក់ជាអេឡិចត្រូនិក

នៅក្នុងឆ្នាំ២០២៤ ចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលមានចំនួនប្រមាណ ៣៧.៨៥០ ប្រតិបត្តិការ (កើនឡើង ៣៣,៥៥%) ដែលមានទំហំប្រាក់ ៥.២៣៦,៨៧ ប៊ីលានរៀល (កើនឡើង ៧,៣៨%)។ ជាមួយគ្នានេះ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមានប្រមាណ ៦១០.៩៥០ ប្រតិបត្តិការ (ថយចុះ ៣,៣៣%) និងទំហំប្រាក់ប្រមាណ ១៥.៣៩៣,៦១ លានដុល្លារអាមេរិក (កើនឡើង ១៧,៣៨%)។ ទំហំប្រាក់សរុបរបស់បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធផាត់ទាត់ជាតិនៅក្នុងឆ្នាំ២០២៤ មានទំហំប្រមាណ ៣៧,១៥% នៃផ.ស.ស។

ជារួមចំនួនបញ្ជាផ្ទេរ និងទំហំប្រាក់ជាប្រាក់រៀលមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៣។ ដោយឡែក ចំពោះបញ្ជាផ្ទេរជាប្រាក់ដុល្លារអាមេរិក ចំនួនប្រតិបត្តិការមានការថយចុះ ប៉ុន្តែទំហំប្រាក់នៅតែបន្តកើនឡើងដដែល។ ដើម្បីបន្តជំរុញការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជា បាននិងកំពុងដាក់ចេញគោលការណ៍មួយចំនួនដូចជាពង្រីកបណ្តាញផ្តល់សេវាបញ្ជាផ្ទេរប្រាក់តាមរយៈសេវាធនាគារអ៊ីនធឺណិត ឬសេវាធនាគារចល័ត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់អតិថិជនប្រើប្រាស់ និងលើកទឹកចិត្តក្នុងការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក តាមរយៈការយកកម្រៃប្រតិបត្តិការតិចជាងប្រតិបត្តិការមូលប្បទានបត្រ។

## តារាង ២៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់បញ្ជាផ្ទេរប្រាក់ជាអេឡិចត្រូនិក

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (គិតជាប៊ីលាន) | ដុល្លារអាមេរិក (គិតជាលាន) |
| **២០២០** | ១០.១០១ | ៣២៨.៤៣៤ | ៤.៦៦៣,២៥ | ១២.៧០៦,៥៩ |
| **២០២១** | ១៥.៨៩៨ | ៥៦៣.០៧៧ | ៤.៨៩៧,៤៦ | ១០.៤០៦,១២ |
| **២០២២** | ២២.៥៤០ | ៦៧៥.៤៥១ | ៤.៥៦១ | ១២.៣១៩,៣០ |
| **២០២៣** | ២៨.៣៣៤ | ៦៣២.០០៩ | ៤.៨៧៦,៩៨ | ១៣.១១៧,៩៨ |
| **២០២៤** | ៣៧.៨៤០ | ៦១០.៩៥០ | ៥.២៣៦,៨៧ | ១៥.៣៩៣,៦១ |

**ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. ប្រព័ន្ធសេវាទូទាត់រហ័ស (FAST)

គិតត្រឹមឆ្នាំ២០២៤ ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុបចំនួន ៥៧ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ៣៥ បានដាក់ដំណើរការជាផ្លូវការ។ គួរបញ្ជាក់ផងដែរថា ប្រព័ន្ធសេវាទូទាត់រហ័សត្រូវបានដាក់ឱ្យប្រើប្រាស់ចាប់តាំងពីឆ្នាំ២០១៦ និងត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0) ដែលបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ក្នុងគោលបំណងសម្រួលដល់ការធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគារជាប្រាក់រៀល និងសម្រួលឱ្យអតិថិជនអាចទទួលបានមូលនិធិភ្លាមៗ។

នៅក្នុងឆ្នាំ២០២៤ បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធសេវាទូទាត់រហ័សមានប្រមាណ ៩.៣៨៣ ប្រតិបត្តិការ (ថយចុះ ៧៨,១៨%) និងទំហំប្រាក់មានចំនួនប្រមាណ ៨,៥៧ ប៊ីលានរៀល (ថយចុះ ៨៩,៧០%) ស្មើនឹង ០,០០៥% នៃផ.ស.ស។

**ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ FAST**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមទិន្នន័យក្នុងក្រាហ្វខាងលើបានបង្ហាញថា ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀលដែលធ្វើឡើងតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការថយចុះ ដោយសារប្រព័ន្ធនេះត្រូវបានធ្វើទំនើបកម្ម ហើយទើបនឹងដាក់ឱ្យដំណើរការជាបណ្តើរៗឡើងវិញ ប៉ុន្តែទំហំប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់រៀលនៅបន្តការកើនឡើង ដែលបង្ហាញឱ្យឃើញថាការប្រើប្រាស់តាមរយៈប្រព័ន្ធសេវាទូទាត់រហ័សនៅមានការពេញនិយមសម្រាប់អតិថិជនទូទៅ ក៏ដូចជាពាណិជ្ជករទូទាត់រាយសម្រាប់ធ្វើប្រតិបត្តិការទូទាត់ជាប្រាក់រៀល។

## គ. ប្រព័ន្ធខេមបូខានស្វែស្វីច (CSS)

ប្រព័ន្ធខេមបូខានស្វែស្វីច ជាប្រតិបត្តិករស្វីច (Local Switch) ត្រូវបានអភិវឌ្ឍឡើងដើម្បីផ្តល់ជាមធ្យោបាយងាយស្រួលសម្រាប់អតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ធ្វើប្រតិបត្តិការទូទាត់ឆ្លងគ្រឹះស្ថានតាមប័ណ្ណទូទាត់ឥណពន្ធខេមបូខានស្វែស្វីចលើគ្រប់ម៉ាស៊ីនដាក់/ដកប្រាក់ (ATM) និងម៉ាស៊ីនឆូតកាត (POS) របស់គ្រឹះស្ថានសមាជិក និងជា Switch ដើម្បីធ្វើសមាហរណកម្មជាមួយប្រទេសក្នុងតំបន់។ ប្រព័ន្ធនេះបានដាក់ឱ្យដំណើរការបឋមកាលពីឆ្នាំ២០១៧ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣។ គិតត្រឹមឆ្នាំ២០២៤ ប្រព័ន្ធខេមបូខានស្វែស្វីចមានសមាជិកសរុបចំនួន ៦០ គ្រឹះស្ថាន ដែលក្នុងនោះសមាជិកផ្ទាល់ដែលជាធនាគារពាណិជ្ជមានចំនួន ៥២ សមាជិកផ្ទាល់ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៤ និងសមាជិកមិនផ្ទាល់ជាធនាគារពាណិជ្ជមានចំនួន ៤ ហើយបច្ចុប្បន្ន សមាជិកកំពុងដំណើរការមានចំនួន ៤២ ខណៈគ្រឹះស្ថានសមាជិកដទៃទៀតកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍផ្សេងៗគ្នា។

ក្នុងឆ្នាំ២០២៤ នេះ ប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលដែលបានចូលទូទាត់តាមប្រព័ន្ធខេមបូខានស្វែស្វីចមានចំនួនប្រមាណ ១៦៣.៩៧០ ប្រតិបត្តិការ (ថយចុះ ៤១,៦០%) និងទំហំប្រាក់មានចំនួន ៣៥,៦១ ប៊ីលានរៀល (ថយចុះ ៤៣,២៦%)។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់ដុល្លារអាមេរិកមានចំនួនប្រមាណ ៣៣.៨៨១ ប្រតិបត្តិការ (ថយចុះ ៣៨,៦៩%) និងទំហំប្រាក់មានចំនួន ៤,៤៨ លានដុល្លារអាមេរិក (ថយចុះ ៤០,៦១%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធខេមបូខានស្វែស្វីចនៅក្នុងឆ្នាំ២០២៤ មានទំហំ ៩,៩៩% នៃផ.ស.ស។

**តារាង ៣៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រព័ន្ធខេមបូខានស្វែស្វីច (CSS)**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (គិតជាលាន) | ដុល្លារអាមេរិក (គិតជាពាន់) |
| **២០២០** | ២០៧.៨៧៨ | ៤៧.៨០០ | ៤២.៧៣០ | ៩.៨៨៨ |
| **២០២១** | ៣១៨.៣៩០ | ៨៦.៩៩៣ | ៧៦.២២៨ | ១០.៣៧០ |
| **២០២២** | ៣៧៧.១៩០ | ៨៩.៧៥៩ | ៨៦.២១៦ | ១១.៨៦៣ |
| **២០២៣** | ២៨០.៨១៨ | ៥៥.២៧០ | ៦២.៧៧៧ | ៧.៥៥៩ |
| **២០២៤** | ១៦៣.៩៧០ | ៣៣.៨៨១ | ៣៥.៦១៦ | ៤.៤៨៣ |

**ក្រាហ្វ ៩ - ប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធខេមបូឌានស៊ែស្វិច**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឃ. ប្រព័ន្ធធនាគារអនឡាញ (OBS)

គិតត្រឹមឆ្នាំ២០២៤ ប្រព័ន្ធធនាគារអេឡិចត្រូនិកមានសមាជិកសរុបចំនួន ៨៣ គ្រឹះស្ថាន ដែលក្នុងនោះមានធនាគារពាណិជ្ជចំនួន ៥៦ ធនាគារឯកទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១៧ និងស្ថាប័នរដ្ឋចំនួន ១ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។

ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS មានចំនួនសរុបប្រមាណ ៨២ .៩៨៨ ប្រតិបត្តិការ ដែលក្នុងនោះការផ្ទេរប្រាក់ក្នុងចំណោមគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមាន ៨២.២១២ ប្រតិបត្តិការ និងការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តមាន ៧៧៦ ប្រតិបត្តិការ។ ការផ្ទេរប្រាក់ជាប្រាក់រៀលរវាងគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមានចំនួន ៥២.៥០៩ ប្រតិបត្តិការ (កើនឡើង ២០,៨៧%) ស្មើនឹងទំហំប្រាក់ ១៣៥,៨១ ទ្រីលានរៀល (កើនឡើង ១៦,១៩%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ២៩.៧០៣ ប្រតិបត្តិការ (កើនឡើង ២៤,៨៩%) ស្មើទំហំប្រាក់ ៨៧.៧៤០ លានដុល្លារអាមេរិក (កើនឡើង ៤១,០៧%)។ ក្នុងរយៈពេលដូចគ្នានេះ ប្រតិបត្តិការផ្ទេរប្រាក់ជាប្រាក់រៀលរវាងគណនីនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តមានចំនួន ៤១០ ប្រតិបត្តិការ (ថយចុះ ១៥,៤៦%) ស្មើទំហំប្រាក់ ៦,២១ ទ្រីលានរៀល (កើនឡើង

៣០,៩៧%) និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣៦៦ ប្រតិបត្តិការ (ថយចុះ ២១,៦២%) ស្មើទំហំប្រាក់ ៣.៩៨៧ លានដុល្លារអាមេរិក (កើនឡើង ៨៩,៣៧%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធធនាគារអេឡិចត្រូនិចនៅក្នុងឆ្នាំ២០២៤ មានទំហំ ២៨២% នៃផ.ស.ស។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រព័ន្ធ OBS នៅតែជាប្រព័ន្ធដែលមានប្រជាប្រិយភាព។ ទោះបីជាយ៉ាងណាក៏ដោយ ធនាគារជាតិនៃកម្ពុជានៅតែបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីជំរុញការទូទាត់សងប្រាក់ជាអេឡិចត្រូនិក និងសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ឱ្យកាន់តែងាយស្រួល និងសុវត្ថិភាព។

**តារាង ៤៖ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្ដាលតាមប្រព័ន្ធ OBS**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (ទ្រីលាន) | ដុល្លារអាមេរិក (លាន) |
| ឆ្នាំ ២០២០ | ២០.៩៦០ | ១១.៣៣០ | ៧២ | ៣១.៨៣៧,០៩ |
| ឆ្នាំ ២០២១ | ២៦.៩០៨ | ១៥.២៤៧ | ៨០,៨៩ | ៤២.៨៧០,៨ |
| ឆ្នាំ ២០២២ | ៣៣.៥៨៤ | ២០.០០០ | ៩១,១៨ | ៥៩.៥៥០,៧៧ |
| ឆ្នាំ ២០២៣ | ៤៣.៤៣៩ | ២៣.៦០៨ | ១១៦,៨៨ | ៦២.៩១៦,៥៦ |
| ឆ្នាំ ២០២៤ | ៥២.៥០៩ | ២៩.៧០៣ | ១៣៥,៨១៧ | ៨៧.៧៤០,០៦ |

**តារាង ៥៖ ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្ដាលនិងសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (ទ្រីលាន) | ដុល្លារអាមេរិក (លាន) |
| ឆ្នាំ ២០២០ | ៩៣៣ | ៨៥៣ | ២,៥ | ៧៥៦ |
| ឆ្នាំ ២០២១ | ៩២១ | ៨៣៤ | ៣,៣ | ១.០៤២ |
| ឆ្នាំ ២០២២ | ៥៥៤ | ៥៣៣ | ២,៥ | ៩៨១ |
| ឆ្នាំ ២០២៣ | ៤៨៥ | ៤៦៧ | ៤,៧៤ | ២.១០៥ |
| ឆ្នាំ ២០២៤ | ៤១០ | ៣៦៦ | ៦,២១ | ៣.៩៨៧ |

**ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធ OBS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ង. ប្រព័ន្ធរីថែលផេ (Retail Pay)

ប្រព័ន្ធរីថែលផេ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ដែលប្រព័ន្ធនេះមានប្រព័ន្ធរងចំនួន ៤ គឺ ១/-ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) ២/-ប្រព័ន្ធទូទាត់ចល័ត (MPS) ៣/-ប្រព័ន្ធទូទាត់តាម QR-Code (QPS) និង ៤/-ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (ECS) ដែលក្នុងចំណោមប្រព័ន្ធទាំង ៤ មានតែប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិកប៉ុណ្ណោះ ដែលបានដាក់ឱ្យប្រើប្រាស់ ចំណែកប្រព័ន្ធផ្សេងទៀតកំពុងស្ថិតក្នុងដំណាក់កាលធ្វើសន្ទានកម្ម។

គិតត្រឹមឆ្នាំ២០២៤ ប្រព័ន្ធរីថែលផេមានគ្រឹះស្ថានសមាជិកសរុបចំនួន ២៤ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ១៦ បានដាក់ឱ្យដំណើរការប្រព័ន្ធរីថែលផេជាសាធារណៈតាមគ្រប់បណ្តាញប្រតិបត្តិការរបស់ខ្លួនដែលរួមមាន ការធ្វើប្រតិបត្តិការតាមបញ្ជររបស់គ្រឹះស្ថាន និងតាមបណ្តាញសេវាធនាគារចល័តរបស់ខ្លួន ដោយអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគាររវាងគ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងប្រសិទ្ធភាព។

ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT ជាប្រាក់រៀល មានចំនួន ៦.៧៤៣ ប្រតិបត្តិការ (ថយចុះ ៥៩,២៩%) និងមានទំហំប្រាក់ជាប្រាក់រៀល ២៣៥.៦៩០ លានរៀល (ថយចុះ ៤៦,៣១%)។ រីឯ ចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៩.០៣៩ ប្រតិបត្តិការ (ថយចុះ

៥៨,៥០%) និងមានទំហំប្រាក់ ១២៩,៥៨ លានដុល្លារអាមេរិក (ថយចុះ ៣៨,៨០%)។ ទំហំប្រាក់សរុបធ្វើប្រតិបត្តិការតាមប្រព័ន្ធរីផែលផេនៅក្នុងឆ្នាំ២០២៤ មានទំហំ ០,៤២% នៃផ.ស.ស។

**តារាង ៦៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រព័ន្ធរីផែលផេ**

| ឆ្នាំ | ចំនួនប្រតិបត្តិការ | | ទំហំប្រាក់ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល (គិតជាលាន) | ដុល្លារអាមេរិក (គិតជាលាន) |
| **២០២០** | ៩.០២២ | ១៥.៣៩៧ | ៤៤.២៦១ | ៥៧.៥៦៦ |
| **២០២១** | ៣៤.៣៨២ | ៦៦.៤២៦ | ៤០១.៧៥៦ | ២០២.៦៧០ |
| **២០២២** | ២១.៥៧០ | ៣៨.៨៨២ | ៤០៨.៩០៩ | ៧៨,៩៧ |
| **២០២៣** | ១៦.៥៦៦ | ៤៥.៨៨៦ | ៤៣៩.០៤០ | ២១២ |
| **២០២៤** | ៦.៧៤៣ | ១៩.០៣៩ | ២៣៥.៦៩០ | ១២៩,៥៨ |

**ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៤ ប្រព័ន្ធបាគងជាប្រព័ន្ធទូទាត់ដែលពេញនិយមដោយមានការប្រើប្រាស់ច្រើនជាងប្រព័ន្ធទូទាត់ផ្សេងៗទៀត បើផ្អែកលើចំនួនប្រតិបត្តិការ។ រីឯ ប្រព័ន្ធធនាគារអនឡាញនៅតែជាប្រព័ន្ធដែលមានទំហំប្រាក់ប្រតិបត្តិការទូទាត់ច្រើនជាងប្រព័ន្ធទូទាត់ផ្សេងៗទៀត ដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម៖

**ក្រាហ្វ ១២ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់នៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.២. ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់

ស្របពេលដែលទិដ្ឋភាពហិរញ្ញវត្ថុមានការវិវឌ្ឍឥតឈប់ឈរ ធនាគារជាតិនៃកម្ពុជានៅតែប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តក្នុងការពង្រឹងប្រព័ន្ធទូទាត់នៅក្នុងប្រទេសកម្ពុជា។ ការធានានូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់សងប្រាក់ ជាកត្តាសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងបង្កើនភាពធន់ផ្នែកហិរញ្ញវត្ថុ។ ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានអនុវត្តឡើងក្នុងគោលបំណងបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងកាត់បន្ថយហានិភ័យចម្បងៗដែលអាចកើតមានក្នុងប្រព័ន្ធទូទាត់ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ។

ដើម្បីបំពេញកាតព្វកិច្ចទាំងនេះបានយ៉ាងប្រសើរ ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមរៀបចំដាក់ចេញនូវយន្តការដូចខាងក្រោម៖

## ក. ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដែលជាឯកសារមូលដ្ឋានបង្ហាញគោលដៅនៃគោលនយោបាយត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលអនុវត្តដោយធនាគារជាតិនៃកម្ពុជា និងជាគោលការណ៍ណែនាំសម្រាប់យកមកធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីកម្រិតហានិភ័យចម្បងៗរបស់ប្រព័ន្ធទូទាត់សងប្រាក់។ ឯកសារនេះ រៀបចំឡើងដោយមានចំណុចសំខាន់ៗចំនួន១០ជំពូក ដូចជា៖ ១) សេចក្តីផ្តើម ២) តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងប្រព័ន្ធទូទាត់សងប្រាក់ ៣) សារៈសំខាន់ក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ៤) វិសាលភាពនៃការត្រួតពិនិត្យ ៥) បទដ្ឋានស្តង់ដារសម្រាប់ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ៦) វិធីសាស្ត្រ ណែនាំក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ៧) កិច្ចសហការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ៨) ការទទួលខុសត្រូវក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ៩) ការកំណត់រយៈពេល ដែលត្រូវអនុវត្តការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និង ១០) ការធ្វើបច្ចុប្បន្នកម្មក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់។

## ខ. ការអនុលោមតាមគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI)

ស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធនាគារ ប្រព័ន្ធទូទាត់សងប្រាក់ ដើរតួនាទីយ៉ាងសំខាន់ដើម្បីរក្សាប្រសិទ្ធភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចទាំងមូល។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាតួនាទីចម្បងមួយផងដែររបស់ធនាគារជាតិនៃកម្ពុជាក្នុងចំណោមតួនាទីផ្សេងៗទៀត និងអនុវត្តឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងមូល។ ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមបទដ្ឋានស្តង់ដារគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។ ក្នុងចំណោមគោលការណ៍ទាំង ២៤ របស់គោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) មានគោលការណ៍ចំនួន ១៧ ត្រូវបានអនុវត្តសម្រាប់ត្រួតពិនិត្យលើប្រព័ន្ធទូទាត់សងប្រាក់។

ប្រព័ន្ធទូទាត់សងប្រាក់ដែលមានលក្ខណៈសំខាន់ជាប្រព័ន្ធ (Systemically Important Payment Systems-SIPS) នឹងត្រូវស្ថិតនៅក្រោមវិសាលភាពក្នុងការត្រួតពិនិត្យ ដោយផ្អែកទៅលើ ចំនួនប្រតិបត្តិការ និងទំហំប្រាក់។ ចំពោះប្រព័ន្ធទូទាត់សងប្រាក់ផ្សេងៗទៀតដែលអភិវឌ្ឍពេលអនាគត ក៏នឹងត្រូវស្ថិតក្រោមវិសាលភាពនៃការត្រួតពិនិត្យផងដែរ ប្រសិនបើធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថាចាំបាច់។

# ៤ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

## ៤.១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីកាន់តែសំខាន់ក្នុងការផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាព និងជួយសម្រួលដល់ការរក្សាបាននូវប្រក្រតីភាពនៃសកម្មភាព និងប្រតិបត្តិការរបស់វិស័យសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់។ ក្នុងចំណោមនោះ ការចាប់យក និងការប្រើប្រាស់ "បច្ចេកវិទ្យាហិរញ្ញវត្ថុ" ទាំងក្នុងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារមានសន្ទុះ និងកំពុងតែបោះជំហានក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ដែលបានជួយសម្រួលដល់ការរស់នៅប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់ ការប្រកបអាជីវកម្មក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមទាំងមូល។ សន្ទុះនៃការអភិវឌ្ឍទាំងនេះ បាននិងកំពុងក្លាយជាកាលានុវត្តភាពថ្មី ដើម្បីជំរុញការអភិវឌ្ឍនវានុវត្តន៍ឌីជីថល ព្រមទាំងបង្កើតធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Startups) ដែលជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការសម្រេចឱ្យបាននូវការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាដ៏រស់រវើកដែលស្របទៅនឹងមុំទី ៥ នៃបញ្ចកោណទី ៥ ស្តីពី ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញក្នុងនីតិកាលទី ៧ នេះ។

បច្ចេកវិទ្យាហិរញ្ញវត្ថុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលនៅក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញពីសក្តានុពលរបស់ច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់ក្នុងការរៀបចំក្របខណ្ឌគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងអ្នកប្រើប្រាស់អាចទទួលបានសេវាទូទាត់សងប្រាក់ដែលគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទោះបីជាមានការរំពឹងទុកពីលទ្ធផលវិជ្ជមានដែលនឹងទទួលបានពីការអភិវឌ្ឍក្នុងដំណាក់កាលដំបូងក៏ដោយក៏ការវិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ បានជំរុញឱ្យធនាគារជាតិនៃកម្ពុជា ពង្រឹងក្របខណ្ឌគតិយុត្ត ដើម្បីធានាថាបច្ចេកវិទ្យាហិរញ្ញវត្ថុមានសុវត្ថិភាព និងស្ថិរភាព ព្រមទាំងគាំទ្រដល់ហេដ្ឋា-រចនាសម្ព័ន្ធចម្បងៗ អាចធ្វើប្រតិបត្តិការទូទាត់អន្តរគ្រឹះស្ថានកាន់តែប្រសើរ និងមានប្រសិទ្ធភាពផងដែរ។ ការណ៍នេះ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ២០២០-២០២៥ ត្រូវបានរៀបចំឡើង ផ្តោតលើសសរស្តម្ភសំខាន់ៗចំនួន ៣ ដែលជាឧត្តមានុវត្តន៍អន្តរជាតិ ប៉ុន្តែត្រូវបានរៀបចំនិងកែសម្រួលឱ្យស្របតាមបរិបទរបស់ប្រទេសកម្ពុជា ដូចជា (១) សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ (២) បច្ចេកវិទ្យាគាំទ្រ និង (៣) គោលនយោបាយជំរុញ។ លើសពីនេះ ផែនទីមគ្គុទ្ទេសក៍នេះ ក៏បានកំណត់វិស័យអាទិភាពសំខាន់ៗដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។

ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តនូវ "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" ដែលមានចក្ខុវិស័យរយៈពេលវែង "អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដោយឈរលើ មូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក"។ គោលនយោបាយនេះ មានគោលបំណងអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ ភាពជឿទុកចិត្ត និងគុណភាពជីវិតរបស់អ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល តាមរយៈការកំណត់នូវគោលដៅចម្បង" រួមមាន ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ការអភិវឌ្ឍផ្ទាលឌីជីថលគ្រឹះ ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និងការជំរុញការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ។

## ៤.២. វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ

### ៤.២.១ កម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុនឆ្នាំ២០២៤

កម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុនឆ្នាំ២០២៤ ធ្វើឡើងរយៈពេល ៥ ថ្ងៃ ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំភាគីពាក់ព័ន្ធ ក្នុងនោះក៏មានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់បណ្តាធនាគារកណ្តាល អ្នកជំនាញផ្នែកហិរញ្ញវត្ថុលំដាប់ពិភពលោក ព្រមទាំងតំណាងជាន់ខ្ពស់មកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ចូលរួមសហការក្នុងការជំរុញការប្រើប្រាស់នវានុវត្តន៍នៃបច្ចេកវិទ្យាក្នុងសេវាហិរញ្ញវត្ថុ និងដើម្បីផ្តល់ជាវេទិកាពិភាក្សាលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងការរីកចម្រើននៃសេវាហិរញ្ញវត្ថុនាថ្ងៃអនាគត។ កម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុនឆ្នាំ២០២៤ ក៏ផ្តល់ជាកាលានុវត្តភាពដល់អ្នកចូលរួម ដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងរចនាសម្ព័ន្ធនៅក្នុងឧស្សាហកម្មហិរញ្ញវត្ថុជប៉ុន ជំរុញសេដ្ឋកិច្ចឌីជីថលរបស់ប្រទេសជប៉ុន និងការប្រកួតប្រជែងជាសកលតាមរយៈការបណ្តាក់ទុនលើបច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅចែករំលែកពីទស្សនៈរបស់អ្នកជំនាញ និងអ្នករៀបចំគោលនយោបាយដែលនឹងរួមចំណែកជំរុញប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងនវានុវត្តន៍ ដែលរួមចំណែកពីវិស័យសាធារណៈ និងវិស័យឯកជន។

ក្នុងកម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុជប៉ុនឆ្នាំ២០២៤ នោះដែរ ក៏មានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសដោយ លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងវេទិកាពិភាក្សាស្តីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (Artificial Intelligence-AI)"។ ការចូលរួមរបស់លោកជំទាវទេសាភិបាល ក្នុងនាមជាវាគ្មិនកិត្តិយសក្នុងវេទិកាលំដាប់ពិភពលោកនេះ ឆ្លុះបញ្ចាំងពីការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

និងទស្សនវិស័យអនាគតច្បាស់លាស់របស់លោកជំទាវក្នុងការដឹកនាំធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្លើយតបនឹងនិន្នាការហិរញ្ញវត្ថុសកល ក៏ដូចជាផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាទូទៅ។




លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាពិភាក្សា ស្តីពី "ការបង្កើតអនាគតបច្ចេកវិទ្យាហិរញ្ញវត្ថុ ៖ កិច្ចពិភាក្សាកម្រិតគោលនយោបាយអំពីបញ្ញាសិប្បនិម្មិត (AI)" នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

## ៤.២.២ កិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃឆ្នាំ២០២៤

កិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ ឆ្នាំ២០២៤ បានប្រព្រឹត្តទៅចំនួនពីរថ្ងៃ ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងឌុយបៃ នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម ដោយមានការចូលរួមពីអ្នករៀបចំគោលនយោបាយ វិនិយោគិន សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងអ្នកសារព័ត៌មានដែលមកពីប្រទេសជាង១០០ ទូទាំងពិភពលោក។

ក្នុងកិច្ចប្រជុំកំពូលនោះ លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាពិភាក្សាក្រោមប្រធានបទ "មូលធនប្រកបដោយចីរភាព៖ ហិរញ្ញវត្ថុដែលគិតគូរពីបរិស្ថាន" នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤។ វេទិកាពិភាក្សានោះ ត្រូវបានរៀបចំឡើង និងជាកម្មវិធីពិសេសមួយនៃកិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ (Dubai Fintech Summit) ក្នុងគោលបំណងពិភាក្សា និងចែករំលែកទស្សនៈទាក់ទងនឹងតួនាទីរបស់ធនាគារកណ្តាល និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការចូលរួមចំណែកលើកកម្ពស់បរិស្ថានបៃតង។ លោកជំទាវបានថ្លែងអំពីតួនាទីដ៏សំខាន់នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការជំរុញនិរន្តរភាពហិរញ្ញវត្ថុ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងកាត់បន្ថយការចំណាយក្នុងការផ្ទេរប្រាក់របស់ប្រជាជន។ លើសពីនេះ លោកជំទាវ ក៏បានចែករំលែកបទពិសោធន៍នៃការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជាលើសញ្ញាប័ណ្ណបៃតង និងសញ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (Environmental, Social, Governance-ESG)

ដែលត្រូវបានបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ សំដៅរួមចំណែកក្នុងការលើកកម្ពស់បរិស្ថាន។




លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនកិត្តិយស
ក្នុងវេទិកាពិភាក្សាក្រោមប្រធានបទ "មូលធនប្រកបដោយចីរភាព៖ ហិរញ្ញវត្ថុដែលគិតគូរពីបរិស្ថាន" នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤
នៅទីក្រុងឌុយបៃ ប្រទេសអេមីរ៉ាតអារ៉ាប់រួម

### ៤.២.៣ វេទិកា Nikkei Forum លើកទី២៩ មូលបទ "អនាគតនៃទ្វីបអាស៊ី"

វេទិកា Nikkei Forum ឆ្នាំ២០២៤ បានរៀបចំឡើងចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដែលមានការចូលរួមពីថ្នាក់ដឹកនាំតំបន់អាស៊ីល្បីៗ រួមទាំងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីផងដែរ។

ក្នុងនោះ លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនក្នុងវេទិកា ស្តីពី "អនាគតនៃទ្វីបអាស៊ី" ក្រោមប្រធានបទ "ការប្រែប្រួលអាកាសធាតុ៖ តើទ្វីបអាស៊ីអាចសម្រេចបាននូវការបំភាយឧស្ម័នកខ្វក់ត្រឹមកម្រិតសូន្យដែរឬទេ?"។ លោកជំទាវ បានលើកឡើងពីគោលដៅអាកាសធាតុរបស់រដ្ឋាភិបាលកម្ពុជា តួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការសម្របសម្រួលលំហូរហិរញ្ញប្បទានប្រកបដោយចីរភាព និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុនៅតំបន់អាស៊ាន។ លោកជំទាវ ក៏បានលើកឡើងពីគំនិតផ្តួចផ្តើម "ការដោះដូរការវិនិយោគមូលបត្របំណុលប្រកបដោយចីរភាព (sustainability bond investment swap)" ដែលជាដំណោះស្រាយថ្មីមួយសម្រាប់កិច្ចសហប្រតិបត្តិការ និងបានសង្កត់ធ្ងន់លើតម្រូវការធនធាន ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុរបស់កម្ពុជា ដោយជំរុញឱ្យមានការគាំទ្រពីស្ថាប័នអន្តរជាតិសម្រាប់ប្រទេសដែលងាយរងគ្រោះ និងមានការបំភាយឧស្ម័នទាប ក្នុងការសម្របខ្លួនទៅនឹងបរិស្ថានអាកាសធាតុថ្មី។






លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានចូលរួមជាវាគ្មិនក្នុងវេទិកា ស្តីពី "អនាគតនៃទ្វីបអាស៊ី" ក្រោមប្រធានបទ "ការប្រែប្រួលអាកាសធាតុ៖ តើទ្វីបអាស៊ីអាចសម្រេចបាននូវការបំភាយឧស្ម័នកខ្វក់ត្រឹមកម្រិត សូន្យដែរឬទេ?" នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នាទីក្រុងតូក្យូ ប្រទេសជប៉ុន

## ៤.២.៤ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០២៤

វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា (CamTech) ប្រចាំឆ្នាំលើកទី៥ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា (CAFT) បានប្រព្រឹត្តទៅចំនួនពីរថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ **ក្រោមទស្សនាទាន "បច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់ទាំងអស់គ្នា៖ ផលប៉ះពាល់ និងនិរន្តរភាព"**។ វេទិកានេះមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានធនាគារ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ និងធុរកិច្ចថ្មី, សិស្សានុសិស្ស ព្រមទាំងសាធារណជន ដែលបានចូលរួមដោយផ្ទាល់ និងតាមរយៈបណ្ដាញសង្គមហ្វេសប៊ុក។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក CamTech បានវិវឌ្ឍន៍ខ្លួនទៅជាវេទិកាកំពូលមួយដែលរៀបចំឡើងក្នុងគោលបំណងផ្ដល់ការគាំទ្រ និងជំរុញដំណើរឆ្ពោះទៅកាន់ការរីកចម្រើន និរន្តរភាព បរិយាបន្ន ព្រមទាំងជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការពិភាក្សា និងការផ្លាស់ប្ដូរយោបល់ ចំណេះដឹង និងបទពិសោធន៍ ពីវាគ្មិននិងអ្នកជំនាញ ដោយឈរលើនិន្នាការថ្មីៗនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឆ្នាំនេះ បានផ្ដល់ជាកាលានុវត្តភាពដល់អ្នកចូលរួមក្នុងការពិភាក្សាអំពីការវិវត្តន៍ចុងក្រោយនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា និងក្នុងតំបន់។ ក្នុងនោះ ក៏បានបង្ហាញពីសុន្ទរកថាសំខាន់ៗដែលគួរឱ្យចាប់អារម្មណ៍ កិច្ចពិភាក្សាជាក្រុម ដែលជំរុញឱ្យមានការវែកញែកយ៉ាងផុសផុល និងមានជាសិក្ខាសាលាដែលរៀបចំឡើង ឱ្យអ្នកចូលរួមទទួលបាននូវចំណេះដឹង និងបទពិសោធន៍សំខាន់ៗ ដើម្បីរៀបចំអនាគតនៃហិរញ្ញវត្ថុឌីជីថល។ ប្រធានបទសំខាន់ៗក្នុងកិច្ចពិភាក្សា និងសិក្ខាសាលានោះរួមមាន ១/ការវិវត្តន៍នៃទិដ្ឋភាពហិរញ្ញវត្ថុឌីជីថលរបស់កម្ពុជា៖ ទិសដៅបច្ចុប្បន្ន និងអនាគត, ២/ការជំរុញឆ្ពោះទៅមុខ៖ យុទ្ធសាស្ត្រក្នុងការពន្លឿនកំណើនសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា, ៣/ការរួមបញ្ចូលគ្នានូវការអនុវត្តគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងការវិវត្តន៍ហិរញ្ញវត្ថុឌីជីថល, ៤/សហគ្រាសធុនតូចនិងមធ្យម និងការវិនិយោគដែលប៉ះពាល់ដល់សង្គម, ៥/ការកសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលមានភាពធន់៖ យុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធអេកូឡូស៊ី

ហិរញ្ញវត្ថុដែលរឹងមាំ,៦/ការផ្លាស់ប្តូរសេវាហិរញ្ញវត្ថុជាមួយបច្ចេកវិទ្យា, ៧/ការពង្រឹងសន្តិសុខសាយប័រក្នុងប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុឌីជីថលកម្ពុជា, ៨/ការការពារទិន្នន័យៈ ធានានូវទំនុកចិត្តលើសេវាហិរញ្ញវត្ថុនៅកម្ពុជា, ៩/បច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលមានភាពធន់, និង ១០/ការគ្រប់គ្រងទិន្នន័យដោយប្រើប្រាស់បច្ចេកវិទ្យា AI ជាដើម។ បន្ថែមលើការធ្វើបទបង្ហាញ និងកិច្ចពិភាក្សាខាងលើ ក៏មានជាកិច្ចប្រជុំចង្អៀតកម្រិតខ្ពស់ចំនួនពីរ ដែលផ្តល់ឱកាសដល់តួអង្គសំខាន់ៗក្នុងវិស័យនេះចូលរួមមតិ និងរួមចំណែកជំរុញការអនុវត្តដើម្បីទទួលបាននូវគោលដៅរួមគឺការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ក្នុងនោះកិច្ចប្រជុំទី១ ផ្តោតទៅលើការទប់ទល់នឹងហានិភ័យសាយប័រ និងទី២ ផ្តោតលើការបង្កើតមាតិកាដោយប្រើប្រាស់បច្ចេកវិទ្យា AI ។ កិច្ចពិភាក្សាទាំងនេះ បានប្រមូលផ្តុំដោយនិយតករ និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មសំខាន់ៗ ដើម្បីជំរុញកិច្ចសហការ និងកំណត់ជំហានបន្ទាប់ដែលអាចអនុវត្តបានសម្រាប់ការជំរុញការផ្លាស់ប្តូរ និងពង្រឹងប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុឌីជីថលរបស់ប្រទេសកម្ពុជា ឱ្យស្របទៅនឹងក្របខណ្ឌគោលនយោបាយនិងសង្គមឌីជីថលកម្ពុជា ដែលដាក់ចេញដោយរាជរដ្ឋាភិបាល។




វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា (CamTech) ក្រោមទស្សនាទាន "បច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់ទាំងអស់គ្នា៖ ផលប៉ះពាល់ និងនិរន្តរភាព" ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា កាលពីថ្ងៃទី១៨-១៩ ខែកញ្ញា ឆ្នាំ២០២៤ នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ

### ៤.២.៥ ពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech ឆ្នាំ២០២៤

នៅក្នុងដំណើរឆ្ពោះទៅរកការពង្រឹងវត្តមានលើឆាកអន្តរជាតិ ប្រទេសកម្ពុជា បានបង្ហាញខ្លួនជាលើកដំបូងក្នុងពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech ឆ្នាំ២០២៤ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣-៤ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង អមកិច្ចប្រជុំកំពូលប្រ៉្វង់កូហ្វូនឆ្នាំ២០២៤។ នៅក្នុងកម្មវិធីនោះ ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានដឹកនាំប្រតិភូធនាគារជាតិនៃកម្ពុជា ដាក់តាំងបង្ហាញប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ ស្របជាមួយនឹងផលិតផលរបស់កម្ពុជាមកពីស្ថាប័នដ៏ទៃចំនួន១៣ ផ្សេងទៀតផងដែរ។

ជាមួយគ្នានេះ ឯកឧត្តម ទេសាភិបាលរង ក៏បានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សាតុមូល ស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុប្រកបដោយចីរភាព ដោយសង្កត់ធ្ងន់លើការរួមចំណែករបស់ប្រព័ន្ធបាគងក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។




ថ្នាក់ដឹកនាំ និងមន្ត្រីធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងពិព័រណ៍ផលិតផលបច្ចេកវិទ្យា FrancoTech ឆ្នាំ២០២៤ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣-៤ ខែតុលា ឆ្នាំ២០២៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង

### ៤.២.៦ ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៤

ពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៤ ប្រារព្ធឡើងចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី ក្នុងគោលបំណងសិក្សាស្វែងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃការវិវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុជាសកល ក៏ដូចជាបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ក្នុងការជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។

ចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា ស្តីពី "កិច្ចគាំពារឆ្អឹងខ្នងនៃសេដ្ឋកិច្ច៖ ការជំរុញកំណើនសហគ្រាសធុនតូចនិងមធ្យមជាសកល តាមរយៈនវានុវត្តន៍ឌីជីថល" លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានលើកឡើងពីវឌ្ឍនភាព និងសសរស្តម្ភនៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងបានរំលេចពីតួនាទីកាន់តែសំខាន់របស់សហគ្រាសធុនតូចនិងមធ្យម (SMEs) ក្នុងការជំរុញកំណើនសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩។ ទន្ទឹមនេះ លោកជំទាវ ទេសាភិបាល ក៏បានលើកឡើងពីកត្តាប្រឈមដែល SMEs បាននិងកំពុងជួបប្រទះ ដូចជាលទ្ធភាពនៅមានកម្រិតក្នុងការទទួលបានហិរញ្ញប្បទាន និងសម្ពាធប្រកួតប្រជែងកាន់តែខ្លាំងក្នុងការពង្រីកប្រតិបត្តិការ ស្របពេលកំណើននៃវិស័យទេសចរណ៍នៅមានកម្រិតនៅឡើយ។

បន្ថែមលើនេះ លោកជំទាវ ទេសាភិបាល ក៏បានបង្ហាញពីគំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការអភិវឌ្ឍ SMEs ដូចជាការលើកកម្ពស់បរិយាកាសធុរកិច្ច ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានសមស្រប និងកិច្ចសហប្រតិបត្តិការល្អប្រសើរក្នុងការអភិវឌ្ឍ និងតភ្ជាប់ប្រព័ន្ធទូទាត់កម្ពុជា ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។










លោកជំទាវ បណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា
ស្តីពី "កិច្ចគាំពារឆ្អឹងខ្នងនៃសេដ្ឋកិច្ច៖ ការជំរុញកំណើនសហគ្រាសធុនតូចនិងមធ្យមជាសកល តាមរយៈនវានុវត្តន៍ឌីជីថល"
ក្នុងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរីឆ្នាំ២០២៤ នាថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅប្រទេសសិង្ហបុរី

# ៥ ការគ្រប់គ្រងសេវាទូទាត់សងប្រាក់

## ៥.១. និន្នាការទូទៅ និងការវិវត្ត

សេវាទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយទិន្នន័យអតិថិជនចុះឈ្មោះបង្កើតគណនីកាបូបអេឡិចត្រូនិក (E-wallet) សរុបបានកើនឡើងដល់ប្រមាណ ២០,៧ លានគណនី ពោលគឺកើនឡើង ៥,៦% ធៀបនឹងឆ្នាំ២០២៣។ ជាមួយនឹងការកើនឡើងនៃការប្រើប្រាស់ស្មាតហ្វូន និងលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ការធ្វើប្រតិបត្តិការតាមរយៈឌីជីថលដោយផ្ទាល់ពេញនិយមជាងប្រតិបត្តិការតាមបញ្ជរភ្នាក់ងារ ដែលជាហេតុនាំឱ្យមានការថយចុះនៃចំនួនភ្នាក់ងារចំនួន ៣,៩% (ប្រមាណ ៥៨,១ ពាន់ទីតាំង) ធៀបនឹងឆ្នាំ២០២៣។ រីឯចំនួនប្រតិបត្តិការសរុបនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិកនៅក្នុងឆ្នាំ២០២៤ មានការកើនឡើងប្រមាណ ៩៩,៣% ពី ៦០១,៣ ទៅ ១.១៩៨,៣ លានប្រតិបត្តិការ និងទំហំប្រាក់កើនឡើងប្រមាណ ៥៣,១% ពី ៧៥,៨ ទៅ ១១៦,១ ប៊ីលានដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០២៣ ប្រមាណ ២៥៤,២% នៃផ.ស.ស។

**ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះគណនី E-wallet និងអតិថិជន Walk-in របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័ត តាមកាបូបអេឡិចត្រូនិក (Mobile E-wallet)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងឆ្នាំ២០២៤នេះ ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយមានចំនួនប្រមាណ ៥៧៥,៥ លានដុល្លារអាមេរិក។ ចំណែកឯ សមតុល្យដែលបានរក្សាទុកក្នុងគណនីអាណត្តិព្យាបាល[១]បានកើនឡើងដល់ប្រមាណ ៥៨១,៣ លានដុល្លារអាមេរិក កើនពី ៤៤៣ លានដុល្លារអាមេរិកកាលពីឆ្នាំ២០២៣។ ការកើនឡើងនេះ បានបង្ហាញពីទំនុកចិត្តរបស់អ្នកប្រើប្រាស់លើសេវាទូទាត់សងប្រាក់តាមបែបឌីជីថល និងក្របខណ្ឌបទប្បញ្ញត្តិដែលគាំទ្រប្រតិបត្តិការទាំងនេះ ដោយធានាថាមូលនិធិរបស់អ្នកប្រើប្រាស់ត្រូវបានការពារប្រកបដោយប្រសិទ្ធភាព។

**ក្រាហ្វ ១៥ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

(១) គណនីអាណត្តិព្យាបាល សំដៅដល់គណនីដែលបើកដោយអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក នៅពេលទទួលសាច់ប្រាក់ពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ រក្សាទុកក្នុងធនាគារអាណត្តិព្យាបាលមួយ ឬច្រើន ក្នុងគោលបំណងធ្វើប្រតិបត្តិការទូទាត់សងប្រាក់តែមួយគត់ ដែលបញ្ជាដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងមិនត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកឡើយ។

មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥០ គ្រឹះស្ថាន ផ្តល់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត ហើយអ្នកចុះឈ្មោះប្រើប្រាស់អាចធ្វើប្រតិបត្តិការសេវាធនាគារផ្សេងៗ ក្នុងនោះចំនួនប្រតិបត្តិការតាមរយៈសេវាធនាគារអ៊ីនធឺណិតក្នុងឆ្នាំ២០២៤ មានការកើនឡើងប្រមាណ ១២៦,៧% ពី ៤,៧ ទៅ ១០,៧ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើងប្រមាណ ៥៥,៦% ពី ១៨,២ ទៅ ២៨,៣ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៦២% នៃផ.ស.ស។ ចំណែកឯ ចំនួនប្រតិបត្តិការរបស់សេវាធនាគារចល័តមានការកើនឡើងប្រមាណ ៥១,៥% ពី ៧៧៩,៥ ទៅ ១.១៨០,៥ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើងប្រមាណ ១៧,៤% ពី ១៨២,២ ទៅ ២១៣,៨ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៤៦៨,២% នៃផ.ស.ស។ អត្រាកំណើនសម្រាប់ប្រតិបត្តិការខាងលើនេះ បានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរឥរិយាបថអ្នកប្រើប្រាស់ឆ្ពោះទៅរកមធ្យោបាយធនាគារឌីជីថល។

**ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការទូទាត់ប្រាក់តាមប័ណ្ណទូទាត់កាន់តែមានភាពទូលំទូលាយ ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤០ គ្រឹះស្ថាន បានចេញផ្សាយប័ណ្ណទូទាត់ចំនួនប្រមាណ ១២,៧ លានប័ណ្ណ។ ក្នុងឆ្នាំ២០២៤ ប្រតិបត្តិការទូទាត់តាមប័ណ្ណទូទាត់ជារូបវន្តក្នុងស្រុកសរុប មានការថយចុះប្រមាណ ២,២% ពី ១៥០,៧ មកត្រឹម ១៤៧,៤ លានប្រតិបត្តិការ ក្នុងទំហំប្រាក់ ២៦,៨ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៥៨,៨% នៃផ.ស.ស។ ដោយឡែក ចំនួនប្រតិបត្តិការប័ណ្ណទូទាត់ជារូបវន្តនៅក្រៅប្រទេសមានការ

កើនឡើងប្រមាណ ៩,៥% ពី ២,៨ ទៅ ៣,១ លានប្រតិបត្តិការ និងក្នុងទំហំប្រាក់ ១,១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ២,៥% នៃផ.ស.ស។ ចំណែកឯប្រតិបត្តិការប័ណ្ណទូទាត់តាមអនឡាញសរុបមានការកើនឡើងប្រមាណ ២២,៣% ពី ២៧,៩ ទៅ ៣៤,១ លានប្រតិបត្តិការ និងទំហំប្រាក់មានការកើនឡើងប្រមាណ ៤៣,៥% ពី ១ ទៅ ១,៥ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៣,២% នៃផ.ស.ស។

គិតត្រឹមឆ្នាំ២០២៤ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤០ គ្រឹះស្ថាន បានតម្លើងម៉ាស៊ីន ATM ចំនួន ៥,៧ ពាន់គ្រឿង និង ៣០ គ្រឹះស្ថានបានតម្លើងម៉ាស៊ីន POS ចំនួន ៥៣,៦ ពាន់គ្រឿង នៅទូទាំងប្រទេសកម្ពុជា ដែលជួយសម្រួលដល់លទ្ធភាពទទួលបានសាច់ប្រាក់កាន់តែងាយស្រួល និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធទូទាត់ទាំងមូល។

**ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM និងម៉ាស៊ីន POS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការទូទាត់តាមឃ្យូអរកូតនៅតែទទួលបានការពេញនិយម និងទាក់ទាញ ដែលជាមធ្យោបាយទូទាត់ប្រាក់ងាយស្រួល និងសុវត្ថិភាព។ ចំនួនប្រតិបត្តិការទូទាត់តាមឃ្យូអរកូតបានកើនឡើង ២៥២,៦% ធៀបនឹងឆ្នាំ២០២៣ ក្នុងទំហំប្រាក់សរុបចំនួន ៥៥,៨ ប៊ីលានដុល្លារអាមេរិក ប្រមាណ ១២៤% នៃផ.ស.ស។ ការណ៍នេះ បានបង្ហាញពីការពេញនិយមប្រើប្រាស់ពីពាណិជ្ជករទូទាត់វាយ និងអ្នកប្រើប្រាស់ ដោយសារតែការទូទាត់មានភាពសាមញ្ញ និងរហ័ស ដែលជាជម្រើសដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់ប្រតិបត្តិការទូទាត់ប្រចាំថ្ងៃ។

**ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥.២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ការកើនឡើងនៃចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងប្រតិបត្តិការទូទាត់សងប្រាក់ទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្មក្របខណ្ឌគតិយុត្ត ក្នុងគោលដៅបង្កលក្ខណៈងាយស្រួលដល់ការរីកចម្រើន ក៏ដូចជាគ្រប់គ្រងហានិភ័យថ្មីៗឱ្យមានប្រសិទ្ធភាព។ ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវក្របខណ្ឌបទប្បញ្ញត្តិសំខាន់ៗមួយចំនួនដែលមានភាពចាំបាច់ដូចជា សេចក្តីណែនាំស្តីពី "ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា" (ខែមីនា ឆ្នាំ២០២៤) ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីអនុវត្តនិងប្រតិបត្តិតាម ក្នុងគោលបំណងលើកកម្ពស់ការទូទាត់ជាប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្ន។

បន្ថែមពីនេះ កាលពីខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំ សេចក្តីណែនាំស្តីពី "ការកែសម្រួលកាលបរិច្ឆេទ និងរយៈពេលបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" ក្នុងគោលបំណងណែនាំ និងតម្រូវឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បញ្ជូនរបាយការណ៍

តាមកាលបរិច្ឆេទកំណត់ឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពជាងមុន និងទាន់ពេលវេលាកំណត់ក៏ដូចជាឱ្យស្របនឹងការអនុវត្តការងារជាក់ស្តែង។ ចំពោះ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ដែលធនាគារជាតិនៃកម្ពុជាបានអនុម័តកន្លងមក មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។ ក្នុងគោលបំណងគ្រប់គ្រងប្រតិបត្តិការ និងអាជីវកម្មពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យប្រើប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងគ្រីបតូ។

ដោយសារការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យាសេវាទូទាត់សងប្រាក់នៅកម្ពុជាចាំបាច់តម្រូវឱ្យមានការដាក់ចេញនូវក្របខណ្ឌបទប្បញ្ញត្តិថ្មីៗ។ ក្នុងគោលដៅលើកកម្ពស់ប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយស្ថិរភាព និងប្រសិទ្ធភាព ធានាការការពារអ្នកប្រើប្រាស់ និងការជំរុញនវានុវត្តន៍សេវាហិរញ្ញវត្ថុឌីជីថល ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិថ្មីៗបន្ថែមទៀត ដូចជា ការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល នីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ និងប្រតិបត្តិករទីផ្សារវេណទានតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៥.៣. ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ការរៀបចំក្របខណ្ឌគ្រប់គ្រងសេវាទូទាត់សងប្រាក់ធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព តម្លាភាព ជំរុញការប្រកួតប្រជែង លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងផ្តល់ទំនុកចិត្តដល់សាធារណជន។ ធនាគារជាតិនៃកម្ពុជាមានតួនាទីក្នុងការផ្តល់អាជ្ញាប័ណ្ណ ធ្វើនិយ័តកម្ម និងត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្រោមប្រកាសស្តីពី "ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់" ចេញផ្សាយនៅឆ្នាំ។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានចំនួនសរុប ២៩ គ្រឹះស្ថាន និងមានគ្រឹះស្ថានធនាគារចំនួន ៣ គ្រឹះស្ថានដែលទទួលបានលិខិតអនុញ្ញាត។ ធនាគារជាតិនៃកម្ពុជា បន្តត្រួតពិនិត្យជាប្រចាំលើគ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ដោយផ្តោតលើវិធីសាស្ត្រត្រួតពិនិត្យលើហានិភ័យ (Risk-based Approach) ក៏ដូចជាការត្រួតពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ (Compliance-based Approach) សំដៅកាត់បន្ថយហានិភ័យ និងធានាបានសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យ ផ្តោតសំខាន់ទៅលើសូចនាករចម្បងៗដូចខាងក្រោម៖

- **អភិបាលកិច្ច និងការត្រួតពិនិត្យផ្ទៃក្នុង៖** ជាការវាយតម្លៃទៅលើប្រសិទ្ធភាពនៃរចនាសម្ព័ន្ធការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំគ្រឹះស្ថាន ក៏ដូចជាការដាក់ចេញនូវគោលនយោបាយសំខាន់ៗ

សម្រាប់ដំណើរការគ្រឹះស្ថាន ការគ្រប់គ្រងហានិភ័យ ការអនុវត្តតាមបទប្បញ្ញត្តិ និងសេចក្ដីណែនាំផ្សេងៗរបស់ធនាគារជាតិនៃកម្ពុជា។

- **ហានិភ័យឥណទាន៖** ជាការវាយតម្លៃលើប្រសិទ្ធភាពនៃហានិភ័យឥណទាន ក្នុងការចាត់វិធានការ និងនីតិវិធីសំខាន់ៗនៅក្នុងការគ្រប់គ្រងហានិភ័យ ជាពិសេសចំពោះការគ្រប់គ្រង និងការរក្សាសុវត្ថិភាពគណនីអាណត្តិព្យាបាលដែលមានមូលនិធិរបស់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់។
- **ហានិភ័យសន្ទនីយភាព៖** ជាការវាយតម្លៃផ្ដោតសំខាន់លើការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថាន និងការពិនិត្យអំពីប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់រវាងគណនីអាណត្តិព្យាបាល និងគណនីរូបិយវត្ថុអេឡិចត្រូនិក ដើម្បីធានាថាគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់មានសន្ទនីយភាពគ្រប់គ្រាន់។
- **ហានិភ័យប្រតិបត្តិការ៖** ជាការវាយតម្លៃ ផ្ដោតទៅលើគុណភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថាន ដូចជាការរក្សាប្រព័ន្ធផ្ទុកទិន្នន័យ ដំណើរការប្រព័ន្ធសុវត្ថិភាពព័ត៌មាន ក៏ដូចជាការពិនិត្យលើបញ្ហាមួយចំនួនរួមមាន ការទប់ស្កាត់ប្រតិបត្តិការក្លែងបន្លំ និងការវាយប្រហារសាយប័រ (Cyber-Attack) ជាដើម ដើម្បីទប់ស្កាត់មិនឱ្យមានការរាំងស្ទះដល់ដំណើរការជាប្រចាំរបស់គ្រឹះស្ថាន និងដោះស្រាយបានទាន់ពេលវេលា។
- **ហានិភ័យការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖** ជាការវាយតម្លៃលើយន្តការ និងនីតិវិធីក្នុងការបង្ការប្រតិបត្តិការដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងការអនុវត្តនិតិវិធីស្គាល់អតិថិជន (KYC)។
- **យន្តការការពារផលប្រយោជន៍អតិថិជន៖** ជាការវាយតម្លៃលើគោលបំណងពិនិត្យលើការដាក់ចេញនូវគោលការណ៍ និងយន្តការសំខាន់ៗដូចជា សេចក្ដីណែនាំអំពីការប្រើប្រាស់សេវា ការផ្ដល់ព័ត៌មានបានទូលំទូលាយដល់អតិថិជន និងការដាក់ចេញនូវវិធានការក្នុងការដោះស្រាយបណ្ដឹងជូនអតិថិជន។
- **លទ្ធភាពស្វែងរកប្រាក់ចំណេញ៖** ជាការវាយតម្លៃទៅលើលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញដោយផ្ដោតលើការដាក់ចេញនូវយន្តការថ្មីទៅលើផលិតផល និងសេវា ដើម្បីទាក់ទាញការប្រើប្រាស់ពីអតិថិជន និងការពិនិត្យលើស្ថានភាពសេដ្ឋកិច្ចដែលអាចជះឥទ្ធិពលទៅលទ្ធភាពរកប្រាក់ចំណូលរបស់គ្រឹះស្ថាន។
- **ភាពគ្រប់គ្រាន់នៃដើមទុន៖** ជាការវាយតម្លៃលើភាពលទ្ធភាពនៃដើមទុន ដើម្បីធានាភាពរឹងមាំនៃគណនីដើមទុន ការទប់ស្កាត់នូវការខាតបង់ផ្នែកគណនេយ្យ និងធានានិរន្តរភាពប្រតិបត្តិការដែលនឹងផ្ដល់ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់មកលើគ្រឹះស្ថាន។

## ៥.៤. ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវធ្វើឡើងជាប្រចាំ តាមរយៈការប្រមូលរបាយការណ៍ប្រតិបត្តិការជាប្រចាំខែ និងជាប្រចាំឆ្នាំ រួចធ្វើការវិភាគទិន្នន័យហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ដើម្បីធានាភាពត្រឹមត្រូវ និងពង្រឹងគុណភាពប្រតិបត្តិការរបស់គ្រឹះស្ថានឱ្យមានសុខុមាលភាពល្អប្រសើរ។ បន្ថែមពីនេះ ការត្រួតពិនិត្យមានការបែងចែកជាពីរប្រភេទដូចជា ការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។

**ក. ការត្រួតពិនិត្យលើឯកសារ**

ការត្រួតពិនិត្យលើឯកសារ ជាការពិនិត្យ សិក្សា និងវាយតម្លៃលើសំណុំឯកសារស្នើសុំរបស់គ្រឹះស្ថាន និងវិភាគលើរបាយការណ៍ប្រតិបត្តិការ និងព័ត៌មានហិរញ្ញវត្ថុដែលគ្រឹះស្ថានផ្ញើជាប្រចាំមកធនាគារជាតិនៃកម្ពុជា។

**ខ. ការត្រួតពិនិត្យដល់ទីកន្លែង**

ការត្រួតពិនិត្យដល់ទីកន្លែង សំដៅលើការចុះត្រួតពិនិត្យដល់ទីស្នាក់ការរបស់គ្រឹះស្ថានផ្ទាល់ជាប្រចាំគ្រានៅតាមទីស្នាក់ការកណ្តាលរបស់គ្រឹះស្ថាន និងភ្នាក់ងារផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីពិនិត្យពីស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថាន ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យ និងការអនុវត្តតាមបទប្បញ្ញត្តិដែលមានជាធរមាន។ នៅក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងភ្នាក់ងារនៅតាមបណ្តាខេត្ត សរុបចំនួន ០៨ គ្រឹះស្ថាន រួមមាន ៖

១. គ្រឹះស្ថាន ផានស៊ី អ៊ិនធើណេសិនណល ថេកណឡជី ម.ក

២. គ្រឹះស្ថាន លីន ផេ ផេម៉ិន សឹល្យូសិន ម.ក

៣. គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក

៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

៥. គ្រឹះស្ថាន ដ្រាហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក

៦. គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក

៧. ធនាគារ ជីប ម៉ុង ខមមើសលប៊ែង ម.ក

៨. គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក

# ៦ ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

## ៦.១. កិច្ចសហប្រតិបត្តិការទ្វេភាគី លើគម្រោងផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន

ការទូទាត់និងផ្ទេរប្រាក់ឆ្លងដែន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក និងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំរុញវិស័យទេសចរណ៍ ព្រមទាំងរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់ជាមធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់ទំនិញដែលមានកម្រៃទាបសម្រាប់ពលករទេសន្តរប្រវេសន៍ និងធុរកិច្ចជន។ ក្នុងគោលបំណង ពង្រឹងកិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ និងក្រុមហ៊ុនអាលីផេ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រីកគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសផ្សេងទៀតក្នុងតំបន់ និងដៃគូសហការនានា ដូចជា ប្រទេសចិន ឥណ្ឌា សិង្ហបុរី ជប៉ុន និងហ្វីលីពីន។ ក្រៅពីគម្រោងទូទាត់ឆ្លងដែន ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការ និងចុះអនុស្សរណៈយោគយល់គ្នាលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសចំនួនបួនផ្សេងទៀត រួមមាន ប្រទេសរវ៉ាន់ដា ហ្វីជី កោះសូឡូម៉ូន និងប្រទេសទីម័រឡេស៍។



## ក. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសម៉ាឡេស៊ី




គម្រោងផ្ទេរប្រាក់ឆ្លងដែននេះ ត្រូវបានដាក់ឱ្យដំណើរការ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ សម្រាប់ការផ្ទេរប្រាក់រវាងប្រព័ន្ធបាគងជាមួយកម្មវិធីធនាគារចល័ត និងនៅតាមបញ្ជររបស់ធនាគារមេយប៊ែង។ ទន្ទឹមនឹងនេះ ធនាគារកម្ពុជាសាធារណៈ ក៏បានដាក់ឱ្យដំណើរការការផ្ទេរប្រាក់មកអតិថិជនដែលមានគណនីបាគង កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២។

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាឡេស៊ី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" កាលពីខែកុម្ភៈ ឆ្នាំ២០២៤ ដោយគម្រោងទូទាត់ឆ្លងដែននេះត្រូវបានចែកចេញជាពីរដំណាក់កាល។ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង ឯកឧត្តម Dato' Seri Abdul Rasheed Ghaffour ទេសាភិបាល ធនាគារកណ្តាលម៉ាឡេស៊ី បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនតាមយូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ដែលគម្រោងនេះ នឹងផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ និងពាណិជ្ជករទទួលបាននូវបទពិសោធន៍ទូទាត់ប្រកបដោយប្រសិទ្ធភាព ងាយស្រួល សុវត្ថិភាព ឆាប់រហ័ស និងតម្លៃសមរម្យ។

## ខ. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ



ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃបានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩។ កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមយូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសថៃ បានដាក់ឱ្យដំណើរការដោយជោគជ័យនូវដំណាក់កាលទី១ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និងដំណាក់កាលទី២ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៣។ គម្រោងទូទាត់នេះ អនុញ្ញាតឱ្យប្រជាជនទាំងពីរ អាចទូទាត់គ្នាទៅវិញទៅមកតាមយូអរកូតបានយ៉ាងងាយស្រួល សុវត្ថិភាព ប្រសិទ្ធភាព និងតម្លៃសមរម្យ។ សម្រាប់ជំហានបន្ទាប់ ក្រុមការងារបច្ចេកទេសធនាគារកណ្តាល ទាំងពីរ កំពុងសិក្សាលទ្ធភាពក្នុងការជំរុញកិច្ចសហប្រតិបត្តិការផ្ទេរប្រាក់រវាងប្រទេសកម្ពុជា និងប្រទេសថៃ។

## ប្រអប់ ៤ - លំហូរប្រតិបត្តិការនៃការទូទាត់របស់ភ្ញៀវទេសចរថៃនៅក្នុងប្រទេសកម្ពុជា




### ពន្យល់រូបភាពទី១៖

១. លោក SawaDee ដែលជាទេសចរថៃ បានមកកម្សាន្តនៅប្រទេសកម្ពុជា ហើយបានចូល ពិសារគុយទាវនៅហាងគុយទាវឆ្ងាញ់។ លោក SawaDee បានទូទាត់ថ្លៃគុយទាវ ចំនួន១ម៉ឺនរៀល ដោយបានប្រើកម្មវិធីទូទាត់របស់ធនាគារ KrungThai ក្នុងទូរស័ព្ទរបស់គាត់ ហើយធ្វើការស្កេនលើ KHQR code របស់ហាងគុយទាវឆ្ងាញ់ដើម្បីទូទាត់។

២. នៅពេលដែលលោក SawaDee ស្កេន KHQR code រួច ប្រតិបត្តិការត្រូវបានបញ្ជូនទៅធនាគាររបស់លោក SawaDee នៅប្រទេសថៃ។ ធនាគារ KrungThai នៅប្រទេសថៃបានដកប្រាក់បាតថៃពីគណនីរបស់លោកនៅប្រទេសថៃ នូវចំនួនប្រាក់សមមូលនឹង ១ម៉ឺនរៀល តាមអត្រាប្តូរប្រាក់ទីផ្សាររបស់ធនាគារ ហើយបង្វែរប្រាក់នោះទៅធនាគារ (អេស៊ីលីដា) របស់ម្ចាស់ហាងគុយទាវឆ្ងាញ់នៅប្រទេសកម្ពុជា។

៣. បន្ទាប់ពីទទួលបានប្រាក់ពីធនាគារនៅប្រទេសថៃរួចមក ធនាគារនៅប្រទេសកម្ពុជា បានផ្ទេរប្រាក់ចំនួន១ម៉ឺនរៀលទៅក្នុងគណនីម្ចាស់ហាងគុយទាវឆ្ងាញ់ ជាកិច្ចបញ្ចប់ប្រតិបត្តិការ។

## ប្រអប់ ៥ - លំហូរប្រតិបត្តិការនៃការទូទាត់របស់ភ្ញៀវទេសចរកម្ពុជានៅក្នុងប្រទេសថៃ




**ពន្យល់រូបភាពទី២៖**

១. លោក វិបុល ដែលជាទេសចរកម្ពុជា បានទៅកំសាន្តនៅប្រទេសថៃ ហើយបានចូលទិញបុកល្ហុងនៅហាង SomTum ។ លោក វិបុល បានទូទាត់ថ្លៃបុកល្ហុង ចំនួន១០០បាត ដោយបានប្រើកម្មវិធីទូទាត់ Bakong ក្នុងទូរស័ព្ទរបស់គាត់ ស្កេនលើ ThaiQR code របស់ហាង SomTum ។

២. នៅពេលដែលលោក វិបុល ស្កេន QR code រួច ប្រតិបត្តិការត្រូវបានបញ្ជូនទៅធនាគាររបស់លោក វិបុល នៅប្រទេសកម្ពុជា។ ធនាគារនៅប្រទេសកម្ពុជា បានដកប្រាក់រៀលពីគណនីរបស់លោកវិបុល នូវចំនួនប្រាក់សមមូលនឹង ១០០បាត តាមអត្រាប្តូរប្រាក់ទីផ្សាររបស់ធនាគារ ហើយបង្វែរប្រាក់នោះទៅធនាគាររបស់ម្ចាស់ហាង SomTum នៅប្រទេសថៃ។

៣. បន្ទាប់ពីទទួលបានប្រាក់ពីធនាគារនៅប្រទេសកម្ពុជារួចមក ធនាគារនៅប្រទេសថៃ បានផ្ទេរប្រាក់ចំនួន១០០បាត ទៅក្នុងគណនីម្ចាស់ហាង SomTum ជាកិច្ចបញ្ចប់ប្រតិបត្តិការ។

## គ. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសឡាវ




គម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសឡាវ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ សម្រាប់អតិថិជនប្រទេសកម្ពុជាអាចធ្វើការទូទាត់ដោយការស្កេនឃ្យូអរកូតនៅប្រទេសឡាវ។ ចំពោះអតិថិជនប្រទេសឡាវ អាចធ្វើការទូទាត់ដោយការស្កេនឃ្យូអរកូតនៅប្រទេសកម្ពុជា គ្រោងនឹងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៥។ កិច្ចសហការនេះ ស្របគ្នានឹងគោលបំណងនៃសហគមអាស៊ានក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចកាន់តែជិតស្និត រវាងប្រទេសកម្ពុជា និងប្រទេសឡាវ ដែលនឹងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ និងអាចឱ្យប្រទេសទាំងពីរឈានដល់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុមួយកម្រិតក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីជាប្រយោជន៍ដល់ប្រជាជនក្នុងប្រទេសទាំងពីរ។

## ឃ. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសវៀតណាម



ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលវៀតណាមបានចុះអនុស្សរណៈយោគយល់គ្នា កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២២ ធនាគារអេស៊ីលីដា ត្រូវបានតែងតាំងជាធនាគារទំនាក់ទំនង (តំណភ្ជាប់បច្ចេកទេស) សម្រាប់ប្រទេសកម្ពុជា និងប្រតិបត្តិករ NAPAS ជាប្រតិបត្តិករតភ្ជាប់បច្ចេកទេស និងធនាគារ BIDV ជាធនាគារទូទាត់នៅខាងភាគីវៀតណាម។ រីឯភាគីខាងវៀតណាម បានជ្រើសរើសប្រតិបត្តិករប្រព័ន្ធទូទាត់សងប្រាក់ NAPAS ទទួលបន្ទុកផ្នែកបច្ចេកទេស និងមានធនាគារដៃគូចំនួន ២ ចូលរួមគឺ TP bank និង BIDV bank។ គម្រោងទូទាត់ឆ្លងដែនតាមរយៈ QR Code រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣ ដោយប្រជាជនកម្ពុជាដែលមានគណនីជាប្រាក់រៀលអាចប្រើប្រាស់កម្មវិធីធនាគារចល័ត ដើម្បីធ្វើការទូទាត់ប្រាក់ តាមរយៈការស្កេនឃ្យូអរកូត (VIETQR) របស់ពាណិជ្ជករ ឬហាងទំនិញនៅប្រទេសវៀតណាម។ ហើយប្រជាជនវៀតណាម ដែលមានគណនីជាប្រាក់ដុងវៀតណាម អាចធ្វើការទូទាត់ប្រាក់ដោយការស្កេនខេអេចឃ្យូអរកូត (KHQR Code) របស់ពាណិជ្ជករ ឬហាងទំនិញនៅក្នុងប្រទេសកម្ពុជា។

## ង. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសកូរ៉េខាងត្បូង





ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូត" ចំនួនបីដាច់ដោយឡែកពីគ្នា។ អនុស្សរណៈទី១ ធ្វើឡើងជាមួយធនាគារគូកមីន (Kookmin Bank Co., Ltd.) ទី២ ជាមួយស្ថាប័ន JB Financial Group Co., Ltd និងទី៣ ជាមួយធនាគារអ៊ូរី (Woori Bank)។ ពិធីចុះហត្ថលេខាលើអនុស្សរណៈទាំង៣ ខាងលើ ត្រូវបានប្រារព្ធឡើងនៅក្នុងរបៀបវារៈនៃវេទិកាធុរកិច្ចកម្ពុជា-កូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចធិបតី** នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៥-១៨ ខែឧសភា ឆ្នាំ២០២៤។ គម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការតាមឃ្យូអរកូត (QR Code) ដំណាក់កាលទី១ (ភ្ញៀវទេសចរមកពីសាធារណរដ្ឋកូរ៉េប្រើប្រាស់កម្មវិធីធនាគារចល័តរបស់ធនាគារ Jeonbuk កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ដើម្បីទូទាត់ផ្ទាល់នៅតាមហាងទំនិញដែលមានស្លាកសញ្ញាខេអេចឃ្យូអរកូត គណនីប្រាក់រៀល) រវាងសាធារណរដ្ឋកូរ៉េ និងព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា លោក KIM Tae Hyun នាយកប្រតិបត្តិរងនៃធនាគារ Jeonbuk និងលោក LEE Jin Young នាយកប្រតិបត្តិនៃធនាគារភ្នំពេញពាណិជ្ជ ម.ក** នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ច. គម្រោងទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុន UnionPay International

ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអន្តរជាតិយូញៀនផេ បានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់" កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៃការទូទាត់ឆ្លងដែនតាមឃ្យូអរកូត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣។ គម្រោងទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូតនេះ ជាសមិទ្ធផលថ្មីមួយទៀតនៃចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូតរបស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយ។




តាមរយៈក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះ អតិថិជនរបស់ក្រុមហ៊ុនអន្តរជាតិយូញៀនផេ អាចស្កេនខេអេច-ឃ្យូអរកូត ដើម្បីទូទាត់ថ្លៃទំនិញ-សេវា ទៅឱ្យអាជីវករ ឬម្ចាស់ហាងលក់ទំនិញ-សេវានៅកម្ពុជាដែលមានគណនីជាប្រាក់រៀលបាន។ នៅដើមឆ្នាំ២០២៤ ប្រជាជនកម្ពុជាក៏អាចប្រើប្រាស់ប្រាក់រៀលក្នុងប្រព័ន្ធបាគង ឬកម្មវិធីធនាគារចល័ត ដើម្បីទូទាត់ថ្លៃទំនិញ-សេវា នៅក្នុងប្រទេសចិន និងបណ្តាប្រទេសផ្សេងៗទៀតក្នុងបណ្តាញទូទាត់អន្តរជាតិយូញៀនផេ នៅទូទាំងពិភពលោកដោយគ្រាន់តែស្កេនឃ្យូអរកូតរបស់ក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UnionPay QR Code)។

### ឆ. គម្រោងទូទាត់ឆ្លងដែនជាមួយក្រុមហ៊ុន Alipay Connect Pte., Ltd

ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអាលីផេ (Alipay Connect Pte. Ltd.) បានចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមឃ្យូអរកូត" កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Ant International បានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនតាមឃ្យូអរកូត (QR Code) រវាងប្រព័ន្ធទូទាត់បាគង (Bakong) របស់ធនាគារជាតិនៃកម្ពុជា និងបណ្តាញទូទាត់ពិភពលោក Alipay+ របស់ក្រុមហ៊ុន Ant International នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ការដាក់ឱ្យដំណើរការនេះ ជាសមិទ្ធផលថ្មីមួយនៃចក្ខុវិស័យពង្រីកវិសាលភាពប្រតិបត្តិការទូទាត់ឆ្លងដែន តាមឃ្យូអរកូតរបស់ប្រព័ន្ធបាគង។ តាមរយៈក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះ អតិថិជនរបស់ក្រុមហ៊ុន Alipay អាចស្កេន KHQR Code ដើម្បីទូទាត់ថ្លៃទំនិញ និងសេវាកម្ម ទៅឱ្យអាជីវករនៅកម្ពុជាជាប្រាក់រៀលដោយស្វ័យប្រវត្តិ។






## ជ. គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសហ្វីលីពីន

ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្ដាលហ្វីលីពីនបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាកាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។ អនុស្សរណៈយោគយល់នេះ ធ្វើឡើងក្នុងគោលបំណងផ្ដល់នូវក្របខណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និត និងសម្រួលដល់កិច្ចសហការវាងភាគីទាំងពីរ ជាពិសេសគម្រោងទូទាត់ឆ្លងដែន។

### ប្រអប់ ៦ - ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្ដាល Lesotho

ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យគណៈប្រតិភូធនាគារកណ្ដាល Lesotho មកធ្វើទស្សនកិច្ចសិក្សាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ នៅធនាគារជាតិនៃកម្ពុជា រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤។ ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្ដាលនៃប្រទេសឡេសូថូ ធ្វើឡើងក្នុងគោលបំណងសិក្សាស្វែងយល់ពីហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា លំហូរប្រតិបត្តិការជាពិសេសផ្នែកបច្ចេកវិទ្យា និងក្របខណ្ឌគតិយុត្ត ដែលជំរុញឱ្យប្រតិបត្តិការទូទាត់អន្តរ-គ្រឹះស្ថានរីកចម្រើនកាន់តែប្រសើរ និងប្រកបដោយបរិយាបន្ន។





## ៦.២. ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

សេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែនដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងជាពិសេសចូលរួមចំណែកលើកស្ទួយជីវភាពនិងសម្រួលដល់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅនិងធ្វើការនៅក្រៅប្រទេសអាចផ្ញើប្រាក់មកឱ្យក្រុមគ្រួសារបានងាយស្រួល រហ័ស ចំណាយតិច និងមានសុវត្ថិភាព។ ដើម្បីធានានិរន្តរភាព និងតម្លាភាពនៃសេវាទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន ព្រមទាំងផ្តល់ការការពារអ្នកប្រើប្រាស់ឱ្យមានសុវត្ថិភាព ធនាគារជាតិនៃកម្ពុជាតែងតែយកចិត្តទុកដាក់ខ្ពស់លើការដាក់ចេញនិងពង្រឹងច្បាប់និងបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងការគាំទ្រកិច្ចផ្តួចផ្តើមថ្មីៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុលើការលើកកម្ពស់បណ្តាញផ្ទេរប្រាក់ផ្លូវការស្របតាមគោលដៅរបស់ធនាគារជាតិនៃកម្ពុជាក្នុងការពង្រីកបរិយាបន្នហិរញ្ញវត្ថុ។

ដើម្បីធានាឱ្យបាននូវភាពរឹងមាំនៃសេវាទូទាត់និងផ្ទេរប្រាក់ឆ្លងដែនដែលវិវត្តន៍យ៉ាងឆាប់រហ័ស និងគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យបន្តយកចិត្តទុកដាក់ខ្ពស់លើការសិក្សានិងដាក់ចេញបទប្បញ្ញត្តិថ្មីៗ ពិនិត្យជាប្រចាំលើការអនុវត្តតាមរបស់គ្រឹះស្ថានឱ្យស្របតាមច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ និងតាមដានស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានទាំងនោះតាមរយៈការត្រួតពិនិត្យលើរបាយការណ៍ដែលគ្រឹះស្ថានផ្តល់ជូនធនាគារជាតិនៃកម្ពុជា ក៏ដូចជាការចុះទៅត្រួតពិនិត្យដល់ទីតាំងរបស់គ្រឹះស្ថានផងដែរ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានៅតែបន្តគាំទ្រដល់គ្រឹះស្ថានក្នុងការពង្រីកបណ្តាញរបស់ខ្លួនសម្រាប់ផ្តល់សេវាទូទាត់សងប្រាក់ក្រៅប្រទេស ជាពិសេសជំរុញការផ្សព្វផ្សាយ និងការធ្វើប្រតិបត្តិការឌីជីថល ដែលអនុញ្ញាតឱ្យអតិថិជនអាចស្នើសុំធ្វើប្រតិបត្តិការផ្ទេរប្រាក់ពីគណនីរបស់ពួកគេបានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ការផ្លាស់ប្តូរនេះបានកាត់បន្ថយយ៉ាងខ្លាំងតម្រូវការសម្រាប់ប្រតិបត្តិការនៅតាមបណ្តាសាខាធនាគារដោយផ្ទាល់ជាពិសេសផ្តល់លទ្ធភាពឱ្យម្ចាស់អាជីវកម្ម អ្នកធុរកិច្ចសហគ្រាសខ្នាតតូចនិងមធ្យម អាចធ្វើការទូទាត់ទំនិញនៅក្រៅប្រទេសបានលឿនជាងមុន និងអាចគ្រប់គ្រងលំហូរសាច់ប្រាក់របស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព។

គិតត្រឹមឆ្នាំ២០២៤ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួនប្រមាណ ២៥ ទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការសេវាផ្ទេរប្រាក់អន្តរជាតិដែលស្ថិតក្រោមកិច្ចសហការសាកល្បងជាមួយដៃគូជាគ្រឹះស្ថានធនាគារ និងក្រុមហ៊ុនផ្ទេរប្រាក់នៅក្រៅប្រទេស ហើយប្រតិបត្តិការនេះដំណើរការយ៉ាងរលូននិងមានប្រសិទ្ធភាព ដែលភាគច្រើនបានជួយសម្រួលដល់ពលករទេសន្តរប្រវេសន៍ក្នុងការផ្ទេរប្រាក់មកក្រុមគ្រួសារ។ ចំពោះកម្រៃសេវាសម្រាប់អតិថិជន គ្រឹះស្ថានកំណត់ដោយផ្អែកលើចន្លោះទំហំប្រាក់ប្រតិបត្តិការ ឬគិតក្នុងតម្លៃជាក់លាក់ណាមួយក្នុងមួយប្រតិបត្តិការ ដែលគិតជាមធ្យមស្ថិតក្នុងចន្លោះ ០,៦% ទៅ ៥,២% នៃទំហំប្រាក់ផ្ទេរក្នុងមួយប្រតិបត្តិការ ដោយពុំគិតលើថ្លៃសេវាផ្សេងៗទៀតនោះទេ។ ចំណែកឯសេវាផ្ទេរប្រាក់អន្តរជាតិតាមច្បាបផ្សេងៗទៀត មានដូចជាការផ្ទេរប្រាក់តាមអ្នកដំណើរការតតិយភាគី មានកម្រៃគិតជាមធ្យមស្ថិតនៅចន្លោះ ០,៣៩% ទៅ ៣%

(បូករួមទាំងតម្លៃ Cable Charge បន្ថែម ជាមធ្យមដោយអាស្រ័យលើប្រទេសគោលដៅ ៥០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ) និងការផ្ទេរប្រាក់តាមប្រព័ន្ធស្វីស នៅរក្សាតម្លៃ ០,១៥% នៃទំហំប្រាក់ប្រតិបត្តិការ និងបូកបន្ថែមតម្លៃ Cable Charge ១៥ ដុល្លារអាមេរិក (តាមការកំណត់របស់ធនាគារភាគច្រើន)។

ក្នុងឆ្នាំ២០២៤ ចំនួនប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អ្នកដំណើរការតតិយភាគី និងកិច្ចសហការសាកល្បងរវាងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងដៃគូ មានចំនួនប្រមាណ ៤,១៣ លានប្រតិបត្តិការ (កើនឡើង ៩,៣%) និងទំហំប្រាក់មានចំនួនប្រមាណ ៦៩,១៥ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៧%) ស្មើនឹង ១៥៣,៨% នៃផ.ស.ស។ ការទូទាត់ទំនិញ និងសេវាផ្ទេរប្រាក់ឆ្លងដែននៅបន្តឆ្លងកាត់ប្រព័ន្ធស្វីសជាចម្បង ដោយសារប្រព័ន្ធនេះផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចទូទាត់បានក្នុងទំហំប្រាក់ធំៗ មានបណ្តាញទូលំទូលាយលើសកលលោក និងមានសុវត្ថិភាពខ្ពស់។ ក្រៅពីប្រព័ន្ធនេះ មានគ្រឹះស្ថានមួយចំនួនកំពុងអនុវត្ត និងរៀបចំដាក់ឱ្យដំណើរការសាកល្បងនូវសេវាផ្ទេរប្រាក់អន្តរជាតិផ្សេងទៀត មានដូចជា ការតភ្ជាប់ប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ វីសា និងម៉ាស្ទ័រកាត ជាដើម ដើម្បីធ្វើប្រតិបត្តិការបានរហ័សជាងមុន និងមានកម្រៃទាបជាងមុន។ ជាទូទៅ ទំហំប្រាក់សរុបនៃការផ្ទេរចេញតាមប្រព័ន្ធខាងលើនេះនៅរក្សាចំនួនធំជាងការផ្ទេរចូល ដោយអាស្រ័យលើកត្តាសកម្មភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ ចំណែកឯ សេវាផ្ទេរប្រាក់តាមរយៈក្រុមហ៊ុនផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែននៅក្រៅប្រទេស នៅបន្តទទួលបានការគាំទ្រខ្ពស់លើការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារ និងសម្រាប់ការទូទាត់អាជីវកម្មខ្នាតតូចនិងមធ្យម ដោយសារសេវានេះមានកម្រៃសេវាទាប ដែលនាំឱ្យទំហំប្រតិបត្តិការតាមសេវានេះមានការកើនឡើងច្រើន និងមានទំហំប្រាក់ផ្ទេរចូលច្រើនជាងការផ្ទេរចេញ។

**ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចាប់តាំងពីឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការនូវប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System - ITRS) ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងជាមធ្យោបាយដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រាយការណ៍អំពីការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន។ គិតត្រឹមឆ្នាំ២០២៤ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥៩ កំពុងរាយការណ៍តាមរយៈប្រព័ន្ធ ITRS នេះ។ ការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន ជាការផ្ទេរប្រាក់ផ្លូវការបែបអេឡិចត្រូនិកចម្បងមួយ តាមរយៈប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ហើយការផ្ទេរប្រាក់នេះភាគច្រើនធ្វើឡើងដោយពលករទេសន្តរវេសន៍។ ក្នុងឆ្នាំ២០២៤ ពលករទេសន្តរប្រវេសន៍បានផ្ទេរប្រាក់មកក្រុមគ្រួសារពីប្រទេសកូរ៉េខាងត្បូងប្រមាណ ៥០,៨% នៃទំហំប្រាក់ផ្ទេរឆ្លងដែនជាលក្ខណៈឯកជនសរុប និងតាមពីក្រោយដោយសហរដ្ឋអាមេរិកចំនួន ១៨,៤% និងបន្តដោយប្រទេសជប៉ុន ៨,១% និងប្រទេសសិង្ហបុរី ៣,១%។ ធនាគារជាតិនៃកម្ពុជាដែលជាបញ្ញត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ បានលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលនិងសេវាថ្មីៗប្រកបដោយនវានុវត្តន៍ ដើម្បីចូលរួមចំណែកលើកកម្ពស់ដល់ការប្រកួតប្រជែងលើទីផ្សារ ក៏ដូចជាធ្វើឱ្យការផ្តល់សេវាផ្ទេរប្រាក់កាន់តែមានតម្លៃទាប ងាយស្រួល រហ័ស និងមានតម្លាភាពសម្រាប់អតិថិជន។ សរុបមក ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលនិងសេវាថ្មីៗទាំងនេះ ជាកត្តាដ៏សំខាន់ក្នុងការលើកទឹកចិត្តឱ្យសាធារណជនងាកមកប្រើប្រាស់សេវាផ្ទេរប្រាក់តាមរយៈបណ្តាញផ្លូវការវិញ។

**ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៦.៣. កិច្ចសហប្រតិបត្តិការពហុភាគីលើគម្រោងទូទាត់សងប្រាក់ឆ្លងដែន

### ក. កិច្ចសហប្រតិបត្តិការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ (RPC)

ធនាគារកណ្តាលឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។ ការចុះហត្ថលេខាលើ MOU នោះធ្វើឡើងក្នុងគោលបំណង (១) ពង្រឹងកិច្ចសហប្រតិបត្តិការលើការតភ្ជាប់ការទូទាត់សងប្រាក់ពហុភាគី (២) ដើម្បីសម្រួលដល់ការទូទាត់សងប្រាក់ឆ្លងដែនឱ្យបានកាន់តែលឿន តម្លៃសមរម្យ តម្លាភាព និងបរិយាបន្ន (៣) ធានាបាននូវយន្តការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យប្រព័ន្ធឱ្យមានប្រសិទ្ធភាព និង (៤) ធានាថាអ្នកប្រើប្រាស់ត្រូវបានការពារសម្រាប់ប្រតិបត្តិការទូទាត់ឆ្លងដែន។ គម្រោង RPC ត្រូវបានកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន ចាត់ទុកជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងបានប្រគល់ភារកិច្ចឱ្យក្រុមការងារគណៈកម្មការប្រព័ន្ធទូទាត់អាស៊ាន (WC-PSS) ធ្វើការជំរុញកិច្ចសហប្រតិបត្តិការក្នុងការតភ្ជាប់ការទូទាត់ក្នុងតំបន់នេះឱ្យបានគ្រប់ប្រទេសនៅក្នុងតំបន់ និងសហការជាមួយក្រុមការងារគណៈកម្មការបរិយាបន្នហិរញ្ញវត្ថុ ដើម្បីចូលរួមក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ធនាគារកណ្តាលវៀតណាមបានចុះអនុស្សរណៈយោគយល់គ្នា បន្ថែមនៅអំឡុងពេលកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលលើកទី១០ នៅប្រទេសឥណ្ឌូនេស៊ី។ ទន្ទឹមនោះក្នុងឆ្នាំ២០២៤ មានធនាគារកណ្តាលចំនួនពីរបានចុះអនុស្សរណៈបន្ថែមរួមមាន ធនាគារកណ្តាលប្រ៊ុយណេបានចុះអនុស្សរណៈយោគយល់គ្នាបន្ថែម កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ និងធនាគារកណ្តាលឡាវក៏បានចុះអនុស្សរណៈយោគយល់គ្នាបន្ថែម កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤។ជាមួយគ្នានោះដែរ នាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី១១ កាលពីខែមេសា ឆ្នាំ២០២៤ នៅប្រទេសឡាវ ក៏បានជំរុញឱ្យប្រទេសជាសមាជិកអាស៊ានផ្សេងទៀតបន្តចូលរួមក្នុងគម្រោង RPC ដើម្បីជំរុញកិច្ចសហប្រតិបត្តិការក្នុងការតភ្ជាប់ការទូទាត់ក្នុងតំបន់នេះឱ្យបានកាន់តែទូលំទូលាយ។

ដើម្បីចូលរួមអនុវត្តការងារខាងលើជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានផ្សេងទៀតប្រកបដោយពិលាស ធនាគារជាតិនៃកម្ពុជាបានផ្ញើលិខិតបញ្ជាក់ពីគោលបំណងក្នុងការចូលរួមចុះ MOU ស្តីពី ការតភ្ជាប់ការទូទាត់សងប្រាក់ក្នុងតំបន់ទៅធនាគារកណ្តាលអាស៊ានទាំងប្រាំបីខាងលើ និងបានទទួលលិខិតឆ្លើយតបជាវិជ្ជមានរួចរាល់ហើយ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងរង់ចាំ និងពិនិត្យមើលខ្លឹមសារនៃ MOU ដើម្បីចុះហត្ថលេខាចូលរួមក្នុងគម្រោងនេះជាផ្លូវការ។

### ខ. សមាជិកអង្កេតការណ៍ក្នុងគម្រោង Nexus

មជ្ឈមណ្ឌលនវានុវត្តន៍របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BISIH) បានអភិវឌ្ឍគម្រោង Nexus ដែលជាគម្រោងតភ្ជាប់ប្រព័ន្ធទូទាត់ពហុភាគីសម្រាប់បណ្តាប្រទេសអាស៊ាន ហើយគម្រោងនេះត្រូវបានអនុម័តពីកិច្ចប្រជុំលើកទី១៨ ថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន កាលពីខែមេសា ឆ្នាំ២០២២ និងត្រូវបានក្រុមការងារគណៈកម្មការប្រព័ន្ធទូទាត់អាស៊ាន (WC-PSS) កំណត់ជាការងារអាទិភាពថ្មីមួយនៅក្នុងឆ្នាំ២០២៣ ក្នុងគោលបំណងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងអនុញ្ញាតឱ្យប្រជាជននៅក្នុងប្រទេសអាស៊ាន មានលទ្ធភាពទទួលបានការប្រើប្រាស់សេវាទូទាត់ឆ្លងដែនដែលមានតម្លៃសមរម្យ រហ័ស និងសុវត្ថិភាព។ ធនាគារកណ្តាលក្នុងប្រទេសសមាជិកអាស៊ាន ៤ និងប្រទេសឥណ្ឌាបានចូលរួមក្នុងគម្រោង Nexus និង BISIH បានអភិវឌ្ឍដំណាក់កាលទី១ និងទី២ រួចរាល់ និងបានបន្តអភិវឌ្ឍសម្រាប់ដំណាក់កាលទី៣ ដែលផ្តោតលើការងារចំនួនបី រួមមាន៖ i). បច្ចេក-វិទ្យានិងប្រតិបត្តិការ ii). ធុរកិច្ចនិងអាជីវកម្ម និង iii). អភិបាលកិច្ច ដែលការងារទាំងនេះបានបញ្ចប់នៅត្រីមាសទី១ ឆ្នាំ២០២៤។ ធនាគារជាតិនៃកម្ពុជា បានចូលរួមជាអ្នកអង្កេតការណ៍ពិសេសអាស៊ានក្នុងការអភិវឌ្ឍគម្រោង Nexus កាលពីខែកញ្ញា ឆ្នាំ២០២៣ ដែលបានផ្តល់លទ្ធភាពដល់ក្រុមការងារធនាគារជាតិនៃកម្ពុជាទទួលបានព័ត៌មានលម្អិតនៃវឌ្ឍនភាពគម្រោង ក៏ដូចជាបញ្ហាប្រឈមនានាដើម្បីយកមកសិក្សាវាយតម្លៃ និងពិចារណាសម្រាប់ការចូលរួមជាសមាជិកក្នុងគម្រោងនាពេលអនាគត។

កាលពីខែកក្កដា ឆ្នាំ២០២៤ BISIH បានចាប់ផ្តើមអភិវឌ្ឍដំណាក់កាលទី៤ ជាមួយប្រទេសចំនួន ៥ (ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងឥណ្ឌា) រីឯប្រទេសឥណ្ឌូនេស៊ី កម្ពុជា ឡាវ និងវៀតណាម បន្តជាអ្នកសង្កេតការណ៍ពិសេសនៅឡើយ។ ក្នុងដំណាក់កាលទី៤នេះ គម្រោង Nexus នឹងធ្វើប្រតិបត្តិការផ្ទាល់ជាមួយប្រទេសជាសមាជិកគម្រោង និងជួយសម្របសម្រួលក្នុងការបង្កើតអង្គការ Nexus Scheme ដែលជាអង្គភាពទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោង Nexus ក៏ដូចជាបន្តសកម្មភាពចាំបាច់ផ្សេងៗដើម្បីសម្រេចបាននូវការតភ្ជាប់ការទូទាត់ឆ្លងដែនពហុភាគីតាមពេលវេលាកំណត់។

### គ. សមាជិកអង្កេតការណ៍ក្នុងគម្រោង mBridge

មជ្ឈមណ្ឌលនវានុវត្តន៍ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BISIH) បាននិងកំពុងផ្តួចផ្តើមក្នុងការអភិវឌ្ឍគម្រោង mbridge ដែលមានសក្តានុពលក្នុងការធ្វើអន្តរប្រតិបត្តិការលើរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល ដោយបង្កើនល្បឿន និងប្រសិទ្ធភាពលើប្រតិបត្តិការទូទាត់ឆ្លងដែន។ កន្លងមក ប្រតិបត្តិការទូទាត់ឆ្លងដែនបែបប្រពៃណី តម្រូវឱ្យមានអន្តរការីច្រើន ដែលបណ្តាលឱ្យមានការពន្យារពេល ថ្លៃសេវាខ្ពស់ និងកង្វះតម្លាភាព ដូចនេះ គម្រោង mBridge នឹងសិក្សាលើលទ្ធភាពក្នុងការប្រើប្រាស់រូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល ដើម្បីដោះស្រាយបញ្ហាទូទាត់ឆ្លងដែនខាងលើ។ សមាជិកចូលរួមនៅក្នុងគម្រោងនេះរួមមាន អាជ្ញាធររូបិយវត្ថុហុងកុង ធនាគារកណ្តាលថៃ និងធនាគារកណ្តាល ប្រទេសអារ៉ាប់រួម ព្រមទាំងមានសមាជិកអង្កេតការណ៍ពីធនាគារ

កណ្តាល និងស្ថាប័នហិរញ្ញវត្ថុជាច្រើនផងដែរ ក្នុងនោះធនាគារជាតិនៃកម្ពុជា បានចូលរួមជាសមាជិកអង្កេតការណ៍តាំងពីដើមឆ្នាំ២០២៤។

គម្រោង mBridge បានឈានដល់ដំណាក់កាលផលិតផលដែលអាចសម្រេចបានអប្បបរមា (minimum viable product (MVP) stage) នៅពាក់កណ្តាលឆ្នាំ ២០២៤ ដែលមានគោលបំណងតភ្ជាប់ថ្នាលរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល (CBDC) ដែលចូលរួមដោយធនាគារកណ្តាល និងធនាគារពាណិជ្ជ ប្រើប្រាស់បច្ចេកវិទ្យាឌីអិលធី (DLT) ដើម្បីធ្វើការទូទាត់ និងទូទាត់ឆ្លងដែនភ្លាមៗ។

# ៧ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល

អភិបាលកិច្ចនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គ្របដណ្តប់ទាំងផ្នែកគោលនយោបាយ និងផ្នែកបច្ចេកទេស។ អភិបាលកិច្ចកម្រិតគោលនយោបាយរួមមាន បទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាពបណ្តាញការទូទាត់សងប្រាក់ តម្រូវការកម្រិតនៃការផ្តល់សិទ្ធ វិធានការប្រឆាំងការសម្អាតប្រាក់ អត្តសញ្ញាណឌីជីថល និងការទទួលបានការអប់រំនិងជំនាញឌីជីថល។ អភិបាលកិច្ចនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលកម្រិតបច្ចេកទេស ផ្តោតលើសសរស្តម្ភចំនួនបួន រួមមាន អត្តសញ្ញាណឌីជីថល (Digital Identity) ការអនុញ្ញាតនិងការផ្តល់សិទ្ធ (Authorization and Consent) អន្តរប្រតិបត្តិការប្រព័ន្ធទូទាត់ (Payment Interoperability) និងផ្លែតហ្វមសម្រាប់ចែករំលែកព័ត៌មាននិងទិន្នន័យ (Data Exchange) ដែលជំរុញនិងសម្រួលដល់ការធ្វើប្រតិបត្តិការប្រកបដោយសុវត្ថិភាព សន្សំសំចៃថ្លៃប្រតិបត្តិការ លើកកម្ពស់បរិយាបន្ន និងប្រសិទ្ធភាព។ សារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គឺសម្រួលការផ្តល់សេវាសាធារណៈ ជំរុញកំណើនសេដ្ឋកិច្ចឌីជីថលតាមរយៈការផ្តល់ជាការផ្តួចផ្តើមនវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការថ្មីៗនៅលើគ្រប់វិស័យ។

## ៧.១. ហេតុអ្វីបានជាប្រព័ន្ធបាគងត្រូវបានចាត់ទុកជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល

កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធបាគង ដោយបានចាត់ទុកថាជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលដ៏សំខាន់មួយ ដោយសារតែប្រព័ន្ធនេះគឺជាប្រព័ន្ធទូទាត់ទំនើប ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ការទូទាត់ជាឌីជីថល អន្តរប្រតិបត្តិការសម្រាប់សាធារណជន។ ប្រព័ន្ធបាគងបានរួមចំណែកក្នុងការលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការជំរុញឱ្យមានការធ្វើអន្តរប្រតិបត្តិការរវាងគ្រឹះស្ថានជាសមាជិកដែលរួមមាន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រាប់បញ្ចូលទាំងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលការណ៍នេះបានពង្រីកនូវលទ្ធភាពក្នុងការធ្វើប្រតិបត្តិការប្រកបដោយភាពងាយស្រួល និងកាន់តែទូលំទូលាយជាងមុនដល់សាធារណជនទូទៅ។ លើសពីនេះ មុខងារទូទាត់ភ្លាមៗរបស់ប្រព័ន្ធបាគង បានជួយបង្កើនប្រសិទ្ធភាពនិងសម្រួលដល់ដំណើរការក្នុងការទូទាត់របស់រាជរដ្ឋាភិបាល ដូចជា ការប្រមូលពន្ធ និងសេវាសាធារណៈផ្សេងទៀតជាច្រើនបានកាន់តែប្រសើរ។ ក្នុងន័យនេះ ប្រព័ន្ធបាគងមិនត្រឹមតែជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាប្រព័ន្ធទូទាត់ដ៏សំខាន់ដែលជំរុញនិងសម្រួលដល់ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្ម សំដៅគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជាផងដែរ។

## ៧.២. ច្រករបៀងតម្លាភាពហិរញ្ញវត្ថុ ( Financial Transparency Corridor-FTC )

កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជានិងអាជ្ញាធររូបិយវត្ថុសិង្ហបុរីបាន ប្រកាសដាក់ឱ្យដំណើរការគម្រោង Financial Transparency Corridor (FTC) នៅអាគាររដ្ឋាភិបាល Istana នៃ សាធារណរដ្ឋសិង្ហបុរី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងឯកឧត្តម ឡរ៉េន វ៉ុង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋ **សិង្ហបុរី** ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុន (ការអនុញ្ញាត និងការផ្តល់សិទ្ធ) រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកនៃគម្រោងនេះនៅប្រទេសកម្ពុជា និងសិង្ហបុរី ដើម្បីសម្រួលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ក្នុងការធ្វើសកម្មភាព ពាណិជ្ជកម្មនិងហិរញ្ញវត្ថុឆ្លងដែន។ តាមរយៈច្រករបៀងនេះ MSMEs អាចមានលទ្ធភាពផ្គូរផ្គងតម្រូវការ រវាងគ្នាទៅវិញទៅមកបានកាន់តែងាយស្រួល និងអាចពង្រីកវិសាលភាពទីផ្សាររបស់ខ្លួនបានកាន់តែ ទូលំទូលាយ។ លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃប្រទេសទាំងពីរ អាចផ្លាស់ប្តូរ និងចែករំលែកព័ត៌មានរវាងគ្រឹះស្ថានជាដៃគូបានយ៉ាងឆាប់រហ័សប្រកបដោយភាពងាយស្រួល ដែលការណ៍ នេះនឹងរួមចំណែកសម្រួលដល់ការវាយតម្លៃហិរញ្ញប្បទានលើអាជីវកម្មឆ្លងដែនរបស់ MSMEs នៃ ប្រទេសទាំងពីផងដែរ។ ច្រករបៀងនេះ បានដើរតួយ៉ាងសំខាន់ក្នុងការអនុញ្ញាត និងការផ្តល់សិទ្ធ តាមរយៈការផ្តល់លទ្ធភាពក្នុងការចែករំលែកព័ត៌មាន MSMEs រវាងគ្រឹះស្ថានជាដៃគូដែលទទួល បានការអនុញ្ញាត និងផ្តល់សិទ្ធឱ្យទទួលយក ចែករំលែក និងប្រើប្រាស់នូវព័ត៌មានដែលចាំបាច់ទាំងនោះ ក្រោមគោលការណ៍ឯកជនភាព និងសុវត្ថិភាព។ ការណ៍នេះ នឹងរួមចំណែកបង្កើនទំនុកចិត្តក្នុង ប្រព័ន្ធទូទាត់ឌីជីថល និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងសកម្មភាពហិរញ្ញវត្ថុឆ្លងដែន។ បច្ចុប្បន្ន គ្រឹះស្ថានសមាជិកដែលរួមមានធនាគារអេស៊ីលីដា ស្ថាបនា ហ្វីលីព វីង និងវឌ្ឍនៈអាស៊ីចំកាត់ នៃ ប្រទេសកម្ពុជា និងគ្រឹះស្ថានចំនួន ៣ មកពីប្រទេសសិង្ហបុរីរួមមាន ANEXT Bank, Liquid Group និង Sing Investment and Finance បាននិងកំពុងតភ្ជាប់ប្រព័ន្ធជាមួយក្រុមហ៊ុន Proxtera។



## ៧.៣. គម្រោងសាកល្បង Universal Trusted Credentials ( UTC )



កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាសហប្រធាន (Co-chair) ជាមួយអង្គការសហប្រជាជាតិ (UNDP) និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធផ្សេង បានចាប់ផ្ដើមគម្រោងដំណើរការសាកល្បងគម្រោង Universal Trusted Credentials (UTC) ដែលផ្ដល់នូវថ្នាលទិន្នន័យ និងក្របខ័ណ្ឌទិន្នន័យជាក់លាក់មួយសម្រាប់ MSMEs និងចូលរួមដោះស្រាយបញ្ហាប្រឈមមួយចំនួនដែល MSMEs បាននិងកំពុងជួបប្រទះ ជាពិសេស ផលវិបាកក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ដែលការណ៍នេះនឹងឈានទៅដល់ការជំរុញលទ្ធភាពក្នុងការនាំចេញផលិតផលរបស់សហគ្រាសធុនតូច និងមធ្យមរបស់កម្ពុជា ទៅកាន់ប្រទេសជាដៃគូ។ គម្រោងនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងរៀបចំក្របខណ្ឌទិន្នន័យដែលសម្រួលដល់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងការកាត់បន្ថយហានិភ័យនៃកិច្ចសន្យាធានា MSMEs និងផ្ដល់លទ្ធភាពកាន់តែប្រសើរជាងមុនដល់ MSMEs ក្នុងការទទួលបានសេវាហិរញ្ញវត្ថុងាយស្រួល ព្រមទាំងអាចកាត់បន្ថយតម្រូវការនៃវត្ថុធានា។ គម្រោង UTC នេះ មិនត្រឹមតែសម្រួលដល់ដំណើរការនៃការបញ្ជាក់ព័ត៌មាន (Authentication Process) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងទំនុកចិត្តរវាងគ្រឹះស្ថានដោយធានាថាការអនុញ្ញាតនិងការផ្ដល់សិទ្ធ (Authorization and Consent) នៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គឺគោរពតាមតម្រូវការរបស់ម្ចាស់ទិន្នន័យនិងព័ត៌មាន។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជា ដែលជាសហប្រធានជាមួយ UNDP បានបង្កើតក្រុមការងារសាកល្បងដោយមានសមាជិកស្នូល រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" (Techo Start Up) ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សាជីវកម្មធានាឥណទានកម្ពុជា (Credit Guarantee Corporation of Cambodia) ការិយាល័យឥណទានកម្ពុជា (Credit Bureau Cambodia) និងសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់វិស័យឯកជន (Private Sector Advisory Body) រួមមាន ធនាគារអេស៊ីលីដា ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ធនាគារកាណាឌីយ៉ា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ធនាគារស្ថាបនា និងគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុអេ អឹម ខេ និងក្រុមហ៊ុន Banhji។ បច្ចុប្បន្ន ក្រុមការងារកំពុងអភិវឌ្ឍថ្នាលសម្រាប់ប្រើប្រាស់ក្នុងគម្រោង UTC។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ - ច្បាប់ និងបទប្បញ្ញត្តិ

| ល.រ | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១ | ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា | ១៩៩៦ |
| ២ | ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ | ១៩៩៧ |
| ៣ | ច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ | ១៩៩៩ |
| ៤ | ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០០៥ |
| ៥ | ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ២០២០ |
| ៦ | ច្បាប់ស្តីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ២០២០ |
| ៧ | ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ២០០៦ |
| ៨ | ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ | ២០០៦ |
| ៩ | ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ | ២០០៨ |
| ១០ | ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ២០០៨ |
| ១១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ២០១០ |
| ១២ | ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី | ២០១០ |
| ១៣ | ប្រកាសស្តីពី ការផ្តល់សទ្ធនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ | ២០១៤ |
| ១៤ | ប្រកាសស្តីពី សមាជិកភាពនៃប្រព័ន្ធ FAST System និង Central Shared Switch | ២០១៦ |
| ១៥ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ | ២០១៦ |
| ១៦ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធី Cambodian Shared Switch | ២០១៧ |
| ១៧ | ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៧ |

| ល.រ | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១៨ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) | ២០១៨ |
| ១៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay | ២០១៩ |
| ២០ | ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay | ២០២០ |
| ២១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ | ២០២០ |
| ២២ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង | ២០២០ |
| ២៣ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង | ២០២០ |
| ២៤ | ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ២០២០ |
| ២៥ | សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០១៦ |
| ២៦ | សារាចរណែនាំស្តីពី នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២១ |
| ២៧ | សេចក្តីជូនដំណឹងស្តីពី កម្រៃប្រតិបត្តិការផ្ទេរប្រាក់សម្រាប់ "សេវាទូទាត់រហ័ស" (FAST Payment System) | ២០១៧ |
| ២៨ | សេចក្តីជូនដំណឹងស្តីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច | ២០១៧ |
| ២៩ | សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) របស់សភាផាត់ទាត់ជាតិ | ២០១៨ |
| ៣០ | សេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ | ២០១៩ |
| ៣១ | សេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច | ២០២០ |
| ៣២ | សេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូឌាន-ស៊ែស្វីច | ២០២០ |
| ៣៣ | សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៤ | សេចក្តីណែនាំស្តីពី ការជ្រើសរើស និងការទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៥ | ឯកសារបាគង White Paper | ២០២០ |
| ៣៦ | សេចក្តីណែនាំស្តីពី "ការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់កិច្ចសហការផ្ទេរប្រាក់អន្តរជាតិ ក្នុងដំណាក់កាលសាកល្បង" | ២០២៣ |
| ៣៧ | សេចក្តីណែនាំស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២៤ |

| | | |
|---|---|---|
| ៣៨ | សេចក្តីណែនាំស្តីពី ការកែសម្រួលបរិច្ឆេទ និងរយៈពេលបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០២៤ |
| ៣៩ | សេចក្តីណែនាំបន្ថែមស្តីពី ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២៤ |
| ៤០ | ប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ | ២០២៤ |

# ឧបសម្ព័ន្ធ ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការ ប្រព័ន្ធបាគង | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការ ប្រព័ន្ធបាគង |
|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២១ | ធនាគារ អេស ប៊ី អាយ លីហ្វូរ ម.ក |
| ២ | ធនាគារ វីង (ខេមបូឌា) ម.ក | ២២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៣ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ៤ | ធនាគារ វឌ្ឍនៈ | ២៤ | ធនាគារ អូរៀនថល ម.ក |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ២៥ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី |
| ៦ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៧ | ធនាគារ ព្រីនស៍ ម.ក | ២៧ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ |
| ៨ | ធនាគារ កាណាឌីយ៉ា ក.អ | ២៨ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៩ | សាជីវកម្មធនាគារ កាថេយ្យូណៃធីតកម្ពុជា ចំកាត់ |
| ១០ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក | ៣០ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ១១ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ៣១ | ធនាគារ អាយ ស៊ី ប៊ី ស៊ី សាខាភ្នំពេញ |
| ១២ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣២ | ធនាគារ ស៊ី អាយ អិម ប៊ី ភីអិលស៊ី |
| ១៣ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ៣៣ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ |
| ១៤ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ៣៤ | ធនាគារ សាខម ប៊ែង ខេមបូឌា |
| ១៥ | ធនាគារ ហត្ថា ម.ក | ៣៥ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១៦ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣៦ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក |
| ១៧ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក | ៣៧ | ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក |
| ១៨ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | ៣៨ | ធនាគារ អឹម ប៊ី (ខេមបូឌា) ម.ក |
| ១៩ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | ៣៩ | ធនាគារ សហពាណិជ្ជ ក.អ |
| ២០ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ៤០ | ធនាគារ ឌីជីប៊ី ម.ក |

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការ ប្រព័ន្ធបាគង | ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការ ប្រព័ន្ធបាគង |
|---|---|---|---|
| ៤១ | ធនាគារ ប្រ៊ីដ ម.ក | ៥១ | គ្រឹះស្ថាន លីហ្វរ ផេប្រ៊ូ ភីអិលស៊ី |
| ៤២ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក | ៥២ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក |
| ៤៣ | ធនាគារ អាល់ហ្វា ម.ក | ៥៣ | គ្រឹះស្ថានធានស្ទ័ អ៊ិនធើណេសិនណល ថេកណូឡូជី ម.ក |
| ៤៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេ អឹម ខេ ភីអិលស៊ី | ៥៤ | គ្រឹះស្ថាន អេស៊ា វែស អិចប្រេស ម.ក |
| ៤៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ៥៥ | គ្រឹះស្ថាន ដាយ ផេ ម.ក |
| ៤៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អម្រឹត ម.ក | ៥៦ | គ្រឹះស្ថាន បងឡូយ ផេម៉ិន ម.ក |
| ៤៧ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មហានគរ ម.ក | ៥៧ | គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក |
| ៤៨ | គ្រឹះស្ថាន ស្ពីត ផេ ម.ក | ៥៨ | គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេម៉ិន សឺវីស ម.ក |
| ៤៩ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | ៥៩ | គ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក |
| ៥០ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេម៉ិន សឺលូសិន ម.ក | ៦០ | គ្រឹះស្ថាន តារាសាគរ ផេ ម.ក |

# ឧបសម្ព័ន្ធ ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក
អាគារលេខ ១៥ ផ្លូវលេខ ៣៩៧ ភូមិ៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
០៩៦ ៩៦៦ ៣៣៣៣ / ០៩៦ ៨១៥ ៧៣៨៨
www.edeel.com

គ្រឹះស្ថាន ស៊ីផែល ហ្វាយនែនសល សឺវីស ម.ក
អាគារលេខ១៩៩ ផ្លូវលេខ៤៣២ ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
០១៨ ៨៨០០ ៨០០
www.bestmpay.com

គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក
អាគារ Keystone (No.146) ជាន់ទី១-២-៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៩៩ ៦៣៩
www.truemoney.com.kh

គ្រឹះស្ថាន លី ហួរ ផេ ប្រ៊ូ ភីអិលស៊ី
ដីឡូតិ៍ ២៤៣-២៤៤ ការិយាល័យ (១៥C-៤១C) ផ្លូវ ៥៩៨ សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
០៨៧ ៦០១ ១១១
www.lyhourpay.com

គ្រឹះស្ថាន អាប៊ីត្រេរី ផេយ ម.ក
Mei Lian Garden Hotel លេខ៣១៥ វិទ្យាលេខ១១៣ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០១០ ៣៧០ ៨៨៨

គ្រឹះស្ថាន អាយផេ៨៨ (ខេមបូឌា) ម.ក
ផ្ទះលេខ១៣ (ជាន់ទី២) មហាវិថីហ្សាលដឺហ្គោល (២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩០១ ៧៨៨
www.ipay88.com.kh

គ្រឹះស្ថាន ផាយ ផេ ម.ក
ផ្ទះលេខ២០ ផ្លូវ ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០២៣ ៩៨៨ ៩៨៩
www.pipay.com

គ្រឹះស្ថាន ផានស៊ូ អ៊ិនធើណេសិនណាល ថេកណូឡូជី ម.ក
អគារលេខ ៤៨-៥០ ជាន់ទី៣ ផ្លូវ ៣១០ ភូមិ ២ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩៨៨ ៧៧៧
www.coolcashcam.com

គ្រឹះស្ថាន បងឡូយ ផេមិន ម.ក
ផ្ទះលេខ១០ ផ្លូវ២៨៨ ភូមិ៦ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៨១ ៩៩៩ ៦១៨
www.bongloy.asia

គ្រឹះស្ថាន អេស៊ា វៃលុយ អិចប្រេស ម.ក
ផ្ទះលេខ B២-០៣៥-០៣៦ ផ្លូវកោះពេជ្រ (ស្ពានឥន្ទនូ) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ៦៦៦ ៦៧៨ / ០៩៩ ៦៦៦ ៦៧៨ / ០៧១ ៦៦៦ ៦៧៨
www.asiaweiluy.com.kh

គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិន សឺលូសិន ម.ក
អគារលេខ២៣៨ (ROYAL K PLAZA) ជាន់ទី១៥ សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០៧១ ៦៥៥ ៥៦៦៦
www.emoney.com.kh

គ្រឹះស្ថាន ដ្រេហ្គនហ្វ្លាយ ហ្វីនថេក  (ខេមបូឌា) ម.ក
អាគារ ROSE GARDEN លេខ២៥២ ជាន់ផ្ទាល់ដី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៨ ២១៨ ៥៥៥
www.dragonfly.com.kh

គ្រឹះស្ថាន ដាយនៃមិក ផេមិន ម.ក
អគារម៉ហ្វែន ជាន់ទី៦ បន្ទប់លេខ០២ និង០៣ ផ្លូវសុរភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៩ ១៨៦ / dpkh@dynamicg.com

គ្រឹះស្ថាន តារាសាគរ ផេ ម.ក
ប្លុក៧៣ ជាន់ផ្ទាល់ដី អគារលេខ២ Phnom Penh City Center ផ្លូវ៦១៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៩៣ ៩៣៩ ៩៧៧
www.darasakorpay.com

គ្រឹះស្ថាន បៃ សេន ថេកណឡជី ម.ក
ផ្លូវលេខB១៨ ផ្លូវបេតុង ភូមិ០១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០៧១ ៩៩៩ ៧៧៧៩

គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក
ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវ ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៩៥៥ ៥៥៥៦

គ្រឹះស្ថាន ផារ៉ាហ្គន ផេមិន សឺវីស ម.ក
អាគារលេខ២១៦ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១២ ៤៥៦ ២៣៧

គ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក
អាគារលេខ១០៥ ជាន់ទី៤ ផ្លូវ ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០៧០ ២២២ ៧០៣
www.kessinnovation.io

គ្រឹះស្ថាន វ៉ន ផេ ម.ក
ផ្ទះលេខអេ១១ ផ្លូវលេខ២១០ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
០៩៩ ២៣៣ ២៣៣

គ្រឹះស្ថាន លីន ផេ ផេមិន សឹលូសិន ម.ក
ផ្ទះលេខ ៩០ ៩២ និង៩៤ ជាន់ទី១ (E-1) ផ្លូវលេខ ២១៧ សង្កាត់អូឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ
០៩៦ ៦៧៥ ៣៥៥៤
www.lync-pay.com

គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក
អាគារលេខ១ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨១ ៩៧៨ ៨៨៩ / ០៨៥ ៩៧៨ ៨៨៩
www.u-pay.com

គ្រឹះស្ថាន ស្តារផេ ហ្វីនថេក ម.ក
ដីឡូត៍លេខ២៧៨៧ ភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល
០៨១ ៩១៦ ១០៩

គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេមិន សឺវីស ម.ក
California Social House (West) លេខ ៥៧១-៥៧៥ D&E ជាន់ទី២ បន្ទប់លេខ០២
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០២៣ ៩០០ ០៩១ / ០២៣ ៩០០ ០៩១
www.lantonpay.com

គ្រឹះស្ថាន ឃ្លីក ផេមិន (ខេមបូឌា) ម.ក
DK Santuary លេខ ១២៨ EF ជាន់ទី៤ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០១០ ៩២៧ ៤៥០

គ្រឹះស្ថាន សាន់ផេ (ខេមបូឌា) ម.ក
អាគារ Morgan Tower, Unit 7/8a/8b, ជាន់ទី២០ ផ្លូវសុភមង្គល (កោះពេជ្រ) ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៩៦ ៦៧៨ ២៦៧៨

គ្រឹះស្ថាន កៃ ហ្វូ តុង ផេមិន ម.ក
សណ្ឋាគារប្លាទីនអន្តរជាតិ ផ្លូវប៉ូឡូវ៉ៃ ជាន់ទី ១ និងទី២ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
០៩៣ ៩២២ ២២៩
www.cpay168.com

គ្រឹះស្ថាន ផេយ៉ុន ម.ក
លេខ ៣F មជ្ឈមណ្ឌល PGCT ផ្លូវលេខ ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ៩៨៧ ៩៧៥
www.payon.com.kh

គ្រឹះស្ថាន ជីន ហុង ជិន ថេកណឡូជី ម.ក
ផ្ទះលេខ ៣៨ ផ្លូវលេខ ៩៦៨ ភូមិ១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ
០៨៨ ៣២៣ ១១៨៨៨
https://www.dvpay.com

គ្រឹះស្ថាន ផេនទ័រ (ខេមបូឌា) ម.ក
អគារលេខ៦៨៥ ជាន់ទី១-២ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
០២៣ ៩០២ ២៨៩/០២៣ ៩០២ ២៥៥
www.pentorcambodia.com.kh

# ឧបសម្ព័ន្ធ ៤ - គ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក

## ១. គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២១ | ធនាគារ មីហ្សូហូ អិលធីឌី |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២២ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៣ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២៣ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក |
| ៤ | ធនាគារ ចិន | ២៤ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៥ | ធនាគារ ព្រីនស៍ ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | ២៧ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៨ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ៣០ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១១ | សាជីវកម្មធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ | ៣១ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ |
| ១២ | ធនាគារ ពាណិជ្ជទីមួយ | ៣២ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣៣ | ធនាគារ វឌ្ឍនៈ |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣៤ | ធនាគារ ឌីជីប៊ី ម.ក |
| ១៥ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣៥ | សាខាធនាគារកសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១៦ | សាខាធនាគារ អ៊ិនដាសស្មៀល ប៊ែង អហ្វ ខូរៀ ភ្នំពេញ | ៣៦ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៧ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៧ | ធនាគារ អូរៀនថល ម.ក |
| ១៨ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | ៣៨ | ធនាគារ អូរី (ខេមបូឌា) ម.ក |
| ១៩ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | ៣៩ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ២០ | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ | | |

## ២. គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារចល័ត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | ២០ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២១ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៣ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | ២២ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៤ | ធនាគារ ចិន | ២៣ | ធនាគារ អេស ប៊ី អាយ លីហ្វូ ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៥ | ធនាគារ សហពាណិជ្ជ ក.អ |
| ៧ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ២៦ | ធនាគារ វឌ្ឍនៈ |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៧ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៨ | ធនាគារ ឌីជីប៊ី ម.ក |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៩ | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី |
| ១១ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣០ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១២ | ធនាគារ ហត្ថា ម.ក | ៣១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក |
| ១៣ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | ៣២ | ធនាគារ អូរៀនថល ម.ក |
| ១៤ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | ៣៣ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ១៥ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | ៣៤ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក |
| ១៦ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | ៣៥ | ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក |
| ១៧ | ធនាគារ ហ្វីលីព ភីអិលស៊ី | ៣៦ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក |
| ១៨ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | ៣៧ | ធនាគារ ខេប៊ីប្រាសាក់ ម.ក |
| ១៩ | ធនាគារ ព្រីនស៍ ម.ក | ៣៨ | ធនាគារ ភីក វេល ម.ក |

## ឧបសម្ព័ន្ធ ៥ - គោលការណ៍ទាំង ២៤ របស់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI)

| គោលការណ៍ | PSs | CSDs | SSSs | CCPs | TRs |
|---|---|---|---|---|---|
| ១. មូលដ្ឋានគតិយុត្ត | • | • | • | • | • |
| ២. អភិបាលកិច្ច | • | • | • | • | • |
| ៣. ក្របខណ្ឌសម្រាប់គ្រប់គ្រងហានិភ័យ | • | • | • | • | • |
| ៤. ហានិភ័យឥណទាន | • | | • | • | |
| ៥. ប្រាតិភោគ | • | | • | • | |
| ៦. ម៉ាជីន | | | | • | |
| ៧. ហានិភ័យសន្ទនីយភាព | • | | • | • | |
| ៨. ការទូទាត់បញ្ចប់ | • | | • | • | |
| ៩. សាច់ប្រាក់ទូទាត់ | • | | • | • | |
| ១០. ការដោះដូរឧបករណ៍ទូទាត់ជារូបវន្ត | | • | • | • | |
| ១១. មជ្ឈមណ្ឌលរក្សាទុកមូលបត្រកណ្ដាល | | • | | | |
| ១២. ប្រព័ន្ធទូទាត់ប្រតិបត្តិការប្ដូរប្រាក់ | • | | • | • | |
| ១៣. វិធាននិងនីតិវិធីស្ដីពីការទូទាត់បរាជ័យរបស់អ្នកចូលរួម | • | • | • | • | |
| ១៤. ការបែងចែកនិងប្រតិបត្តិការផ្ទេរមូលនិធិ ឬមូលបត្រពីភាគីមួយទៅភាគីមួយ | | | | • | |
| ១៥. ហានិភ័យធុរកិច្ចទូទៅ | • | • | • | • | • |
| ១៦. ហានិភ័យក្នុងការគ្រប់គ្រង និងវិនិយោគ | • | • | • | • | |
| ១៧. ហានិភ័យប្រតិបត្តិការ | • | • | • | • | • |
| ១៨. ការចូលជាសមាជិកប្រើប្រព័ន្ធ | • | • | • | • | • |
| ១៩. ការចាត់ថ្នាក់សមាជិកចូលរួម | • | • | • | • | • |
| ២០. ការតភ្ជាប់គ្នារបស់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ | | • | • | • | • |
| ២១. ប្រសិទ្ធភាព និងប្រសិទ្ធផល | • | • | • | • | • |
| ២២. ស្តង់ដារនិងនីតិវិធីទំនាក់ទំនង | • | • | • | • | • |
| ២៣. ការបង្ហាញវិធាននិងនីតិវិធី និងទិន្នន័យ | • | • | • | • | • |

| | | | | | |
|---|---|---|---|---|---|
| ២៩. ការបង្ហាញទិន្នន័យទីផ្សារដោយមជ្ឈមណ្ឌលរក្សាទុកទិន្នន័យជួញដូរ | | | | | • |
| PSs = ប្រព័ន្ធទូទាត់សងប្រាក់, CSDs = មជ្ឈមណ្ឌលរក្សាទុកមូលបត្រ, SSSs = ប្រព័ន្ធផាត់ទាត់មូលបត្រ, CCPs = មជ្ឈមណ្ឌលផាត់ទាត់បដិភាគី, TRs = មជ្ឈមណ្ឌលរក្សាទុកទិន្នន័យជួញដូរឧបករណ៍និស្សន្ទ | | | | | |

